

# ការគាំទ្រ កុមាររងគ្រោះ និងកុមារជាសាក្សី

សៀវភៅណែនាំសម្រាប់អ្នកអនុវត្តវិជ្ជាជីវៈដែលធ្វើការជាមួយកុមាររងគ្រោះ និងកុមារជាសាក្សី

HAGAR
the whole journey

## សេចក្តីថ្លែងអំណរគុណ

ការរៀបចំសៀវភៅណែនាំនេះអាចប្រព្រឹត្តទៅបានដោយសារតែមានការរួមចំណែកដែលមិនអាចកាត់ថ្លៃបានរបស់ដៃគូដូចខាងក្រោមដែលបានគាំទ្រយ៉ាងសប្បុរសធម៌ចំពោះការងាររបស់អង្គការហាការកម្ពុជា (Hagar Cambodia) ៖

- យូនីសេហ្វ (UNICEF)
- Linklaters LLP ដែលបានគាំទ្រការងាររបស់មេធាវីបរទេសក្នុងការបញ្ចប់សៀវភៅណែនាំនេះ ព្រមទាំងផ្តល់នូវការស្រាវជ្រាវផ្នែកច្បាប់ដោយមិនគិតកម្រៃ
- E3 Reloaded ដែលបានផ្តល់នូវសេវារចនាទស្សនាទានដោយមិនគិតកម្រៃ
- Cheeky Monkey Productions and Tanya Bennett ដែលបានផ្តល់ការថតជាវីដេអូ និងស្នាដៃសិល្បៈដោយមិនគិតកម្រៃ ដើម្បីបង្កើតគំនូរជីវចលសម្រាប់កុមារ

# ការគាំទ្រកុមាររងគ្រោះ និងកុមារជាសាក្សី

អង្គការហាការ សូមស្វាគមន៍ចំពោះការចែកឱ្យប្រើប្រាស់ និងការផ្សព្វផ្សាយសៀវភៅណែនាំនេះ សម្រាប់គោលបំណងមិនដើម្បីធ្វើជំនួញ តែសូមឱ្យមានការផ្តល់នូវការទទួលស្គាល់នូវស្នាដៃរបស់អ្នកនិពន្ធ និងអង្គការបោះពុម្ពផ្សាយឱ្យបានសមរម្យ ។ រក្សាសិទ្ធិដោយអង្គការហាការ ។ ទទួលបានវិញ្ញាបនប័ត្រ តាមរយៈលក្ខខណ្ឌនៃ Creative Commons Attribution Non-Commercial License (CC BY-NC 4.0), creativecommons.org/licenses/by-nc/4.0/.

របាយការណ៍នេះត្រូវបានដកស្រង់ពី **Papworth, D** (២០១៦) ការគាំទ្រកុមារក្នុងដំណើរការច្បាប់ សៀវភៅណែនាំសម្រាប់អ្នកអនុវត្តវិជ្ជាជីវៈដែលធ្វើការជាមួយកុមាររងគ្រោះ និងកុមារជាសាក្សី អង្គការហាការ (Hagar) អង្គការយូនីសេហ្វ (UNICEF) រាជធានីភ្នំពេញ ប្រទេសកម្ពុជា ។

HAGAR
the whole journey



# មាតិកា


| | |
|---|---|
| សេចក្តីផ្តើម | 06 |
| ទិដ្ឋភាពទូទៅនៃនីតិវិធីច្បាប់ដើម្បីការពារកុមាររងគ្រោះ និងកុមារជាសាក្សី | 08 |
| ផែនការយុទ្ធសាស្រ្តសម្រាប់គាំទ្រកុមារជាសាក្សី | 40 |
| ការយល់ដឹងអំពីកុមារ និងការប៉ះទង្គិចផ្លូវចិត្ត | 46 |
| ការប្រមូលភស្តុតាងពីកុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត | 58 |
| ការត្រៀមខ្លួនកុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តសម្រាប់តុលាការ-សម្រាប់មេធាវី | 66 |
| ការត្រៀមខ្លួនកុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តសម្រាប់តុលាការ-សម្រាប់អ្នកគាំទ្រមិនមែនផ្នែកច្បាប់ | 76 |
| ថ្ងៃសវនាការ | 88 |




# សេចក្ដីផ្ដើម

## ហេតុអ្វីបានជាយើងត្រូវការឧបករណ៍ពិសេសដើម្បីគាំទ្រកុមាររងគ្រោះ និងកុមារជាសាក្សី?

ដំណើរការយុត្តិធម៌អាចមានភាពគួរឱ្យភ័យខ្លាច និងតានតឹងសម្រាប់អ្នកដែលជាជនរងគ្រោះ ឬសាក្សីនៃបទល្មើសព្រហ្មទណ្ឌ។ សម្រាប់កុមារដំណើរការនេះអាចមានការលំបាកជាពិសេស ។

វាហាក់ដូចជាកុមារដែលជាជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ និងការរំលោភបំពាននឹងទទួលរងពីការប៉ះទង្គិចផ្លូវចិត្តដោយសារហេតុការណ៍ទាំងនោះ ។ ការប៉ះទង្គិចផ្លូវចិត្តប៉ះពាល់ដល់របៀបដែលពួកគេគិត របៀបនៃឥរិយាបទរបស់ពួកគេ និងរបៀបដែលពួកគេពាក់ព័ន្ធនឹងមនុស្សផ្សេងទៀត ។ វាក៏អាចប៉ះពាល់ដល់សមត្ថភាពរបស់ពួកគេក្នុងការផ្ដល់ភស្តុតាងនៅក្នុងតុលាការ និងសមត្ថភាពក្នុងការទទួលយកយុត្តិធម៌ពីបទល្មើសដែលអាចត្រូវបានប្រព្រឹត្តប្រឆាំងនឹងពួកគេផងដែរ ។

ជាងនេះទៀត ដំណើរការយុត្តិធម៌ រួមបញ្ចូលទាំងការដែលត្រូវតែផ្ដល់សក្ខីកម្មនៅក្នុងតុលាការអាចជាបទពិសោធន៍ដែលប៉ះទង្គិចផ្លូវចិត្តខ្លួនឯងនៅក្នុង និងនៃដំណើរការនោះផ្ទាល់ផងដែរ ។ កុមាររងគ្រោះងាយទទួលរងក្នុងការធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តបន្ថែម ឬការធ្វើឱ្យប៉ះទង្គិចផ្លូវចិត្តឡើងវិញ ដែលត្រូវបានពន្យល់បន្ថែមនៅក្នុងជំពូកបន្ទាប់ ។

ដូច្នេះវាជាការសំខាន់ណាស់ដែលត្រូវប្រើប្រាស់ឧបករណ៍ពិសេស-វិធានការកុមារមេត្រី-ដើម្បីគាំទ្រកុមាររងគ្រោះ និងកុមារជាសាក្សីដែលចាំបាច់ត្រូវចូលរួមក្នុងដំណើរការយុត្តិធម៌ ។

## តើអ្វីទៅជាគោលបំណងនៃកម្មវិធីនៃការត្រៀមខ្លួនសម្រាប់តុលាការ?

វាជាការសំខាន់ណាស់ដែលកុមាររងគ្រោះ និងកុមារជាសាក្សីទទួលបានការគាំទ្រប្រសើរបំផុតតាមដែលអាចធ្វើទៅបាន ខណៈដែលពួកគេចូលរួមនៅក្នុងដំណើរការយុត្តិធម៌ ។ ប្រការនេះនឹងសម្រេចបាននូវគោលដៅសំខាន់ៗចំនួនពីរៈ

- កាត់បន្ថយភាពតានតឹង និងការប៉ះទង្គិចផ្លូវចិត្តចំពោះកុមារឱ្យនៅកម្រិតអប្បបរមា ។
- កែលម្អសមត្ថភាពរបស់ពួកគេក្នុងការផ្ដល់នូវភស្តុតាងដែលត្រឹមត្រូវល្អបំផុតនៅពេលជំនុំជម្រះ ។

## តើសៀវភៅណែនាំនេះមានគោលបំណងសម្រាប់អ្នកណា?

សៀវភៅណែនាំនេះមានគោលបំណងសម្រាប់អ្នកវិជ្ជាជីវៈដែលគាំទ្រកុមារដែលត្រូវឆ្លងកាត់ដំណើរការយុត្តិធម៌ ។នេះអាចរួមបញ្ចូលទាំងឪពុកម្ដាយ និងអាណាព្យាបាលរបស់កុមារ អ្នកប្រឹក្សាយោបល់ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល បុគ្គលិកគាំពារកុមារមេធាវី និងអ្នកគាំទ្រផ្សេងទៀត ។ យើងក៏លើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្ដល់សេវាផ្សេងទៀតដែលគាំទ្រកុមារឆ្លងកាត់ដំណើរការយុត្តិធម៌ ប្រើប្រាស់វាជាឧបករណ៍នេះក្នុងការបណ្ដុះបណ្ដាលជាបន្តសម្រាប់បុគ្គលិករបស់ពួកគេផងដែរ ។

នៅក្នុងសៀវភៅណែនាំនេះ យើងបានបញ្ចូលឧបករណ៍ងាយស្រួលប្រើ និងបញ្ជីផ្ទៀងផ្ទាត់សមស្រប ដើម្បីធ្វើឱ្យការងាររបស់អ្នកកាន់តែងាយស្រួល ។





# ទិដ្ឋភាពទូទៅនៃ
# នីតិវិធីច្បាប់



## ការប្រើប្រាស់ច្បាប់ដើម្បីការពារកុមារនៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការយុត្តិធម៌

ចាប់ពីពេលដែលកំណត់ហេតុត្រូវបានធ្វើឡើងអំពីបទល្មើសប្រឆាំងនឹងកុមារ បុគ្គលទាំងឡាយដែលគាំទ្រកុមារត្រូវខិតខំប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីការពារឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារ។ ឧបករណ៍ដ៏សំខាន់បំផុតមួយដើម្បីធ្វើកិច្ចការនេះ គឺការប្រើច្បាប់។

សម្រាប់អ្នកប្រឹក្សាយោបល់ បុគ្គលិកសង្គមកិច្ច បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ឬបុគ្គលមិនមែនផ្នែកច្បាប់ដែលគាំទ្រកុមារតាមរយៈដំណើរការតុលាការ វាជាការសំខាន់ណាស់ដែលអ្នកមានការយល់ដឹងជាមូលដ្ឋានអំពីដំណើរការដែលពាក់ព័ន្ធក្នុងការនាំយកសំណុំរឿងទៅកាន់តុលាការ។

**ហេតុអ្វី?**

- អ្នកនឹងអាចគាំទ្រកុមារបានកាន់តែប្រសើរ ឆ្លើយនឹងសំណួរមួយចំនួនរបស់កុមារ និងរំពឹងទុកជាមុននូវព្រឹត្តិការណ៍គួរឱ្យតានតឹង ឬភ័យខ្លាចនៅក្នុងដំណើរការតុលាការ។
- អ្នកអាចជាមនុស្សម្នាក់ក្នុងចំណោមមនុស្សមួយចំនួនតូចដែលកុមារទុកចិត្ត។ អ្នកអាចជួយពន្យល់រឿងរ៉ាវដល់កុមារអំពីដំណើរការតុលាការ និងកសាងភាពជឿជាក់របស់គាត់ ឬនាង។
- អ្នករាល់គ្នាអាចប្រើប្រាស់ច្បាប់ដើម្បីការពារកុមារ! មិនមែនមានតែមេធាវីដែលអាចចាត់វិធានការនានាក្នុងការប្រើច្បាប់ដើម្បីការពារកុមាររងគ្រោះ/សាក្សីជាកុមារនោះទេ។

សម្រាប់មេធាវី - ពិនិត្យមើលឡើងវិញលើជំពូកនេះសម្រាប់ទិដ្ឋភាពទូទៅនៃច្បាប់ដែលអ្នកអាចប្រើប្រាស់ ដើម្បីការពារកូនក្តីជាកុមាររបស់អ្នក។

ដ្យាក្រាមនៅចុងបញ្ចប់នៃជំពូកនេះ សង្ខេបអំពីរបៀបដែលអ្នកអាចប្រើប្រាស់ច្បាប់ដើម្បីការពារកុមាររងគ្រោះ ឬសាក្សីជាកុមារនៅដំណាក់កាលនីមួយៗនៃដំណើរការយុត្តិធម៌ចាប់ពីពេលឧប្បត្តិហេតុ រហូតដល់ការជំនុំជម្រះ។



## ប្រភេទនៃបទល្មើស និងប្រភេទនៃការស៊ើបអង្កេត

### ប្រភេទផ្សេងៗនៃបទល្មើស

មានប្រភេទបទល្មើសព្រហ្មទណ្ឌផ្សេងៗគ្នាចំនួន ៣ ដែលប្រភេទនីមួយៗមានទោសទណ្ឌខុសៗគ្នា ។

| | | |
|---|---|---|
| បទលហុ | ជាប់ពន្ធនាគារ អតិបរមារយៈពេល ៦ ថ្ងៃ | **ឧទាហរណ៍:** ការប៉ុនប៉ងលួចកង់ |
| បទមជ្ឈិម | ជាប់ពន្ធនាគារអតិបរមារយៈពេលចាប់ពី ៧ ថ្ងៃ ដល់ ៥ ឆ្នាំ | **ឧទាហរណ៍:** អំពើអាសអាភាស |
| បទឧក្រិដ្ឋ | ជាប់ពន្ធនាគារអតិបរមារយៈពេលលើសពី ៥ ឆ្នាំ | **ឧទាហរណ៍:** ឃាតកម្ម ការរំលោភសេពសន្ថវៈ |

ការប៉ុនប៉ងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ(ទោះបីជាការប៉ុនប៉ងទាំងនោះមិនជោគជ័យក៏ដោយ)ក៏ត្រូវបានផ្តន្ទាទោសផងដែរ ។

### ប្រភេទផ្សេងៗនៃការស៊ើបអង្កេត

ប្រសិនបើបទល្មើសណាមួយត្រូវបានប្រព្រឹត្តឬប្រសិនបើមានការសង្ស័យអំពីបទល្មើសណាមួយ នគរបាលត្រូវតែធ្វើការស៊ើបអង្កេត ។

ការស៊ើបអង្កេតដោយនគរបាលចំនួនពីរប្រភេទដែលត្រូវបានធ្វើឡើងអាស្រ័យលើប្រភេទនៃបទល្មើស :

1. ការស៊ើបអង្កេតបទល្មើសជាក់ស្តែងត្រូវបានធ្វើឡើងប្រសិនបើជនសង្ស័យៈ

- ត្រូវបានចាប់ខ្លួនក្នុងអំឡុងពេលប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋ ឬភ្លាមៗក្រោយពីបទល្មើសត្រូវបានប្រព្រឹត្ត ។

● ត្រូវបានចាប់ខ្លួនជាមួយនឹងវត្ថុស្លាកស្នាម ឬភស្តុតាងផ្សេងទៀតដែលបង្ហាញថា គាត់បានប្រព្រឹត្តបទល្មើស ។

ឧទាហរណ៍:

“ពូអ៊ុំប្រុស” ត្រូវបានចាប់ខ្លួននៅក្នុងពេលធ្វើសកម្មភាពរំលោភសេពសន្ថវៈលើក្មេងស្រីម្នាក់ ។

សម្រាប់ករណីជាក់ស្តែង នគរបាលត្រូវតែជូនដំណឹងភ្លាមៗទៅព្រះរាជអាជ្ញា ។

2. ការស៊ើបអង្កេតបឋមត្រូវបានធ្វើឡើង ប្រសិនបើនគរបាលដឹងអំពីសកម្មភាពដែលអាចជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ (សូមមើលខាងក្រោម) ។ នគរបាលមានឆន្ទានុសិទ្ធិថាតើត្រូវធ្វើការស៊ើបអង្កេតបឋមឬយ៉ាងណា ។

## សំណុំរឿងព្រហ្មទណ្ឌ និងសំណុំរឿងរដ្ឋប្បវេណី

មាន “សំណុំរឿង” ពីរប្រភេទ ដែលអាចត្រូវបាននាំយកទៅតុលាការ:

● សំណុំរឿងព្រហ្មទណ្ឌត្រូវបាននាំយកដោយព្រះរាជអាជ្ញា (តាងនាមឱ្យផលប្រយោជន៍សាធារណៈ)ដើម្បីស៊ើបអង្កេតថាតើបទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្តដែរឬទេ ប្រសិនបើជនរងគ្រោះបានដាក់បណ្តឹង ។

● សំណុំរឿងរដ្ឋប្បវេណីត្រូវបាននាំយកដោយបុគ្គលឯកជន(ជនរងគ្រោះ)ដើម្បីទទួលបានសំណងចំពោះរបួស ឬការខូចខាតដែលបុគ្គលនោះបានទទួលរង ដោយសារអ្វីមួយដែលធ្វើឡើងដោយបុគ្គលម្នាក់ផ្សេងទៀត ។

ទោះបីជាសំណុំរឿងមានភាពផ្សេងគ្នាក៏ដោយ ប្រសិនបើវាទាក់ទងនឹងបញ្ហាតែមួយ សំណុំរឿងនោះនឹងត្រូវបានជំនុំជំរះនៅពេលតែមួយនៅក្នុងតុលាការ ។



ឧទាហរណ៍ ប្រសិនបើកុមារត្រូវបានរំលោភសេពសន្ថវៈ

- នេះជាសំណុំរឿងព្រហ្មទណ្ឌដែលដំណើរការដោយព្រះរាជអាជ្ញាដើម្បីពិនិត្យមើលថាតើជនជាប់ចោទមានពិរុទ្ធពីបទរំលោភសេពសន្ថវៈនិងត្រូវដាក់ទោសដែរឬទេ ។
- ជនរងគ្រោះក៏អាចដាក់សំណុំរឿងរដ្ឋប្បវេណីប្រឆាំងនឹងជនជាប់ចោទផងដែរ ដើម្បីទាមទារប្រាក់សំណងជំងឺចិត្តដល់ជនរងគ្រោះសម្រាប់របួសស្នាមរបស់នាង ។
- សំណុំរឿងទាំងពីរត្រូវបានជំនុំជម្រះនៅក្នុងសាលាដំបូងនៅពេលតែមួយ ។

ក្រោយពីសេចក្ដីសម្រេចត្រូវបានផ្ដល់ដោយសាលាដំបូង:

- មានតែព្រះរាជអាជ្ញា (ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍) ឬជនជាប់ចោទប៉ុណ្ណោះ (ប៉ុន្តែមិនមែនជនរងគ្រោះ) អាចប្ដឹងឧទ្ធរណ៍លើសំណុំរឿងព្រហ្មទណ្ឌទៅកាន់សាលាឧទ្ធរណ៍ (និងបន្ទាប់មកទៅកាន់តុលាការកំពូល) ។

- មានតែជនជាប់ចោទ (ដែលហៅថា អ្នកទទួលខុសត្រូវរដ្ឋប្បវេណី)ឬជនរងគ្រោះប៉ុណ្ណោះអាចប្ដឹងឧទ្ធរណ៍សំណុំរឿងរដ្ឋប្បវេណីទៅកាន់សាលាឧទ្ធរណ៍(និងបន្ទាប់មកទៅកាន់តុលាការកំពូល) ។

**ប្រសិនបើមានសំណុំរឿងរដ្ឋប្បវេណី ជនរងគ្រោះអាចមានមេធាវីដើម្បីតំណាងឱ្យពួកគេនៅក្នុងតុលាការ**

ជនរងគ្រោះមិនត្រូវបានប្រគល់ឱ្យនូវមេធាវីនៅក្នុងសំណុំរឿងព្រហ្មទណ្ឌទេ ។

ប៉ុន្តែប្រសិនបើមានសំណុំរឿងរដ្ឋប្បវេណីត្រូវបានដាក់ជនរងគ្រោះមានសិទ្ធិទទួលបានការតំណាងដោយមេធាវីមួយរូប ។

នេះជាការសំខាន់ណាស់ ពីព្រោះមេធាវីរដ្ឋប្បវេណីអាចជួយជនរងគ្រោះនៅក្នុងដំណើរការតុលាការទាំងមូល រួមទាំងសំណុំរឿងព្រហ្មទណ្ឌផងដែរ ។

**ការដកសំណុំរឿងរដ្ឋប្បវេណីមិនបញ្ចប់សំណុំរឿងព្រហ្មទណ្ឌឡើយ**

សំណុំរឿងព្រហ្មទណ្ឌអាចត្រូវបានដាក់ ទោះបីជាគ្មានការដាក់សំណុំរឿងរដ្ឋប្បវេណីក៏ដោយ ។ នេះមានន័យថា ប្រសិនបើមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយជនរងគ្រោះសម្រេចចិត្តមិនដាក់ឬដកសំណុំរឿងរដ្ឋប្បវេណីសំណុំរឿងព្រហ្មទណ្ឌអាចនៅតែបន្តដំណើរការ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៥) ។ ប៉ុន្តែនៅក្នុងការអនុវត្តជាញឹកញាប់នគរបាលទំនងជានឹងមិនបន្តជាមួយនឹងសំណុំរឿងព្រហ្មទណ្ឌទេ ប្រសិនបើជនរងគ្រោះមិនដាក់បណ្ដឹង ឬដកសំណុំរឿង ។

**ប្រសិនបើជនជាប់ចោទយល់ព្រមទូទាត់ប្រាក់ដល់ជនរងគ្រោះ ការណ៍នេះមិនបញ្ចប់សំណុំរឿងព្រហ្មទណ្ឌទេ។**

កិច្ចព្រមព្រៀងក្រៅប្រព័ន្ធតុលាការសម្រាប់ជនជាប់ចោទក្នុងការសងប្រាក់ដល់ជនរងគ្រោះ (ឬគ្រួសាររបស់គាត់/នាង) មិនមានន័យថា សំណុំរឿងព្រហ្មទណ្ឌនឹងត្រូវលើកចោលនោះទេ ។

វាជារឿង ផ្ទុយនឹងច្បាប់ ប្រសិនបើនគរបាលលុបចោលសំណុំរឿងព្រហ្មទណ្ឌដោយមិនចាត់ការ ទោះបីជាជនរងគ្រោះដកបណ្ដឹងឬប្រសិនបើមានការចរចារវាងជនរងគ្រោះ និងជនជាប់ចោទ ក៏ដោយ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៥) ។

## នីតិវិធីនៃការដាក់សំណុំរឿងព្រហ្មទណ្ឌ និងរដ្ឋប្បវេណីទៅធ្វើការជំនុំជម្រះ

មានជំហានពាក់ព័ន្ធមួយចំនួនចាប់ពីពេលដែលឧប្បត្តិហេតុកើតឡើងចំពោះកុមាររងគ្រោះ រហូតដល់ពេលដែលសំណុំរឿងត្រូវបានយកទៅធ្វើការជំនុំជម្រះ ។ មានដំណាក់កាលសំខាន់ៗចំនួន ៥ :




អ្នកនឹងឃើញក្រាហ្វិកសាមញ្ញមួយដែលសង្ខេបអំពីរបៀបដែលដំណាក់កាលនីមួយៗដំណើរការនៅផ្នែកខាងក្រោយនៃសៀវភៅណែនាំនេះ ។

ខាងក្រោមគឺជាសេចក្ដីសង្ខេបបទបញ្ញត្តិសំខាន់ៗបំផុតតែប៉ុណ្ណោះ ហើយអ្នកគួរពិនិត្យមើលបទបញ្ញត្តិជាក់ស្ដែងនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

### ការដាក់បណ្ដឹងព្រហ្មទណ្ឌ



បណ្ដឹងទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌអាចត្រូវបានធ្វើឡើងដោយជនរងគ្រោះណាម្នាក់ ( ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥ និង ៦)  ទៅ :

- មន្ត្រីនគរបាលយុត្តិធម៌ (ដែលនឹងបញ្ជូនបណ្ដឹងនោះទៅព្រះរាជអាជ្ញា) ឬ
- ព្រះរាជអាជ្ញាដែលមានយុត្តាធិការត្រឹមត្រូវ  (ព្រះរាជអាជ្ញានៅទីតាំងដែលបទល្មើសត្រូវបានប្រព្រឹត្ត នៅកន្លែងស្នាក់នៅរបស់បុគ្គលដែលត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស   ឬនៅដែនដីដែលបុគ្គលនោះត្រូវបានសង្ស័យថាបានប្រព្រឹត្តបទល្មើស) ឬ
- ចៅក្រមស៊ើបសួរដោយផ្ទាល់ (តាមរយៈការចាប់ផ្ដើមការទាមទារសំណងរដ្ឋប្បវេណី) ។

ព្រះរាជអាជ្ញា គឺជាបុគ្គលដែលនឹងដាក់បណ្ដឹងព្រហ្មទណ្ឌ ដើម្បីផលប្រយោជន៍ទូទៅរបស់សង្គម (ក្រមនីតិវិធី ព្រហ្មទណ្ឌ មាត្រា ៦) ។

ប្រសិនបើព្រះរាជអាជ្ញា មិនឆ្លើយតបទៅនឹងបណ្ដឹងរបស់ជនរងគ្រោះ ឬតម្កល់សំណុំរឿងទុកឥតចាត់ការ ជនរងគ្រោះអាចដាក់សំណើដោយផ្ទាល់ទៅអគ្គព្រះរាជអាជ្ញា (ដែលនៅអមសាលាឧទ្ធរណ៍) ។ អគ្គព្រះរាជអាជ្ញាអាចលុបចោលបណ្ដឹងឧទ្ធរណ៍ ឬអាចយល់ព្រមជាមួយជនរងគ្រោះ និងបង្គាប់ឱ្យព្រះរាជអាជ្ញាចាប់ផ្ដើមចំណាត់ការព្រហ្មទណ្ឌ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១) ។

## ការស៊ើបអង្កេតបឋម



**ការសាកសួរតាមគោលការណ៍ ឬការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា**

នៅពេលមន្ត្រីនគរបាលយុត្តិធម៌បានទទួលបណ្ដឹងភ្លាម មន្ត្រីនរគបាលយុត្តិធម៌ចាំបាច់ត្រូវ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៧៤ ):

- ចាប់ផ្ដើមភ្លាមៗនូវការស៊ើបអង្កេតបឋម

- ប្រសិនបើបទល្មើសគឺជាបទល្មើសជាក់ស្ដែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ចប់ការស៊ើបអង្កេតក្នុងរយៈពេល ៧ ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការកើតឡើងនូវបទល្មើស បើមិនដូច្នោះទេ មន្ត្រីនរគបាលយុត្តិធម៌ ត្រូវតែបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១០៦) ។

- បញ្ជូនកំណត់ហេតុនៃបណ្ដឹងទៅព្រះរាជអាជ្ញាដើម្បីឱ្យពួកគេសម្រេចថាតើពួកគេនឹងធ្វើការស៊ើបអង្កេតបឋម ឬអត់ (ឬបញ្ជូនវាត្រឡប់ទៅមន្ត្រីនរគបាលយុត្តិធម៌វិញ ដើម្បីធ្វើការស៊ើបអង្កេត) ។

ទោះជាព្រះរាជអាជ្ញាក្ដី ឬ មន្ត្រីនរគបាលយុត្តិធម៌ក្ដី ចាប់ផ្ដើមការស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌ នឹងចាត់វិធានការ ដូចជា ការបង្គាប់ឱ្យបង្ហាញខ្លួនរបស់បុគ្គលនានា (រួមទាំងកុមាររងគ្រោះ) សម្រាប់ការស្ដាប់ចម្លើយដើម្បីផ្ដល់ព័ត៌មានអំពីរឿងក្ដី ការប្រមូលភស្តុតាង និងការកំណត់អត្តសញ្ញាណ និងការឃាត់ខ្លួន ជនសង្ស័យ ។

ក្នុងអំឡុងការស៊ើបអង្កេតបឋមនេះ មន្ត្រីនគរបាលយុត្តិធម៌ អាចបង្គាប់ឱ្យធ្វើការសួរចម្លើយជនសង្ស័យនិងឃាត់ខ្លួនជនសង្ស័យរហូតដល់រយៈពេល ៤៨ ម៉ោង(អាចត្រូវបានពន្យារពេល ២៤ ម៉ោងបន្ថែមទៀតដោយព្រះរាជអាជ្ញាសម្រាប់ជនសង្ស័យដែលមិនមែនជាអនីតិជន) (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៩៦) ។

ក្រោយពីការបញ្ចប់ការសាកសួរបឋមតាមគោលការណ៍ មន្ត្រីនគរបាលយុត្តិធម៌ប្រគល់រាល់កំណត់ហេតុជា លាយលក្ខណ៍អក្សរទាំងអស់ដល់ព្រះរាជអាជ្ញា ។

**ព្រះរាជអាជ្ញាសម្រេចចាប់ផ្ដើមបណ្ដឹងព្រហ្មទណ្ឌ ឬមិនចាប់ផ្ដើម**

ក្នុងរយៈពេល ២ ខែ ចាប់ពីទទួលបានបណ្ដឹង ព្រះរាជអាជ្ញាអាចសម្រេច :

- តម្កល់សំណុំរឿងទុកឥតចាត់ការ ឬ
- អនុវត្តនីតិវិធីចោទប្រកាន់ប្រឆាំងនឹងជនល្មើស ។

ប្រសិនបើព្រះរាជអាជ្ញាបានសម្រេចតម្កល់បណ្ដឹងទុកឥតចាត់ការ ប៉ុន្តែ ប្រសិនបើជនរងគ្រោះចង់ប្ដឹង គាត់ ឬនាងអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញា (អមសាលាឧទ្ធរណ៍)នៅភ្នំពេញ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៤១) ។

## ការស៊ើបសួរ ដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬការបង្ហាញខ្លួនភ្លាម

ប្រសិនបើសំណុំរឿងកំពុងដំណើរការ ព្រះរាជអាជ្ញានឹងអនុវត្តដំណើរការដោយអាស្រ័យលើថាតើ សំណុំរឿងគឺជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។

- សម្រាប់បទឧក្រិដ្ឋមួយចំនួនព្រះរាជអាជ្ញាត្រូវតែចាប់ផ្តើមការស៊ើបសួរ(ដែលសំណុំរឿងត្រូវបានស៊ើបអង្កេតបន្ថែមដោយចៅក្រមស៊ើបសួរ)។ នេះគឺជាជម្រើសសម្រាប់បទមជ្ឈិម (មាត្រា ១២២)។
- សម្រាប់បទមជ្ឈិម ព្រះរាជអាជ្ញាអាចៈ

- បើកការស៊ើបសួរ ឬ
- ចេញដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់(ដីកាបង្គាប់ឱ្យជនជាប់ចោទបង្ហាញខ្លួនភ្លាមនៅសាលាដំបូងនៅពេលវេលាជាក់លាក់ណាមួយ) ឬ
- ចេញដីកាកោះ(ស្របតាមដីកាបង្គាប់ឱ្យជនជាប់ចោទបង្ហាញខ្លួនជាបន្ទាន់នៅសាលាដំបូង)។

- សម្រាប់បទលហុ ព្រះរាជអាជ្ញាចេញដីការកោះ(ដីកាបង្គាប់ឱ្យជនជាប់ចោទបង្ហាញខ្លួននៅសាលាដំបូងនៅពេលវេលាជាក់លាក់ណាមួយ) ។



ដើម្បីធ្វើការស៊ើបសួរព្រះរាជអាជ្ញាធ្វើ "ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ" ទៅចៅក្រមស៊ើបសួរពាក់ព័ន្ធ ដែលជាចៅក្រមស៊ើបសួរ នៅទីកន្លែងនៃ :

- បទល្មើសព្រហ្មទណ្ឌ
- ទីលំនៅរបស់ជនល្មើសសង្ស័យ ឬ
- ទីកន្លែងដែលជនល្មើសសង្ស័យ ត្រូវបានចាប់ខ្លួន (មាត្រា ៣៩) ។

ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យនាំខ្លួនជនសង្ស័យណាម្នាក់(ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៨៦) និងអាច "ធ្វើការចោទប្រកាន់" បុគ្គលណាម្នាក់ពីបទល្មើស ។ បន្ទាប់មក ជនសង្ស័យក្លាយជា "ជនត្រូវចោទ" ។

**ការដាក់បណ្តឹងរដ្ឋប្បវេណីទៅចៅក្រមស៊ើបសួរ**

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមអាចដាក់បណ្តឹងរដ្ឋប្បវេណីទៅចៅក្រមស៊ើបសួរ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥, ១៣៧ និង ១៣៨) ។ ដើមបណ្តឹងរដ្ឋប្បវេណី មានសិទ្ធិទទួលបានជំនួយពីមេធាវី (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៥០) ។

**តើអ្នកណាអាចដាក់បណ្តឹងរដ្ឋប្បវេណីសម្រាប់ជនរងគ្រោះជាអនីតិជន?**

ប្រសិនបើជនរងគ្រោះគឺជាអនីតិជន តំណាងស្របច្បាប់របស់គាត់ ឬនាង ឬមនុស្សពេញវ័យណាម្នាក់ក្រោមអាណាព្យាបាល ភាពស្របច្បាប់អាចដាក់បណ្តឹងទាមទារជំនួសឱ្យជនរងគ្រោះបាន (ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ១៥) ។

ជាងនេះទៀត ប្រសិនបើជនរងគ្រោះ (ឬមេធាវីរបស់គាត់ ឬនាង)យល់ព្រម សមាគមជាក់លាក់មួយចំនួនអាចដាក់បណ្តឹងទាមទាររដ្ឋប្បវេណីជំនួសឱ្យជនរងគ្រោះសម្រាប់បទល្មើសដែលត្រូវបានបញ្ជាក់មួយចំនួន:

- សម្រាប់បទល្មើសគំរាមកំហែងដោយចេតនាដល់អាយុជីវិត ការបៀតបៀនដល់បូរណភាពនៃបុគ្គល ការបៀតបៀនខាងផ្លូវភេទ បណ្តឹងតវ៉ាអាចត្រូវបានធ្វើឡើងដោយសមាគមណាមួយដែលបានធ្វើការប្រកាសក្នុងរយៈពេល ៣ ឆ្នាំមុនកាលបរិច្ឆេទនៃការកើតឡើងនូវបទល្មើសដែលកម្មវត្ថុនៃលក្ខន្តិកៈគ្រប់គ្រងរបស់ខ្លួន គឺការតស៊ូប្រឆាំងនឹងអំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រឆាំងនឹងកុមារ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៧) ។
- សម្រាប់បទល្មើសទាក់ទងនឹងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សមាគមណាមួយដែលបានធ្វើការប្រកាសក្នុងរយៈពេល ៣ ឆ្នាំមុនកាលបរិច្ឆេទនៃបទល្មើសដែលកម្មវត្ថុនៃលក្ខន្តិកៈគ្រប់គ្រងរបស់ខ្លួន គឺការតស៊ូប្រឆាំងនឹងការចាប់ពង្រត់ ការជួញដូរមនុស្ស ឬការធ្វើអាជីវកម្មផ្លូវភេទ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៨) ។

ចៅក្រមស៊ើបសួរបញ្ជូនបណ្ដឹងរដ្ឋប្បវេណីទៅព្រះរាជអាជ្ញាដែលគាត់ជាអ្នកតម្កល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាមួយចៅក្រមស៊ើបសួរសម្រាប់សំណុំរឿងរដ្ឋប្បវេណី។

ក្នុងករណីដែលចៅក្រមស៊ើបសួរសម្រេចមិនស៊ើបអង្កេតបណ្ដឹងរដ្ឋប្បវេណី ចៅក្រមនោះត្រូវតែចេញដីកាមួយភ្លាមដោយមានការបញ្ជាក់ពីមូលហេតុនិងជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណីជាបន្ទាន់ ដោយគ្មានការពន្យាពេល (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៣៩) ។ ដើមបណ្ដឹងរដ្ឋប្បវេណីអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍ក្នុងរយៈពេល ៥ ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែលដីកាត្រូវបានជូនដំណឹង។

សំណុំរឿងរដ្ឋប្បវេណីត្រូវបានជំនុំជម្រះនៅពេលតែមួយជាមួយគ្នានឹងសំណុំរឿងព្រហ្មទណ្ឌ។ ជនរងគ្រោះក្លាយជា "ដើមចោទ" នៃបណ្ដឹងរដ្ឋប្បវេណី។

**ការអនុវត្តការស៊ើបសួរ**

ក្នុងអំឡុងពេលនៃការស៊ើបសួរៈ

- ព្រះរាជអាជ្ញាអាចស្នើឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយដែលអាចមានប្រយោជន៍ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៣២)។
- ដើមបណ្ដឹងរដ្ឋប្បវេណីក៏អាចស្នើសុំចៅក្រមស៊ើបសួរឱ្យស្ដាប់ចម្លើយគាត់ ឬនាង ស្ដាប់ចម្លើយសាក្សីទាំងឡាយ សួរចម្លើយជនត្រូវចោទផងដែរ។ ចៅក្រមស៊ើបសួរត្រូវតែសម្រេចថាតើត្រូវធ្វើដូច្នោះ ឬអត់ក្នុងរយៈពេល ១ ខែ បើមិនដូច្នោះទេ ព្រះរាជអាជ្ញាអាចធ្វើការសម្រេចបាន (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៣៤)។

ប្រសិនបើចៅក្រមស៊ើបសួរចេញដីកាបដិសេធមិនអនុវត្តកិច្ចស៊ើបសួរដែលស្នើសុំទេនោះ អ្នកណាក៏ដោយដែលបានធ្វើសំណើ (ដើមបណ្ដឹងរដ្ឋប្បវេណីឬព្រះរាជអាជ្ញា) អាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងរយៈពេល ៥ ថ្ងៃ ចាប់ពីកាលបរិច្ឆេទដែលដីកាត្រូវបានជូនដំណឹង។

**ការស្ដាប់ចម្លើយជនរងគ្រោះជាដើមបណ្ដឹងរដ្ឋប្បវេណី**

ប្រសិនបើចៅក្រមស៊ើបសួរ សម្រេចធ្វើការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់ក្នុងអំឡុងពេលនៃការស៊ើបសួរ ចៅក្រមនោះចាំបាច់ត្រូវតែកោះហៅមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនោះ យ៉ាងហោចណាស់ ៥ ថ្ងៃ មុនការស្ដាប់ចម្លើយ។

ដើមបណ្ដឹងរដ្ឋប្បវេណីអាចត្រូវបានស្ដាប់ចម្លើយ តែក្នុងករណីដែលមេធាវីរបស់ខ្លួនមានវត្តមានប៉ុណ្ណោះ(ទោះបីជាប្រសិនមេធាវីត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ប៉ុន្តែមិនបង្ហាញខ្លួន ចៅក្រមស៊ើបសួរអាចស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ដោយមិនចាំបាច់មានវត្តមានរបស់មេធាវីឡើយ)។

ក្នុងអំឡុងពេលស្ដាប់ចម្លើយព្រះរាជអាជ្ញា និងមេធាវីទាំងសងខាងអាចសួរសំណួរដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ (ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ១៥១)។

**ការឃុំខ្លួនបណ្ដោះអាសន្ន ឬការត្រួតពិនិត្យតាមផ្លូវតុលាការក្នុងអំឡុងពេលស៊ើបសួរ**

ក្នុងអំឡុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរអាចសម្រេចបង្គាប់ឱ្យឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន (រង់ចាំការបិទការស៊ើបសួរ) ឬបង្គាប់ឱ្យជនត្រូវចោទអាចនៅមានសេរីភាព ប៉ុន្តែត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ។

- ការឃុំខ្លួនបណ្ដោះអាសន្ន

- នៅក្នុងសំណុំរឿងនៃបទឧក្រិដ្ឋឬបទមជ្ឈិមដែលពាក់ព័ន្ធនឹងការផ្ដន្ទាទោសជាប់ពន្ធនាគារចំនួន ១ ឆ្នាំ ឬលើសពីនេះរាជអាជ្ញាអាចស្នើសុំទៅចៅក្រមស៊ើបសួរឱ្យចេញដីកាឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន (ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ២០៤)រហូតដល់រយៈពេលអតិបរមា (ដែលមានរៀបរាប់ខាងក្រោម) ។

- ប្រសិនបើចៅក្រមសម្រេចមិនចេញដីកាឃុំខ្លួនទេនោះចៅក្រមត្រូវតែចេញដីកា “មិនឃុំខ្លួន” ក្នុងរយៈពេល ៥ ថ្ងៃ។ ព្រះរាជអាជ្ញាត្រូវតែទទួលបានការជូនដំណឹងភ្លាមៗ ។

- ប្រសិនបើចៅក្រមស៊ើបសួរខកខានមិនបានធ្វើការសម្រេចក្នុងរយៈពេល ៥ ថ្ងៃទេនោះ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរដោយផ្ទាល់ដែលគាត់នឹងសម្រេចជំនួសចៅក្រមស៊ើបសួរ ។(ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៧)

- ការត្រួតពិនិត្យតាមផ្លូវតុលាការ

- ចៅក្រមស៊ើបសួរតាមគំនិតផ្ដួចផ្ដើមផ្ទាល់របស់ខ្លួនឬតាមសំណើរបស់ព្រះរាជអាជ្ញាអាចចេញ សេចក្ដីបង្គាប់មួយសម្រាប់ “ការត្រួតពិនិត្យតាមផ្លូវតុលាការ” ប្រឆាំងនឹងជនត្រូវចោទដើម្បីឱ្យបុគ្គលនោះនៅមានសេរីភាព ប៉ុន្តែស្ថិតក្រោមលក្ខខណ្ឌជាក់លាក់មួយចំនួន។

- ប្រសិនបើព្រះរាជអាជ្ញាបានធ្វើសំណើសុំការត្រួតពិនិត្យតាមផ្លូវតុលាការហើយចៅក្រមស៊ើបសួរមិនឯកភាពតាមសំណើ ចៅក្រមត្រូវតែចេញដីកាបដិសេធក្នុងរយៈពេល ៥ ថ្ងៃ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២២៦) ហើយព្រះរាជអាជ្ញាត្រូវទទួលបានការជូនដំណឹងអំពីដីកាបដិសេធនោះភ្លាមៗ ។

- ប្រសិនបើចៅក្រមស៊ើបសួរខកខានមិនបានធ្វើការសម្រេចក្នុងរយៈពេល ៥ ថ្ងៃទេនោះ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរដោយផ្ទាល់ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ ។

### ការបិទការស៊ើបសួរ ៖ ព្រះរាជអាជ្ញាតម្កល់ដីកាសន្និដ្ឋានស្ថាពរ




នៅពេលចៅក្រមស៊ើបសួរពិចារណាថាការស៊ើបសួរបានបញ្ចប់រួចរាល់ ចៅក្រមជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវី ។

ពីរថ្ងៃបន្ទាប់មក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ ។ ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យធ្វើការស៊ើបសួរបន្ថែម ប្រសិនបើយល់ឃើញថាចាំបាច់ ។

បន្ទាប់មក ព្រះរាជអាជ្ញាត្រូវតែបង្វិលសំណុំរឿងត្រឡប់ទៅចៅក្រមស៊ើបសួរវិញ រួមជាមួយនឹង “ដីកាសន្និដ្ឋានស្ថាពរ” របស់ព្រះរាជអាជ្ញា ក្នុងរយៈពេល ៣០ ថ្ងៃ ក្រោយពីទទួលបានសំណុំរឿង (ទោះជាយ៉ាងក៏ដោយ ប្រសិនបើជនសង្ស័យស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្ន ប្រការនេះត្រូវធ្វើឡើងក្នុងរយៈពេល ១៥ ថ្ងៃ ក្រោយពីការទទួលបានសំណុំរឿង) ។

នៅក្នុងដីកាសន្និដ្ឋានស្ថាពរ ព្រះរាជអាជ្ញាអាចស្នើសុំចៅក្រមស៊ើបសួរឱ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ប្រឆាំងនឹងជនសង្ស័យ ឬចេញដីកាលើកលែងការចោទប្រកាន់ ។ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៤៦) ។

**ចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ**

ចៅក្រមស៊ើបសួរបញ្ចប់ការស៊ើបសួរតាមរយៈដីកាដំណោះស្រាយនៃ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៤៧)៖

- ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ជនត្រូវចោទក្លាយជា “ជនជាប់ចោទ” នៅក្នុងការជំនុំជម្រះព្រហ្មទណ្ឌ) ឬ
- ដីកាលើកលែងការចោទប្រកាន់ ។

ដីកាដំណោះស្រាយមានអានុភាព (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៤៩)៖

1. បញ្ចប់ដីកាឃុំខ្លួនបណ្តោះអាសន្ន (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៤៩)

- ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកមួយដែលចេញរួមគ្នាជាមួយនឹងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្នរហូតដល់ពេលដែលគាត់ឬនាងត្រូវបានកោះហៅឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ ។ ប៉ុន្តែប្រសិនបើជនត្រូវចោទ មិនត្រូវបានកោះហៅឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះក្នុងរយៈពេល ៤ ខែទេនោះ ជនត្រូវចោទនឹងត្រូវបានដោះលែងឱ្យនៅក្រៅឃុំជាបណ្តោះអាសន្នដោយឯកឯង ។

2. បញ្ចប់ដីកាត្រួតពិនិត្យតាមផ្លូវតុលាការ

- ប៉ុន្តែតាមសេចក្តីសម្រេចដោយឡែកមួយដែលចេញរួមគ្នាជាមួយនឹងដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរ អាចបង្គាប់ឱ្យដាក់ជនត្រូវចោទឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ រហូតដល់ពេលដែលគាត់ត្រូវបានកោះហៅឱ្យបង្ហាញខ្លួននៅចំពោះមុខតុលាការជំនុំជម្រះ ។

ក្រោយពេលដែលចៅក្រមស៊ើបសួរ បានចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះចៅក្រមបញ្ជូនសំណុំរឿងទៅប្រធានតុលាការជំនុំជម្រះ ដើម្បីកំណត់កាលបរិច្ឆេទធ្វើការជំនុំជម្រះ ។



**ការផុតកំណត់រយៈពេលនៃការស៊ើបសួរ**

ការស៊ើបសួរត្រូវធ្វើឡើងភ្លាមៗ ដើម្បីឱ្យមានភាពយុត្តិធម៌ដល់ភាគីទាំងអស់ដែលពាក់ព័ន្ធ។ ដូច្នេះ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២៨៦)៖

● ក្រោយរយៈពេល១ឆ្នាំបន្ទាប់ពីជនត្រូវចោទបានទទួលដំណឹងថាគាត់ឬនាងស្ថិតនៅក្រោមការស៊ើបសួរ ជនត្រូវចោទអាចស្នើសុំចៅក្រមស៊ើបសួរឱ្យបិទការស៊ើបសួរ។

-ចៅក្រមស៊ើបសួរត្រូវតែធ្វើការសម្រេច ក្នុងរយៈពេល ១ ខែ ក្រោយពីទទួលបានសំណើ។ ប្រសិនបើចៅក្រមស៊ើបសួរខកខានមិនបានធ្វើការសម្រេចក្នុងរយៈពេលនោះទេ ជនត្រូវចោទអាចស្នើសុំទៅ ប្រធានសភាស៊ើបសួរ (សភាដែលសម្រេចលើបណ្តឹងសាទុក្ខប្រឆាំងនឹងចៅក្រមស៊ើបសួរ) ដែលអាចបង្គាប់ឱ្យចៅក្រមស៊ើបសួរចេញសេចក្តីសម្រេច។

● ក្រោយរយៈពេល១ឆ្នាំបន្ទាប់ពីបុគ្គលម្នាក់ត្រូវបានកំណត់ជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីនោះ អាចស្នើសុំចៅក្រមស៊ើបសួរឱ្យបិទការស៊ើបសួរ។

-ចៅក្រមស៊ើបសួរត្រូវតែធ្វើការសម្រេចក្នុងរយៈពេល ១ ខែក្រោយពីទទួលបានសំណើ។ប្រសិនបើចៅក្រមស៊ើបសួរខកខានមិនបានធ្វើការសម្រេច ក្នុងរយៈពេលនោះទេ ដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំទៅប្រធានសភាស៊ើបសួរដែលអាចបង្គាប់ឱ្យចៅក្រមស៊ើបសួរចេញសេចក្តីសម្រេច។

## សវនាការសាលាដំបូង

**ដើមបណ្តឹងរដ្ឋប្បវេណីនៅតែអាចដាក់ពាក្យស្នើសុំ**

ទោះបីជាជនរងគ្រោះមិនបានដាក់ពាក្យស្នើសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿងនៅក្នុងអំឡុងពេលស៊ើបសួរក៏ដោយ គាត់ ឬនាងនៅតែអាចដាក់ពាក្យស្នើសុំចូលរួមនៅក្នុងនីតិវិធីក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការជំនុំជម្រះដោយធ្វើការដាក់ពាក្យស្នើសុំទៅក្រឡាបញ្ជីតុលាការ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣១១)។

សំណុំរឿងរដ្ឋប្បវេណីត្រូវបានជំនុំជម្រះ នៅពេលតែមួយជាមួយនឹងសំណុំរឿងព្រហ្មទណ្ឌ ៖



**ការចាប់ផ្តើមការជំនុំជម្រះព្រហ្មទណ្ឌ**

ប្រសិនបើសំណុំរឿងកំពុងចាប់ផ្តើមជាមួយនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះព្រះរាជអាជ្ញាចាំបាច់ត្រូវ តែកោះហៅបុគ្គលខាងក្រោមឱ្យចូលរួមសវនាការ:

- ជនជាប់ចោទ
- ដើមបណ្តឹងរដ្ឋប្បវេណី
- ជនរងគ្រោះដែលមិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរ
- សាក្សី
- អ្នកជំនាញ
- អ្នកបកប្រែផ្ទាល់មាត់ / អ្នកបកប្រែឯកសារ
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដែលត្រូវបានកំណត់អត្តសញ្ញាណដោយជនជាប់ចោទ ឬដោយដើមបណ្តឹងរដ្ឋប្បវេណី ។

សំណុំរឿងត្រូវបានជំនុំជម្រះដោយគណៈវិនិច្ឆ័យដែលមានចៅក្រមជំនុំជម្រះចំនួន ៣ រូប ។

**សាលក្រម**

ក្រោយពេលបញ្ចប់ការជំនុំជម្រះ តុលាការនឹងចេញសេចក្តីសម្រេចទាក់ទងនឹង:

- សំណុំរឿងព្រហ្មទណ្ឌ (មានពិរុទ្ធ ឬគ្មានពិរុទ្ធ និងទោសព្រហ្មទណ្ឌណាមួយប្រឆាំងនឹងជនជាប់ចោទ)
- សំណុំរឿងរដ្ឋប្បវេណី(ទំនួលខុសត្រូវ និងសំណងរដ្ឋប្បវេណីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីដែលគាត់ ឬនាងត្រូវតែផ្តល់ជូនជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី) ។



### បណ្តឹងឧទ្ធរណ៍

បណ្តឹងឧទ្ធរណ៍ណាមួយប្រឆាំងនឹងសេចក្តីសម្រេចរបស់សាលាដំបូងអាចត្រូវបានធ្វើឡើងទៅសាលាឧទ្ធរណ៍ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧២) ដោយ(ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៧៥):

● នៅក្នុងសំណុំរឿងព្រហ្មទណ្ឌ-ព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ (ឬពិរុទ្ធជន) ;

● នៅក្នុងសំណុំរឿងរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណី (ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី-ជាធម្មតា ជនជាប់ចោទ) ទាក់ទងនឹងបញ្ហារដ្ឋប្បវេណីនៃសំណុំរឿង ។

សំណុំរឿងព្រហ្មទណ្ឌ →
- អគ្គព្រះរាជអាជ្ញា
- ពិរុទ្ធជន
- សំណុំរឿងរដ្ឋប្បវេណី

ព្រះរាជអាជ្ញា →
- ដើមបណ្តឹងរដ្ឋប្បវេណី (ជនរងគ្រោះ)
- អ្នកទទួលខុសត្រូវរដ្ឋប្បវេណី (ជាធម្មតា ជនជាប់ចោទ)

**ពេលវេលាកំណត់សម្រាប់ការប្តឹងឧទ្ធរណ៍**

សម្រាប់បណ្តឹងឧទ្ធរណ៍ព្រហ្មទណ្ឌ(ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ៣៨១, ៣៨២) ដោយ:

● ព្រះរាជអាជ្ញា បណ្តឹងឧទ្ធរណ៍ត្រូវតែធ្វើក្នុងរយៈពេល ១ ខែ

● ដោយអគ្គព្រះរាជអាជ្ញា បណ្តឹងឧទ្ធរណ៍ត្រូវតែធ្វើក្នុងរយៈពេល ៣ ខែ

● ដោយពិរុទ្ធជន បណ្តឹងឧទ្ធរណ៍ត្រូវតែធ្វើក្នុងរយៈពេល ១ ខែចាប់ពីកាលបរិច្ឆេទដែលសាលក្រមត្រូវបានប្រកាស ។

សម្រាប់បណ្តឹងឧទ្ធរណ៍រដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណីត្រូវតែដាក់បណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ១ ខែ ក្រោយកាលបរិច្ឆេទដែលសាលក្រមត្រូវបានប្រកាស (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៨២) ។ ក្នុងករណីមានការឃុំខ្លួន បណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចនៃការឃុំខ្លួនអាចត្រូវបានធ្វើឡើងដោយ:

● ព្រះរាជអាជ្ញា (ក្នុងរយៈពេល ៤៨ ម៉ោង ក្រោយសេចក្តីសម្រេចរបស់តុលាការលើការឃុំខ្លួន) ។

● ពិរុទ្ធជន(ក្នុងរយៈពេល៥ថ្ងៃក្រោយសេចក្តីសម្រេចរបស់តុលាការលើការឃុំខ្លួន) ។

## ក្របខណ្ឌនៃសិទ្ធិសម្រាប់កុមាររងគ្រោះនិងកុមារជាសាក្សី

| | |
| --- | --- |
| សន្ធិសញ្ញាអន្តរជាតិ | ច្បាប់ជាតិ |

នៅក្នុងដំណើរការទាំងមូលដែលរៀបរាប់ខាងលើ មានក្របខណ្ឌច្បាប់ស្តីពីការការពារដែលចែងអំពីសិទ្ធិ និងដំណើរការដែលត្រូវបានអនុវត្តចំពោះកុមារពាក់ព័ន្ធដែលជាកុមាររងគ្រោះ និងកុមារជាសាក្សី ។

នេះរួមបញ្ចូលទាំងច្បាប់អន្តរជាតិក៏ដូចជាច្បាប់ជាតិ និង លិខិតុបករណ៍ជាតិដែលចងកាតព្វកិច្ចផ្សេងទៀត (រួមទាំងប្រកាស គោលការណ៍ណែនាំ និងបទប្បញ្ញត្តិផ្សេងទៀត) ។

**ប្រើប្រាស់សិទ្ធិទាំងនេះ**

ទោះបីជាសម្រាប់បុគ្គលគាំទ្រមិនមែនផ្នែកច្បាប់ក៏ដោយ មានវិធីជាច្រើនដែលអ្នកត្រូវធ្វើការជាមួយមេធាវីរបស់កុមារដើម្បីធានាថាការអនុវត្តបែបកុមារមេត្រីត្រូវបានប្រើប្រាស់នៅក្នុងតុលាការ ។

យល់ដឹងនូវច្បាប់ទាំងឡាយដែលអាចរកបានដើម្បីការពារកុមារ ដូច្នេះអ្នកអាចត្រៀមខ្លួនជាស្រេចក្នុងការ ស្នើសុំនគរបាល ឬតុលាការ និងមេធាវីឱ្យប្រើប្រាស់សិទ្ធិរបស់កុមារ ។ វាគឺជាផ្នែកមួយនៃការងាររបស់អ្នកដែលត្រូវប្រាកដថា ច្បាប់ទាំងនេះត្រូវបានអនុវត្ត ក្នុងអំឡុងប្រតិបត្តិការរបស់នគរបាល ការសម្ភាសន៍ជនរងគ្រោះ និងនៅក្នុងសាលសវនាការ ។

## អន្តរជាតិ

### សិទ្ធិរបស់កុមាររងគ្រោះ និងកុមារជាសាក្សី

ប្រទេសកម្ពុជាបានផ្ដល់សច្ចាប័នលើសន្ធិសញ្ញាអន្តរជាតិមួយចំនួនដែលពាក់ព័ន្ធនឹងសិទ្ធិរបស់កុមារដែលជាជនរងគ្រោះនិងជាសាក្សី ។ លិខិតុករណ៍សំខាន់ៗ គឺៈ

● **អនុសញ្ញាស្តីពីសិទ្ធិកុមារ**[1] -សន្ធិសញ្ញាអន្តរជាតិដែលទទួលស្គាល់សិទ្ធិរបស់កុមារ(ដែលត្រូវបានកំណត់និយមន័យថាជាបុគ្គលដែលមានអាយុរហូតដល់ ១៨ឆ្នាំ) ។ រដ្ឋជាភាគីត្រូវតែធានាថា កុមារទាំងអស់-ដោយមិនមានការរើសអើង-ទទួលអត្ថ-ប្រយោជន៍ពីសិទ្ធិអប្បបរមាមួយចំនួន និងវិធានការការពារពិសេសនានា ។ ជាពិសេសៈ

-កថាខណ្ឌខាងលើដែលគូសបញ្ជាក់អំពីកាតព្វកិច្ចទាំងឡាយទាក់ទងនឹងកុមាររងគ្រោះ ឬកុមារជាសាក្សី គឺថានៅក្នុងវិធានការទាំងអស់ដែលពាក់ព័ន្ធនឹងកុមារ "ឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារ"គឺជាការពិចារណាចម្បង (មាត្រា ៣) ។

-រដ្ឋជាភាគីត្រូវតែចាត់វិធានការសមស្របទាំងអស់ដើម្បីជំរុញការធ្វើឱ្យជាសះស្បើយឡើងវិញផ្នែករាងកាយ ផ្លូវចិត្ត និងការធ្វើសមាហរណកម្មផ្នែកសង្គមសម្រាប់កុមាររងគ្រោះ (មាត្រា ៣៩) ។

● **សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីគោលការណ៍ជាមូលដ្ឋាននៃយុត្តិធម៌សម្រាប់ជនរងគ្រោះនៃបទល្មើសព្រហ្មទណ្ឌ និងការរំលោភអំណាច**[2] -នេះតម្រូវឱ្យរដ្ឋទាំងឡាយអនុវត្តនីតិវិធីនានាដែលអនុញ្ញាតឱ្យមានការទទួលបានការប្រព្រឹត្តដោយយុត្តិធម៌ និងត្រឹមត្រូវ ។ នេះរួមបញ្ចូលទាំងប្រការដែលថាៈ

- ជងរងគ្រោះគួរត្រូវបានប្រព្រឹត្តចំពោះដោយការអាណិតអាសូរនិងការគោរពចំពោះសេចក្តីថ្លៃថ្នូររបស់ពួកគេ (មាត្រា ៤) ។

- ជនរងគ្រោះមានសិទ្ធិទទួលបានយន្តការនៃយុត្តិធម៌និងសំណងភ្លាមៗសម្រាប់ការខូចខាតដែលពួកគេបានទទួលរង (មាត្រា៥) ។ ជនរងគ្រោះគួរត្រូវបានជូនដំណឹងអំពីសិទ្ធិរបស់ពួកគេក្នុងការទាមទារសំណងតាមរយៈយន្តការតុលាការនិងរដ្ឋបាលសម្រាប់ការទាមទារសំណង ។

### សិទ្ធិមនុស្សនៅក្នុងការអនុវត្តការជំនុំជម្រះ

ប្រទេសកម្ពុជាក៏បានផ្ដល់សច្ចាប័នផងដែរលើសន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សផ្សេងទៀតដែលកំណត់កាតព្វកិច្ចក្នុងការការពារសិទ្ធិមនុស្សនៅក្នុងការជំនុំជម្រះនិងក្នុងការកាពារស្ត្រី និងកុមារជាពិសេស ។

● **កតិកាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ**[3] -មាត្រា ១៤ ចែងអំពីសិទ្ធិ ទាក់ទងនឹងការជំនុំជម្រះ ដោយយុត្តិធម៌ ។ ទាក់ទងនឹងជនរងគ្រោះនេះ រួមបញ្ចូលទាំងការហាមប្រាមសារព័ត៌មាន និងសាធារណជនពីការជំនុំជម្រះសម្រាប់ហេតុផលសីលធម៌ និងនៅពេលដែលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវ និងការមិនផ្សព្វ-ផ្សាយសាលក្រមពាក់ព័ន្ធនឹងកុមារ ។

1. ផ្ដល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ។ ក្រុមប្រឹក្សាធម្មនុញ្ញបានចេញសេចក្ដីសម្រេចលេខ០៩២/00៣/២00៧ ចុះថ្ងៃទី១០ខែកក្កដាឆ្នាំ២00៧ដែលកំណត់ថាច្បាប់អន្តរជាតិដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជា រួមទាំងអនុសញ្ញាស្តីពីសិទ្ធិកុមារនឹងត្រូវបញ្ចូលជាផ្នែកមួយនៃច្បាប់ជាតិដែលចៅក្រមត្រូវតែយោងដល់នៅក្នុងការជំនុំជម្រះរឿងក្តី ។

2. សេចក្តីសម្រេចនៃមហាសន្និបាតA/RES/40/34-ទោះបីជាសេចក្ដីប្រកាសនេះដែលអនុម័តដោយសេចក្ដីសម្រេចនៃមហាសន្និបាតអង្គការសហប្រជាជាតិមិនចងកាតព្វកិច្ចជាលក្ខណៈបច្ចេកទេសលើប្រទេសកម្ពុជាក៏ដោយ ក៏វានឹងមានអានុភាពបញ្ចុះបញ្ចូលផងដែរ ។

3. ត្រូវបានផ្ដល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ។

- **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច និងសង្គម**[4] -វិធានការពិសេសស្តីពីការការពារ និងជំនួយត្រូវបានធ្វើឡើង តាងនាមឱ្យកុមារ និងយុវជនទាំងអស់ ដោយគ្មានការរើសអើង (មាត្រា ១០) ។
- **អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំង នឹងស្ត្រី**[5] ដែលចែងអំពីវិធានការដើម្បីការពារស្ត្រី ។ រដ្ឋជាភាគីត្រូវតែចាត់វិធានការសមស្របទាំងអស់ដើម្បីធានានូវការអភិវឌ្ឍ និងការរីកចម្រើនពេញលេញរបស់ស្ត្រី (មាត្រា ៣) ។

## ជាតិ

ច្បាប់

- **រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា**

- រដ្ឋត្រូវបានតម្រូវឱ្យទទួលស្គាល់និងការពារសិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សកតិកាសញ្ញា និងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ (មាត្រា ៣១) ។
- រដ្ឋត្រូវបានតម្រូវឱ្យការពារសិទ្ធិកុមារដូចមានចែងនៅក្នុងអនុសញ្ញាស្តីពីសិទ្ធកុមារនិងថា រដ្ឋត្រូវតែការពារកុមារពី អំពើទាំងឡាយដែលបង្កការប៉ះពាល់ដល់ឱកាសអប់រំសុខភាព និងសុខុមាលភាពរបស់ពួកគេ (មាត្រា ៤៨) ។

- **ក្រមនីតិវិធីព្រហ្មទណ្ឌ**[6] ចែងអំពីវិធាននីតិវិធីព្រហ្មទណ្ឌនៅក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ។

- ក្រោយពីការបើកការស៊ើបអង្កេតរបស់តុលាការ ជនរងគ្រោះអាចនៅពេលណាមួយដាក់សំណើធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី (មាត្រា ១៣៧) ។ ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិទទួលបានជំនួយពីមេធាវីមួយរូប (មាត្រា ១៥០) ។
- ក្នុងអំឡុងពេលស៊ើបអង្កេតលើសំណុំរឿងក្តីដោយចៅក្រមស៊ើបសួរពេលនោះប្រសិនបើកុមារត្រូវបានស្តាប់ចម្លើយ នោះមេធាវីរបស់កុមារត្រូវតែមានវត្តមាននៅទីនោះ ហើយមេធាវីអាចធ្វើការសួរសំណួរទៅលើកុមារជាមួយចៅក្រមស៊ើបសួរបានប្រសិនបើមានការអនុញ្ញាតពីគាត់ ។ (មាត្រា ១៥០, ១៥១) ។

អ្នកអាចប្រើប្រាស់ចំណុចនេះដើម្បីទទូចឱ្យមានវត្តមានរបស់មេធាវីសំដៅការពារកុមារ ក្នុងអំឡុងដំណើរការស៊ើបអង្កេត ។

ប្រសិនបើអ្នកដឹងថាកុមារនឹងត្រូវបានស្តាប់ចម្លើយដោយចៅក្រមស៊ើបសួរ ត្រូវប្រាកដថាអ្នកបានប្រាប់មេធាវី (ឬស្វែងរកមេធាវីឱ្យបានឆាប់រហ័សបំផុតដើម្បីតំណាងឱ្យកុមារ) ដើម្បីឱ្យមេធាវីអាចមានវត្តមាននៅពេលសម្ភាសន៍ ។

4. ត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ។

5. ត្រូវបានផ្តល់សច្ចាប័នដោយប្រទេសកម្ពុជានៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ។

6. ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ (ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧) ។

បុគ្គលណាម្នាក់ដែលត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ អាចត្រូវបានឃុំខ្លួនសម្រាប់រយៈពេលវែងចាំ ការជំនុំជម្រះ យោងតាម "ការឃុំខ្លួនបណ្ដោះអាសន្ន" (មាត្រា ២០៦) នៅក្នុងកាលៈទេសៈជាក់លាក់មួយចំនួន រួមទាំងដើម្បីៈ

- បញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតឡើងម្ដងទៀត
- បង្ការការបៀតបៀនសាក្សី ឬជនរងគ្រោះឬបង្ការការឃុបឃិតណាមួយរវាងជនត្រូវចោទ និងជនសមគំនិត ។

ការឃុំខ្លួនបណ្ដោះអាសន្នអាចៈ នៅក្នុងករណីនៃបទឧក្រិដ្ឋរហូតដល់ ៦ ខែ (អាចត្រូវបានពន្យារម្ដងរយៈពេល ៦ ខែបន្ថែមទៀត) ។ ក្នុងករណីបទមជ្ឈិម រហូតដល់ ៤ ខែ (អាចត្រូវបានពន្យារម្ដងរយៈពេល ២ ខែបន្ថែមទៀត) ។ ប៉ុន្តែក្នុងករណីអនីតិជនអាយុក្រោម ១៤ ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្ដោះអាសន្នបានទេ (មាត្រា ២១២) ។

សម្រាប់អនីតិជនដែលមានអាយុពី ១៤ ឆ្នាំដល់ ១៨ ឆ្នាំដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ ខែឡើយ ប្រសិនបើអនីតិជនមានអាយុក្រោម ១៦ ឆ្នាំ និងមិនអាចលើសពី ៦ ខែឡើយ ប្រសិនបើអនីតិជនមានអាយុពី ១៦ ដល់ ១៨ ឆ្នាំ (មាត្រា ២១៣) ។

សម្រាប់អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ១៨ ឆ្នាំ ដែលពាក់ព័ន្ធនឹងបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ ខែឡើយ ប្រសិនបើអនីតិជនមានអាយុក្រោម ១៦ ឆ្នាំ និងមិនអាចលើសពី ៤ ខែឡើយ ប្រសិនបើអនីតិជនមានអាយុពី ១៦ ដល់ ១៨ ឆ្នាំ (មាត្រា ២១៤) ។

អ្នកអាចប្រើបញ្ញត្តិនេះដើម្បីស្នើសុំតុលាការធ្វើការឃុំខ្លួនបណ្ដោះអាសន្ន ដើម្បីការពារកុមារពីជនជាប់ចោទ មុនពេលជំនុំជម្រះ ប្រសិនបើមានហានិភ័យនៃបទល្មើស ឬការបៀតបៀនបន្ថែម ។

ជាជម្រើសផ្សេងមួយទៀតក្រៅពីការឃុំខ្លួនបណ្ដោះអាសន្ន តុលាការក៏អាចចេញសេចក្ដីសម្រេចថា ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពីបទល្មើសដែលជាប់ពន្ធនាគារ ត្រូវបានអនុញ្ញាតឱ្យនៅមានសេរីភាព រង់ចាំការជំនុំជម្រះ ប៉ុន្តែស្ថិតក្រោម "ការត្រួតពិនិត្យតាមផ្លូវតុលាការ" (មាត្រា ២២៣) ។ នេះមានន័យថា ជនជាប់ចោទនៅមានសេរីភាព ប៉ុន្តែស្ថិតក្រោមកាតព្វកិច្ចជាក់លាក់មួយចំនួន រួមទាំងមិនអាចទៅក្រៅបរិវេណដែនដីដែលកំណត់ដោយ ចៅក្រមស៊ើបសួរ មិនត្រូវបានអនុញ្ញាតឱ្យផ្លាស់ប្ដូរលំនៅដ្ឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ និងមិនត្រូវបានអនុញ្ញាតឱ្យទៅកាន់កន្លែងជាក់លាក់មួយចំនួនដែលកំណត់ដោយចៅក្រមស៊ើបសួរ ។ អនីតិជនមិនអាចត្រូវបានដាក់ឱ្យស្ថិតក្រោមកាត្រួតពិនិត្យតាមផ្លូវតុលាការឡើយ(មាត្រា២២៤) ។

អ្នកអាចប្រើបញ្ញត្តិនេះដើម្បីស្នើសុំតុលាការចេញដីកាត្រួតពិនិត្យតាមផ្លូវតុលាការ ដើម្បីការពារកុមារពីជនជាប់ចោទមុនពេលជំនុំជម្រះ ប្រសិនបើតុលាការមិនបានផ្ដល់ចេញដីកាឃុំខ្លួនបណ្ដោះអាសន្នចំពោះជនជាប់ចោទ ។

-ជនរងគ្រោះ ឬមេធាវីរបស់ជនរងគ្រោះអាចស្នើសុំសវនាការជាអសាធារណៈ (មាត្រា ៣១៦) ។

អ្នកអាចប្រើប្រាស់ប្រការនេះដើម្បីការពារភាពជាឯកជនរបស់កុមារនៅក្នុងសាលសវនាការ ។ អ្នកគួរតែធានាថាមេធាវីបានស្នើសុំចៅក្រមឱ្យបើកសវនាការជាអសាធារណៈ ។

- **ក្រមព្រហ្មទណ្ឌ**[7] ចែងអំពីបទល្មើស ទំនួលខុសត្រូវចំពោះបទល្មើស និងទោសទណ្ឌ រួមទាំងបទល្មើសព្រហ្មទណ្ឌទាក់ទងនឹងការសម្លុត និងការគំរាមកំហែងជនរងគ្រោះ និងសាក្សី និងការរាយការណ៍អំពីបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងកុមារ ។ វាគឺជាបទល្មើសព្រហ្មទណ្ឌៈ

- ចំពោះអ្នកណាម្នាក់ដែលសម្លុតឬគំរាមកំហែងជនរងគ្រោះមិនឱ្យដាក់បណ្តឹង (មាត្រា ៥២៧) ។

- ចំពោះចារីដែលសម្លុតសាក្សីមិនឱ្យផ្តល់សេចក្តីបញ្ជាក់ឬផ្តល់ភស្តុតាងមិនពិតប្រាកដ (មាត្រា ៥៤៦) ។

- ចំពោះអ្នកណាម្នាក់ដែលដឹងអំពីការប្រព្រឹត្តមិនត្រឹមត្រូវឬការរំលោភបំពានផ្លូវភេទប្រឆាំងនឹងអនីតិជនដែលមានអាយុតិចជាង ១៥ ឆ្នាំ ក្នុងការខកខានមិនបានជូនដំណឹងដល់អាជ្ញាធរតុលាការ ឬអាជ្ញាធរមានសត្ថកិច្ចផ្សេងទៀត (មាត្រា ៥៣០) ។

- ចំពោះអ្នកណាម្នាក់ដែលផ្តល់សំណូកសូកប៉ាន់ដល់សាក្សីដើម្បីកុំឱ្យផ្តល់សក្ខីកម្ម ឬផ្តល់ភស្តុតាងមិនពិត (មាត្រា ៥៤៨) ។

អ្នកអាចប្រើប្រាស់ចំណុចនេះដើម្បីការពារកុមារពីការគំរាមកំហែងឱ្យដកបណ្តឹង ។

ប្រសិនបើអ្នកគិតថាគ្រួសារជនសង្ស័យកំពុងគំរាមកំហែងកុមារឬគ្រួសាររបស់គាត់/នាងដើម្បីជំរុញឱ្យពួកគេដកបណ្តឹង ចូរប្រាប់នគរបាល ។ នេះគឺជាបទល្មើសព្រហ្មទណ្ឌ ។

សម្រាប់បទឧក្រិដ្ឋបំពានផ្លូវភេទ តុលាការអាចផ្តល់ទោសទណ្ឌបន្ថែមដែលមានប្រយោជន៍នៅក្នុងការការពារកុមាររងគ្រោះ រួមទាំង (មាត្រា ២៤៥) ៖

- ការដកហូតសិទ្ធិពលរដ្ឋមួយចំនួនរបស់ចារី ។

- ការហាមឃាត់ចារីពីការប្រកបវិជ្ជាជីវៈមួយចំនួន ការកាន់កាប់អាវុធ ឬការកាន់កាប់លំនៅដ្ឋាន ។

- សម្រាប់ជនបរទេស ការហាមឃាត់ការចូលមករស់នៅក្នុងប្រទេសកម្ពុជា ។

ចំពោះបទល្មើសព្រហ្មទណ្ឌ ដែលមានទោសជាប់ពន្ធនាគារចាប់ពី ៦ ខែដល់ ៥ ឆ្នាំ តុលាការអាចធ្វើការព្យួរទោសដោយមានលក្ខខណ្ឌ ។ កាតព្វកិច្ចមួយចំនួនអាចត្រូវបានកំណត់ក្នុងអំឡុង ការព្យួរទោសមានលក្ខខណ្ឌ រួមទាំង (មាត្រា ១២០) ។

- ការមិនមានវត្តមាននៅទីតាំងមួយចំនួន
- ការមិនពាក់ព័ន្ធនឹងទីតាំងមួយចំនួន

អ្នកអាចប្រើចំណុចនេះ ប្រសិនបើចារីត្រូវបានដោះលែងដោយការព្យួរទោស មានលក្ខខណ្ឌ ដើម្បីបង្ការគាត់ ឬនាងពីការបង្ហាញខ្លួននៅក្នុងបរិវេណរបស់កុមារ ឬពាក់ព័ន្ធជាមួយនឹងកុមារ ។

7. ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ (ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩) ។

● **ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ**[8] ចែងអំពីយន្តការផ្លូវច្បាប់នានា ដើម្បីទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ[9] ។

- អាជ្ញាធរដែលនៅជិតបំផុតមានតួនាទីធ្វើអន្តរាគមន៍ប្រសិនបើអំពើហិង្សាក្នុងគ្រួសារកើតឡើង ឬទំនងជាកើតឡើង។ (មាត្រា ៩)

អ្នកអាចប្រើចំណុចនេះដើម្បីទទួចឱ្យមានអន្តរាគមន៍សំដៅការពារកុមារដែលស្ថិតក្នុងហានិភ័យនៃអំពើហិង្សាក្នុងគ្រួសារ។

ក្រោយពីការស៊ើបអង្កេតបឋមផ្ទាល់ខ្លួនរបស់អ្នក ប្រសិនបើអ្នកសង្ស័យថាកុមារស្ថិតក្នុងហានិភ័យនៃអំពើហិង្សា ក្នុងគ្រួសារ ចូររាយការណ៍បញ្ហានេះទៅកាន់នគរបាល និងទទួចសុំអន្តរាគមន៍ ។ លើកឡើងអំពីកាតព្វកិច្ចរបស់ពួកគេក្នុងការធ្វើអន្តរាគមន៍ប្រសិនបើនគរបាលមិនចាត់វិធានការស៊ើបអង្កេតណាមួយទេនោះ។

- អាជ្ញាធរអាចចេញសេចក្តីសម្រេចរដ្ឋបាលដើម្បីការពារជនរងគ្រោះនិងហាមឃាត់ចារីពីការទៅកាន់ ឬចូលផ្ទះ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ (មាត្រា ១៤)។

អ្នកអាចប្រើចំណុចនេះដើម្បីការពារកុមារដែលស្ថិតក្នុងហានិភ័យនៃអំពើហិង្សាក្នុងគ្រួសារពីទំនាក់ទំនងជាមួយនឹងចារី។

ប្រសិនបើអតិថិជនរបស់អ្នកគឺជាកុមាររងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ហើយជនសង្ស័យមិនត្រូវបានឃុំខ្លួនមុនពេលជំនុំជម្រះទេនោះ វានឹងអាចជាការគំរាមកំហែងចំពោះកុមារឬគ្រួសាររបស់គាត់/នាង។ ចូរឱ្យមេធាវីស្នើសុំសេចក្តីសម្រេចផ្នែករដ្ឋបាលពីក្រុមប្រឹក្សាឃុំដើម្បីបង្ការជនសង្ស័យពីការទៅរកកុមារ ឬដើម្បីយកកុមារចេញ។

- បន្ថែមលើអន្តរាគមន៍របស់អាជ្ញាធរ ជនរងគ្រោះមានសិទ្ធិដាក់បណ្តឹងទៅកាន់តុលាការ ខេត្ត/ក្រុងដើម្បីចេញដីកាការពារ ជាវិធានការរដ្ឋប្បវេណី (មាត្រា ១៦)។ ដីកាការពារអាចបង្គាប់ឱ្យយកជនរងគ្រោះចេញពីចារី និងទប់ស្កាត់ចារីពីការធ្វើអ្វីៗនានាផងដែរ ដូចជា (មាត្រា ២៥)

1. ការទាក់ទងជនរងគ្រោះ
2. ការបំផ្លាញទ្រព្យសម្បត្តិរបស់ជនរងគ្រោះ
3. ការទៅកាន់ ឬការចូលក្នុងផ្ទះ ឬកន្លែងធ្វើការរបស់ជនរងគ្រោះ

- ដីកាការពារអាចមានប្រសិទ្ធភាពសម្រាប់រយៈពេល ២ ឬ ៦ ខែ :

1. បណ្តោះអាសន្ន (មានប្រសិទ្ធភាពសម្រាប់រយៈពេល ២ ខែ“រយៈពេលបន្ទាន់”)
2. រយៈពេលបន្ថែមចំនួន ៦ ខែ ក្នុងអំឡុងពេលដែលតុលាការកំពុងធ្វើការស៊ើបអង្កេតលើ ករណី (មុនពេលការជំនុំជម្រះត្រូវបានបញ្ចប់) ។

អ្នកអាចប្រើចំណុចនេះដើម្បីការពារកុមារពីការបន្តមានទំនាក់ទំនងជាមួយចារីដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ ដោយរឹតបណ្តឹងសកម្មភាពរបស់ចារី។

8. ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០០៥/០៣១ (ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥) ។

9. អំពើហិង្សាក្នុងគ្រួសាររួមបញ្ចូលទាំងអំពើហិង្សាប្រឆាំងនឹងប្តី ប្រពន្ធ កូនក្នុងបន្ទុក អ្នកក្នុងបន្ទុកផ្សេងទៀតនៅក្នុងគ្រួសារ។

ប្រសិនបើអតិថិជនរបស់អ្នកគឺជាកុមាររងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារ ហើយជនសង្ស័យមិនត្រូវបានឃុំខ្លួនមុនការជំនុំជម្រះ និងអាចជាការគំរាមកំហែងចំពោះកុមារ ឬគ្រួសាររបស់គាត់/នាង ។ ចូរឱ្យមេធាវីស្នើសុំដីកាការពារដើម្បីបង្ការជនសង្ស័យពីការទៅរកកុមារ ឬដើម្បីយកកុមារចេញ ។

- ប្រសិនបើអំពើហិង្សាក្នុងគ្រួសារគឺប្រឆាំងនឹងកុមារ តុលាការអាចចេញដីកាទៅបណ្តាស្ថាប័នដើម្បីស្វែងរកជំនួយនិងការគាំទ្រសម្រាប់ជនរងគ្រោះនិងការពារពួកគេក្នុងអំឡុងនីតិវិធីតុលាការ (មាត្រា២៨) ។

**ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ**[10] -មានបញ្ញត្តិនានាសំដៅទប់ស្កាត់ការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងការ ការពារជនរងគ្រោះ ។

- គ្រប់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ត្រូវបានហាមឃាត់មិនឱ្យបោះពុម្ពផ្សាយឬផ្សព្វផ្សាយព័ត៌មានណាមួយដែលអាចធ្វើឱ្យសាធារណៈជនបានដឹងអំពីអត្តសញ្ញាណរបស់ជនរងគ្រោះក្នុងបទល្មើសទាំងឡាយដែលពាក់ព័ន្ធ (មាត្រា ៤៩) ។

អ្នកអាចប្រើប្រាស់ចំណុចនេះដើម្បីទទូចសុំការមិនអោយផ្សព្វផ្សាយឈ្មោះរបស់កុមាររងគ្រោះនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ។

ប្រសិនបើអតិថិជនរបស់អ្នក គឺជាជនរងគ្រោះនៃករណីជួញដូរមនុស្ស ឬអំពើអាជីវកម្មផ្លូវភេទ ចូរស្នើឱ្យមេធាវីរំឭកប្រព័ន្ធផ្សព្វផ្សាយណាមួយដែលអាចដឹងអំពីករណីនោះថា ពួកគេមិនត្រូវរាយការណ៍អំពីករណីនោះតាមរបៀបមួយដែលនឹងកំណត់អត្តសញ្ញាណកុមារឡើយ ។ស្នើសុំចៅក្រម ប្រសិនបើសមស្របឱ្យធ្វើការប្រកាសបែបនោះ ។

- **ច្បាប់ស្តីពីរបបសារព័ត៌មាន**

- លើកលែងតែមានការអនុញ្ញាតពីតុលាការ សារព័ត៌មានត្រូវបានហាមឃាត់មិនឱ្យផ្សាយព័ត៌មាន រូបថត ឬគំនូរដែលអាចធ្វើឱ្យអ្នកអានអាចស្គាល់ឈ្មោះ ឬ អិនភាគរបស់កុមារដែលមានអាយុក្រោម ១៨ ឆ្នាំនៅក្នុងបណ្តឹងរដ្ឋប្បវេណីឬព្រហ្មទណ្ឌណាមួយឡើយ (មាត្រា ១៥) ។

អ្នកអាចប្រើចំណុចនេះដើម្បីទទូចសុំកុំឱ្យមានការផ្សាយឈ្មោះរបស់កុមាររងគ្រោះនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ ។

ប្រសិនបើអតិថិជនរបស់អ្នកគឺជាកុមាររងគ្រោះករណីព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីណាមួយ ចូរស្នើឱ្យមេធាវីរំឭក ប្រព័ន្ធផ្សព្វផ្សាយណាមួយដែលអាចដឹងអំពីករណីនោះថា ពួកគេមិនត្រូវរាយការណ៍អំពីករណីនោះតាមរបៀបមួយដែលនឹងកំណត់អត្តសញ្ញាណកុមារឡើយ ។ ស្នើសុំចៅក្រម ប្រសិនបើសមស្របឱ្យធ្វើការប្រកាសបែបនោះ ។

10. ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៥ (ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨) ។

## ប្រកាស គោលការណ៍ណែនាំ និងលិខិតុបករណ៍ច្បាប់ផ្សេងទៀត

● **ប្រកាសលេខ ៦២ កយប្រក/០៨ ស្តីពីការប្រើប្រាស់របាំងសវនាការ និងការផ្តល់សក្ខីកម្មភ្ជាប់តាមបណ្តាញទូរទស្សន៍ពីកុមាររងគ្រោះ/កុមារដែលងាយរងគ្រោះឬសាក្សីជាកុមារ (ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៨)-**

របាំងសវនាការ ឬការផ្តល់សក្ខីកម្មភ្ជាប់តាមបណ្តាញទូរទស្សន៍ គប្បីត្រូវបានប្រើជាវិធានការការពារ នៅក្នុងគ្រប់សំណុំរឿងទាំងអស់ ពាក់ព័ន្ធនឹងកុមាររងគ្រោះ/កុមារងាយរងគ្រោះ ឬសាក្សីជាកុមារ ប្រសិនបើការផ្តល់សក្ខីកម្មនៅចំពោះវត្តមានរបស់ជនជាប់ចោទ បង្កនូវភាពតានតឹងមិនសមស្របឬការប៉ះទង្គិចផ្លូវចិត្តចំពោះកុមាររងគ្រោះ/កុមារងាយរងគ្រោះ ឬសាក្សីជាកុមារ (លើកលែងតែកុមាររងគ្រោះ/កុមារងាយរងគ្រោះ ឬសាក្សីជាកុមារមិនចង់បានវិធានការបែបនោះ ហើយចៅក្រមក្រោយពីការពិគ្រោះយោបល់ជាមួយជនរងគ្រោះ ឬសាក្សី មេធាវីរបស់គាត់/នាង និង/ឬបុគ្គលិកសង្គមកិច្ចគិតថាវាមិនផ្តល់នូវឧត្តមប្រយោជន៍ល្អបំផុតដល់ជនរងគ្រោះ/សាក្សីឡើយ) ។

របាំងសវនាការ

● របាំងសនាការគឺជាវិធានការការពារដ៏សំខាន់សម្រាប់កុមាររងគ្រោះ/កុមារងាយរងគ្រោះ/សាក្សីជាកុមារ (ចំណុច ១) ។

● របាំងនេះនឹងត្រូវរៀបចំឡើង មុនពេលកុមាររងគ្រោះ/ជនរងគ្រោះដែលងាយរងគ្រោះ/សាក្សីជាកុមារចូលក្នុងបន្ទប់ និងត្រូវដាក់ ដើម្បីឱ្យជនរងគ្រោះ/សាក្សី ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីអាចមើលឃើញ និងស្តាប់ឮគ្នាទៅវិញទៅមក ប៉ុន្តែជនជាប់ចោទមិនអាចមើលឃើញជនរងគ្រោះ ឬសាក្សីឡើយ ។

● របាំងនេះនឹងត្រូវយកចេញ តែក្រោយពីជនរងគ្រោះ ឬសាក្សីបានចាកចេញពីសាលសវនាការប៉ុណ្ណោះ (ប្រការ៨) ។

អ្នកអាចប្រើចំណុចនេះដើម្បីការពារកុមារពីការមើលឃើញជនជាប់ចោទនៅក្នុងសាលសវនាការ ។

ប្រសិនបើកុមាររបស់អ្នកមិនចង់មើលឃើញជនជាប់ចោទនៅក្នុងតុលាការទេនោះ ត្រូវធានាថា មេធាវីបានធ្វើការស្នើសុំទៅកាន់តុលាការឱ្យបានឆាប់រហ័សបំផុតដើម្បីប្រើរបាំងសវនាការ ។តុលាការមិនអាចបដិសេធសំណើនេះបានទេ ។ធានាថា វាត្រូវបានរៀបចំឡើងមុនពេលកុមារចូលក្នុងបន្ទប់ ។

កន្លែងរង់ចាំ និងការចូលទៅក្នុង ឬការចាកចេញពីសាលសវនាការ

● គួរមានកន្លែងរង់ចាំនិងការរៀបចំដាច់ដោយឡែកដើម្បីការពារកុមារពីការមើលឃើញជនជាប់ចោទ:

- កុមាររងគ្រោះ/សាក្សីអាចស្ថិតនៅក្នុងបន្ទប់រង់ចាំដាច់ដោយឡែកពីគ្នា និងចូលសាលសវនាការតែនៅពេលដល់វេនរបស់គាត់/នាងក្នុងការផ្តល់សក្ខីកម្មប៉ុណ្ណោះ ។
- ជនរងគ្រោះ/សាក្សីគួរត្រូវបានអមដំណើរដោយមនុស្សពេញវ័យសមស្រប ដូចជា ឪពុកម្តាយ បុគ្គលិកសង្គមកិច្ច ក្រឡាបញ្ជី មន្ត្រីនគរបាល ឬបុគ្គលសមស្របផ្សេងទៀតនៅពេលចូល និងចាកចេញពីសាលសវនាការ ។

-កុមាររងគ្រោះ/សាក្សីគួរចូលនិងចាកចេញពីសាលសវនាការ តាមរបៀបមួយដែលគាត់/នាងជៀសវាងទំនាក់ទំនងជាមួយ ឬការមើលឃើញជនជាប់ចោទ-ដូច្នេះជនរងគ្រោះ/សាក្សីបានអង្គុយរួចជាស្រេចនៅក្រោយរបាំង មុនពេលជនជាប់ចោទចូល ឬជនជាប់ចោទបានអង្គុយរួចជាស្រេចនៅក្រោយរបាំង មុនពេលជនរងគ្រោះ/សាក្សីចូល (ចំណុច ៥) ។

អ្នកអាចប្រើចំណុចនេះដើម្បីការពារកុមារពីការមើលឃើញជនជាប់ចោទខណៈដែលពួកគេកំពុងរង់ចាំនៅក្នុងតុលាការ ។

ប្រាប់ទៅកាន់ក្រឡាបញ្ជី មុនថ្ងៃសវនាការដើម្បីប្រាកដថា មានបន្ទប់រង់ចាំមួយដែលត្រូវបានរៀបចំទុកសម្រាប់កុមារ ។

សក្ខីកម្មត្រូវបានផ្តល់ "ក្នុងបន្ទប់ជាអសាធារណៈ" (សវនាការជាអសាធារណៈ)

- សក្ខីកម្មរបស់កុមារ ឬកុមារងាយរងគ្រោះ នឹងត្រូវធ្វើឡើងនៅក្នុងបន្ទប់ជាអសាធារណៈ (ចំណុច ៦) ។
- តុលាការក៏អាចណែនាំទីតាំង និងការផ្លាស់ទីរបស់មនុស្សទាំងអស់ដែលត្រូវបានអនុញ្ញាតឱ្យចូលក្នុងតុលាការផងដែរ រួមទាំងគូភាគី ព្រះរាជអាជ្ញា មេធាវី មន្ត្រីតុលាការ សាក្សី និងអ្នកគាំទ្រ ក្នុងលក្ខខណ្ឌថា ជនរងគ្រោះ/សាក្សី ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីអាចមើលឃើញ និងស្តាប់ឮគ្នាទៅវិញទៅមក និងថា មេធាវីចុងចោទអាចសង្កេតឃើញ អាកប្បកិរិយារបស់ជនរងគ្រោះ/សាក្សី (ចំណុច ៦) ។

វត្តមានរបស់អ្នកគាំទ្រសម្រាប់ជនរងគ្រោះ ឬសាក្សី

- អ្នកគាំទ្រដែលឯកភាពដោយតុលាការ ដូចជា ឪពុកម្តាយ អាណាព្យាបាល បុគ្គលិកសង្គមកិច្ច ឬមនុស្សពេញវ័យដែលទទួលខុសត្រូវផ្សេងទៀត ដែលកុមារបានជ្រើសរើស នឹងត្រូវបានអនុញ្ញាតឱ្យអង្គុយក្បែរកុមារនៅមុខរបាំង ប្រសិនបើចាំបាច់ ។

អ្នកអាចប្រើចំណុចនេះដើម្បីធានាថា កុមារមានការគាំទ្រ ខណៈពេលផ្តល់ភស្តុតាង ។

ប្រសិនបើកុមារមានភាពងាយរងគ្រោះ ឬភ័យខ្លាចជាពិសេស សួរកុមារថា តើពួកគេចង់មានអ្នកគាំទ្រម្នាក់ អង្គុយជាមួយពួកគេ ខណៈដែលពួកគេផ្តល់ភស្តុតាងដែរឬទេ ។ ប្រសិនបើដូច្នោះ សរសេរទៅកាន់ក្រឡាបញ្ជី (ឬស្នើឱ្យមេធាវីធ្វើដូច្នោះ) ឱ្យបានឆាប់រហ័សបំផុត មុនពេលសវនាការ ដើម្បីស្នើសុំឱ្យអនុញ្ញាតចំពោះអ្នកគាំទ្រដោយផ្តល់ព័ត៌មានលម្អិតពេញលេញអំពីអ្នកគាំទ្រនោះ ។

ការផ្តល់សក្ខីកម្មភ្ជាប់តាមទូរទស្សន៍

- ប្រសិនបើជនរងគ្រោះ/សាក្សីត្រូវការការពារជាពិសេសហើយដែលរបាំងសវនាការមិនអាចបម្រើបានការផ្តល់សក្ខីកម្មភ្ជាប់តាមទូរទស្សន៍អាចត្រូវបានប្រើ (ចំណុច ១) ។
- ការស្នើសុំដីកាបង្គាប់ឱ្យធ្វើការផ្តល់សក្ខីកម្មនៅក្នុងបន្ទប់មួយនៅក្រៅបន្ទប់តុលាការនិងការផ្សាយតាមទូរទស្សន៍ទៅកាន់បន្ទប់តុលាការតាមរយៈការភ្ជាប់ទូរទស្សន៍បន្តផ្ទាល់អាចត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា ឬមេធាវី នៅពេលចាប់ផ្តើមការជំនុំជម្រះ (ចំណុច ៩) ។

● នៅពេលពិចារណាលើការស្នើសុំសម្រាប់ការផ្តល់សក្ខីកម្មភ្ជាប់តាមបណ្តាញទូរទស្សន៍ ចៅក្រមនឹងសួរសំណួរជនរងគ្រោះ/សាក្សី (កំបាំងមុខជនជាប់ចោទ) ថាតើពួកគេមានអារម្មណ៍ដូចម្តេចអំពីការផ្តល់សក្ខីកម្មនៅក្នុងសាលសវនាការ (ចំណុច ៩) ។

អ្នកអាចប្រើចំណុចនេះដើម្បីការពារកុមារពីការមើលឃើញជនជាប់ចោទនៅក្នុងសាលសវនាការ ។

ប្រសិនបើកុមារមានភាពងាយរងគ្រោះជាពិសេស ហើយសូម្បីតែរបាំងសវនាការនៅមិនគ្រប់គ្រាន់ក្នុងការធ្វើឱ្យកុមារមានអារម្មណ៍ងាយស្រួលអំពីការផ្តល់សក្ខីកម្ម ត្រូវធានាថា មេធាវីធ្វើការស្នើសុំទៅកាន់តុលាការឱ្យបានឆាប់រហ័សបំផុត ដើម្បីឱ្យកុមារផ្តល់ភស្តុតាងនៅក្នុងបន្ទប់ដែលភ្ជាប់ទូរទស្សន៍ ។ ប្រាប់ទៅកាន់ក្រឡាបញ្ជីមុនពេលសវនាការ ដើម្បីបញ្ជាក់អះអាងថា បរិក្ខារត្រូវបានរៀបចំឡើង មុនពេលកុមារទៅកាន់តុលាការ ។

● គោលការណ៍ណែនាំលេខ ០១ KYSNN/ ០៩ (ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩) ស្តីពីការអនុវត្តមាត្រា ៤២ (ការរួមភេទ ជាមួយអនីតិជនក្រោមអាយុ ១៥ ឆ្នាំ) និងមាត្រា ៤៣ (អំពើអាសចំពោះអនីតិជនក្រោមអាយុ ១៥ ឆ្នាំ) នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលចេញដោយក្រសួងយុត្តិធម៌ ។

● គោលនយោបាយនិងបទដ្ឋានអប្បបរមាសម្រាប់ការពារសិទ្ធិជនរងគ្រោះនៃអំពើជួញដូរមនុស្ស ដែលចេញដោយ MOSYVY (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) ។គោលនយោបាយនេះនិងបទដ្ឋានអប្បបរមាផ្តល់នូវទស្សនាទានទាក់ទងនឹងការការពារគំរូ និងគោលនយោបាយទូទៅ ស្តីពីការការពារសិទ្ធិរបស់ជនរងគ្រោះនៃអំពើជួញដូរមនុស្ស ។

● គោលការណ៍ណែនាំសម្រាប់ការការពារសិទ្ធិរបស់កុមារដែលត្រូវបានជួញដូរនៃព្រះរាជាណាចក្រកម្ពុជា ដែលចេញដោយ CNCC12 ដើម្បីជួយកុមាររងគ្រោះនៃអំពើជួញដូរឱ្យទទួលបានសិទ្ធិជាមូលដ្ឋានរបស់ពួកគេ និងទទួលបានការគាំទ្រសម្រាប់សមាហរណកម្មឡើងវិញដែលសមស្រប ។

● សៀវភៅណែនាំអំពីនីតិវិធីនគរបាលយុត្តិធម៌ដែលអនុម័តដោយនគរបាលជាតិនៃប្រទេសកម្ពុជា ។

តើបុគ្គលមិនមែនផ្នែកច្បាប់អាចធ្វើអ្វីខ្លះដើម្បីជួយអនុវត្តសិទ្ធិរបស់កុមាររងគ្រោះ?

ក្នុងនាមជាមេធាវី បុគ្គលិកសង្គមកិច្ច អ្នកប្រឹក្សាយោបល់ ឬអ្នកគាំទ្រមិនមែនផ្នែកច្បាប់ផ្សេងទៀតសម្រាប់កុមារ អ្នកគឺជាអ្នកតស៊ូមតិដើម្បីឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារ និងត្រូវបានប្រគល់នូវភារកិច្ចការពារកុមារនៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការយុត្តិធម៌ ។

នៅក្នុងករណីខ្លះ កុមារអាចមិនមានមេធាវីទេ ហើយប្រសិនបើករណីនោះកើតឡើង អ្នកតស៊ូមតិសម្រាប់កុមារដែលមិនមែនផ្នែកច្បាប់គួរមានតួនាទីពេញលេញក្នុងការធានាថា កុមារត្រូវបានការពារដោយច្បាប់ដោយធ្វើការជាមួយព្រះរាជអាជ្ញា ។

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## <u>ពាក្យស្នើសុំប្រើប្រាស់បន្ទប់សន្ទនាតាមវីដេអូ</u> / <u>របាំងសវនាការ</u>

មេធាវី................................ជាមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេខ......................................................
មានការិយាល័យ.......................................................................................................................................................... ។

**សូមគោរពជូន**

លោក................................ ប្រធានក្រុមប្រឹក្សាជំនុំជម្រះ........................................................................សាលាដំបូង

**សូមទានជ្រាប ។**

**កម្មវត្ថុ** : ស្នើសុំប្រើប្រាស់បន្ទប់សន្ទនាតាមវិដេអូ ឬរបាំងសវនាការក្នុងបន្ទប់តុលាការ សម្រាប់ជនរង-គ្រោះជាអនីតិជន ឈ្មោះ ................................អាយុ................ទីលំនៅបច្ចុប្បន្ន រស់នៅក្នុងមណ្ឌល....................................................................... ។

**យោង** :
-ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី
-ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
-លិខិតប្រគល់សិទ្ធិរបស់ឈ្មោះ ................................ចុះថ្ងៃទី..............ខែ...............ឆ្នាំ.............. ។

សេចក្តីដូចដែលបានជម្រាបជូនតាមកម្មវត្ថុខាងលើ ខ្ញុំបាទ មានកិត្តិយស សូមជម្រាបជូនលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាជ្រាបថាៈ ក្នុងនាមខ្ញុំបាទ ជាមេធាវីតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី និងការពារសិទ្ធិឱ្យជនរងគ្រោះ ខ្ញុំបាទស្នើសុំលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាអនុញ្ញាតឱ្យកុមារ ដែលបានរាយនាមដូចខាងលើបានប្រើប្រាស់បន្ទប់សន្ទនាតាមវីដេអូ ឬរបាំងសវនា-ការក្នុងបន្ទប់តុលាការក្នុងតំណើរការសវនាការនៅថ្ងៃទី..............ខែ...............ឆ្នាំ..............វេលាម៉ោង..............ព្រឹក/រសៀល ដើម្បីធានាឱ្យបាននូវនីតិវិធីនៃការផ្តល់ចម្លើយ ក៏ដូចជាការសួរចម្លើយប្រកបដោយសុវត្ថិភាព និងការរក្សាការសម្ងាត់ ដោយផ្អែកលើនីតិវិធីកុមារមេត្រី ។

អាស្រ័យហេតុនេះ សូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាអនុញ្ញាត និងជួយសម្រួលតាមនីតិវិធីច្បាប់ ។ សូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី..............ខែ...............ឆ្នាំ..............

**ហត្ថលេខា និង ត្រា**



## ចាប់ពីឧប្បត្តិហេតុដល់ការជំនុំជម្រះក្តី៖ ការប្រើប្រាស់ច្បាប់ដើម្បីគាំពារកុមារ

| ឧប្បត្តិហេតុ | ការស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌ | ការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា |
|---|---|---|
| • ធ្វើការសម្ភាសន៍កុមារដើម្បីប្រមូលភស្តុតាង<br>• អមដំណើរកុមារទៅធ្វើកោលសល្យវិច្ឆ័យណាមួយហើយបញ្ជូនបន្តនូវសំណើសុំអ្នកពិនិត្យដែលមានភេទដូចគ្នា ប្រសិនបើកុមារទាមទារ<br>• ធានាថានគរបាលរក្សាភស្តុតាងនៅកន្លែងកើតហេតុនៃបទល្មើសព្រហ្មទណ្ឌ<br>• ប្រសិនបើកុមាររងគ្រោះចង់ដាក់ពាក្យបណ្តឹងទទួចឱ្យអាជ្ញាធរធ្វើសកម្មភាពដើម្បីអន្តរាគមន៍ (LPDV មាត្រា ៩)<br>• ការពារកុមារប្រឆាំងនឹងការគំរាមកំហែង ការបំភិតបំភ័យ សំណូកតាមរយៈការរាយការណ៍ឧប្បត្តិហេតុទៅកាន់នគរបាល (ក្រមព្រហ្មទណ្ឌ មាត្រា ៥២៧, ៥៤៦, ៥៤៨) | • ធានាថា កុមារបានត្រៀមខ្លួនរួចរាល់ក្នុងការចូលរួមមុនពេលអនុញ្ញាតឱ្យនគរបាលចាប់ផ្តើមការសម្ភាសន៍<br>• អមដំណើរកុមារទៅកាន់ការសម្ភាសន៍របស់នគរបាល និងធានាថាកុមារយល់អ្វីៗទាំងអស់នៅក្នុងរបាយការណ៍របស់នគរបាលមុនពេលកុមារចុះហត្ថលេខាលើអ្វីមួយ<br>• ទទួចឱ្យមានការសួរសំណួរដែលសមស្របចំពោះកុមារ<br>• ទទួចសុំអ្នកបកប្រែ ប្រសិនបើចាំបាច់ | • ធានាថា កុមារត្រៀមខ្លួនជាស្រេចក្នុងការចូលរួមមុនពេលអនុញ្ញាតឱ្យចាប់ផ្តើមធ្វើការសម្ភាសន៍របស់នគរបាល<br>• អមដំណើរកុមារទៅកាន់ការសម្ភាសន៍របស់នគរបាលនិងធានាថាកុមារយល់អ្វីៗទាំងអស់នៅក្នុងរបាយការណ៍របស់នគរបាលមុនពេលកុមារចុះហត្ថលេខាលើអ្វីមួយ<br>• ទទួចស្នើសុំការសួរសំណួរសមស្របចំពោះកុមារ<br>• ទទួចស្នើសុំអ្នកបកប្រែប្រសិនបើចាំបាច់ |

CCP -ក្រមនីតិវិធីព្រហ្មទណ្ឌ
LPDV -ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និង កិច្ចការពារជនរងគ្រោះ

LSHTSE -ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ

PC -ក្រមព្រហ្មទណ្ឌ

ប្រកាសលេខ 62/កយប្រក/08 ស្តីពីការប្រើប្រាស់របាំងសវនាការ និង ការផ្តល់សក្ខីកម្មតាមរយៈបណ្តាញទូរទស្សន៍ពីកុមាររងគ្រោះកុមារងាយរងគ្រោះ ឬកុមារជាសាក្សី

| ការស៊ើបអង្កេតរបស់តុលាការ | ការជំនុំជម្រះក្តី | ក្រោយការជំនុំជម្រះ |
|---|---|---|
| ● អមដំណើរកុមារទៅកាន់ការសម្ភាសន៍ និងការធ្វើសក្ខីកម្មដោយចៅក្រមស៊ើបអង្កេត (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៥០ និង ១៥១) ។ ប្រឆាំងនឹងការសម្ភាសន៍ណាមួយដោយក្រឡាបញ្ជី<br>● ពិនិត្យឡើងវិញលើបញ្ហានៃការការពារដើម្បីធានានូវសុវត្ថិភាព និងសន្តិសុខរបស់កុមារ<br>- ស្នើសុំការឃុំខ្លួនជនជាប់ចោទជាបណ្តោះអាសន្ន (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៦) ឬ<br>- ស្នើសុំការត្រួតពិនិត្យរបស់តាមផ្លូវតុលាការ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២២៣)<br>- ក្នុងករណីអំពើហិង្សាក្នុងគ្រួសារ ពិចារណាស្នើសុំសេចក្តីសម្រេចផ្នែករដ្ឋបាល (LPDV មាត្រា ១៤) ឬ ដីកាការពារ ដើម្បីបង្ការការប៉ះពាល់បន្ថែមពីជនជាប់ចោទ (LPDV មាត្រា ១៦, ២៥ ២៨) ។ | ● អ្នកគាំទ្រដើម្បីឈរក្បែរកុមារនៅក្នុងតុលាការ (ប្រកាស ៦២)<br>● សវនាការជាអសាធារណៈ(ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣១៦)<br>● ប្រើប្រាស់ការផ្តល់ភស្តុតាងតាមរយៈរបាំងសវនាការ ឬ ភ្ជាប់តាមទូរទស្សន៍ (ប្រកាស៦២)<br>● បន្ទប់រង់ចាំតាមបែបកុមារមេត្រី (ប្រកាស ៦២)<br>● សម្រាកប្រសិនបើចាំបាច់<br>● ការសួរសំណួរសមស្របចំពោះកុមារ<br>● ការហាមឃាត់ប្រព័ន្ធផ្សព្វផ្សាយដែលបង្ហាញឈ្មោះកុមារ (ក្នុងករណីនៃការជួញដូរមនុស្ស ឬអំពើធ្វើអាជីវកម្មផ្លូវភេទ) ឬនៅលើសារព័ត៌មានដែលបោះពុម្ពផ្សាយព័ត៌មាន រូបថត គំនូរ ឬដែលរាយការណ៍តាមរបៀបមួយដែលកំណត់អត្តសញ្ញាណកុមារ (ក្នុងករណីណាក៏ដោយដែលពាក់ព័ន្ធនឹងកុមារ) (LSHTSE មាត្រា៤៩ ច្បាប់ស្តីពីរិជ្ជាជីវៈរបបសារព័ត៌មានមាត្រា ១៥) ។ | ● ប្រសិនបើជនជាប់ចោទមិនត្រូវបានផ្តន្ទាទោសជាប់ពន្ធនាគារទេនោះ ពិចារណាស្នើសុំទោសទណ្ឌបន្ថែមដែលរារាំងជនជាប់ចោទមិនឱ្យទាក់ទងកុមារ ។ ក្នុងករណីជនបរទេស មិនឱ្យស្ថិតនៅក្នុងប្រទេសកម្ពុជា (ក្រមនីតិវិធីព្រហ្មទណ្ឌមាត្រា ២៤៥) ។<br>● ប្រសិនបើជនជាប់ចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំ សម្រាប់ការព្យួរទោសមានលក្ខខណ្ឌ ស្នើសុំលក្ខខណ្ឌនានាដែលការពារកុមារប្រឆាំងនឹងជនជាប់ចោទពីការខិតជិត ឬទាក់ទងកុមារ ។ |



# ផែនការយុទ្ធសាស្ត្រសម្រាប់
# គាំទ្រកុមារជាសាក្សី



# របៀបដែលអ្នកគាំទ្រកុមារជាសាក្សី

ចងចាំថាកុមារនីមួយៗមានលក្ខណៈពិសេសផ្ទាល់ខ្លួន។ ពួកគេឆ្លើយតបខុសៗគ្នាទៅនឹងស្ថានភាពប៉ះទង្គិចផ្លូវចិត្ត ។ អ្វីដែលមានប្រសិទ្ធភាពសម្រាប់កុមារម្នាក់អាចមិនមានប្រសិទ្ធភាពសម្រាប់កុមារម្នាក់ទៀតនោះទេ។

ដំណាក់កាលអភិវឌ្ឍន៍របស់កុមារអាចមិនចាំបាច់ស្របទៅនឹងអាយុតាមលំដាប់ពេលវេលារបស់ពួកគេឡើយ ។ ឧទាហរណ៍កុមារដែលបានទទួលរងការប៉ះទង្គិចផ្លូវចិត្ត ឬការព្រងើយកន្តើយដដែលៗអាចមានកម្រិតយល់ដឹងទាបជាងអ្វីដែលគេរំពឹងទុកសម្រាប់កុមារដែលស្ថិតក្នុងអាយុរបស់ពួកគេ។

យុទ្ធសាស្ត្ររបស់អ្នក សម្រាប់ការគាំទ្រសាក្សីដែលជាកុមារ និងការត្រៀមខ្លួនសម្រាប់តុលាការ គួរផ្អែកលើការយល់ដឹងរបស់អ្នកអំពីអត្តចរិត និងស្ថានភាពរបស់កុមារនោះរួមទាំង :

- ការសង្កេតរបស់អ្នកអំពីឥរិយាបថកម្រិតនៃការយល់ដឹង និងអាកប្បកិរិយារបស់កុមារ។
- ការយល់ដឹងរបស់អ្នកអំពីបទល្មើសព្រហ្មទណ្ឌដែលត្រូវបានប្រព្រឹត្ត។
- កាលៈទេសៈផ្ទាល់ខ្លួនជាក់លាក់របស់កុមារ (រួមទាំងថាតើពួកគេមានការគាំទ្រពីគ្រួសារឬសហគមន៍ដែរឬទេ)។
- ការវាយតម្លៃរបស់អ្នកអំពីអ្វីដែលកុមារព្រួយបារម្ភ (ឧទាហរណ៍កុមារមួយចំនួនភ័យខ្លាចក្នុងការឃើញជនជាប់ចោទនៅពេលជំនុំជម្រះ តែកុមារខ្លះទៀតមិនភ័យខ្លាច កុមារខ្លះបារម្ភអំពីការធ្លាក់ចូលទៅក្នុងបញ្ហាប្រសិនបើពួកគេផ្តល់សក្ខីកម្មមិនបានល្អ)។

## ជំហានសំខាន់ៗទាំងបីក្នុងការគាំទ្រកុមារ

មានជំហានចំនួនបីក្នុងការគាំទ្រកុមារ:

### ការការពារ

ធានាថា សុវត្ថិភាព និងសន្តិសុខរបស់កុមារត្រូវបានថែរក្សា ។

### ការគាំទ្រផ្លូវអារម្មណ៍

ធានាថាការជម្រាបប្រាប់អំពីការប៉ះទង្គិចផ្លូវចិត្តក្នុងការគាំទ្រផ្លូវអារម្មណ៍ត្រូវបានផ្តល់ដល់កុមារដើម្បីជួយពួកគេជំនះភាពតានតឹងនៃការចូលរួមនៅក្នុងដំណើរការយុត្តិធម៌។

### ការត្រៀមខ្លួន

ការត្រៀមកុមារឱ្យយល់ និងចូលរួមនៅក្នុងដំណើរការយុត្តិធម៌-ការផ្តល់ឱ្យពួកគេនូវព័ត៌មាន និងឧបករណ៍។

ការផ្តល់ការត្រៀមខ្លួនសម្រាប់តុលាការមុនពេលជំនុំជម្រះ និងការគាំទ្រនៅថ្ងៃជំនុំជម្រះ។

អ្នកអាចស្វែងរកព័ត៌មានបន្ថែមរបស់យើងអំពីជំហានទាំងបីនេះ នៅក្នុងជំពូកខាងក្រោមនៃសៀវភៅណែនាំនេះ។

## ចាប់ផ្ដើមយ៉ាងឆាប់បំផុតតាមដែលអាចធ្វើទៅបាន

វាគឺជាការសំខាន់បំផុតដែលអ្នកចាប់ផ្ដើមកម្មវិធីត្រៀមខ្លួនសម្រាប់តុលាការរបស់អ្នកឱ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន ។ ដោយសារអ្នកកំពុងធ្វើការជាមួយកុមារដែលអាចត្រូវបានធ្វើឱ្យទទួលរងការប៉ះទង្គិចផ្លូវចិត្ត អ្នកនឹងត្រូវការពេលវេលាច្រើនជាងធម្មតាក្នុងការត្រៀមខ្លួនពួកគេដើម្បីទៅតុលាការ។ អ្នកចាំបាច់ត្រូវអនុញ្ញាតឱ្យមានពេលវេលាច្រើន ដើម្បីរៀបចំទំនាក់ទំនងផ្ដល់នូវការគាំទ្រផ្លូវចិត្តពន្យល់អំពីនីតិវិធីនានា និងត្រៀមខ្លួនកុមារដើម្បីឆ្លើយសំណួរនានា។

## ដាក់បញ្ចូលគ្នានូវក្រុមអ្នកគាំទ្រ

ក្រុមអ្នកគាំទ្រគប្បីត្រូវបានដាក់បញ្ចូលគ្នាដែលនឹងត្រូវតាមដានរឿងក្ដីរបស់កុមាររហូតដល់ចប់ ។ វាជាការមួយដែលកាន់តែប្រសើរដែលត្រូវមានមនុស្សដដែលស្ថិតនៅជាមួយកុមារក្នុងអំឡុងពេលដំណើរការទាំងមូល ។ ដើម្បីបន្តផ្ដល់នូវស្មារតីសម្រាប់កុមារធ្វើឱ្យកុមារនឹងអាចឆ្លើយតបកាន់តែប្រសើរទៅមនុស្សដែលពួកគេមានឱកាសក្នុងការអភិវឌ្ឍន៏ទំនាក់ទំនងជាមួយបន្ដបន្ទាប់ទៀត។

ក្រុមរបស់អ្នកគួររួមបញ្ចូលបុគ្គលដូចខាងក្រោម ដោយបុគ្គលនីមួយៗអនុវត្តតួនាទីខុសៗគ្នា ៖






## ការធ្វើការជាក្រុម-អ្នកណាធ្វើអ្វី ?

មនុស្សគ្រប់គ្នានៅក្នុងក្រុមទទួលខុសត្រូវចំពោះការគាំទ្រសុខុមាលភាពផ្លូវអារម្មណ៍និងផ្លូវចិត្តរបស់កុមារនៅពេលពួកគេត្រៀមខ្លួនរួចរាល់ដើម្បីទៅតុលាការ និងធ្វើការឆ្ពោះទៅទទួលបានការកាត់ទោសជនល្មើស ។

សមាជិកទាំងអស់នៃក្រុមត្រូវតែធ្វើការឆ្ពោះទៅសម្រេចគោលដៅទាំងពីរនេះ ដោយសមាជិកនីមួយៗផ្តោតការងាររបស់ខ្លួនលើទិដ្ឋភាពផ្សេងៗនៃការការពារ និងការត្រៀមខ្លួន :

១. ការផ្តល់ការគាំទ្រផ្លូវអារម្មណ៍ និងផ្លូវចិត្ត

២. ត្រៀមខ្លួនកុមារដើម្បីផ្តល់ភស្តុតាងនៅក្នុងតុលាការ

សមាជិកម្នាក់ៗនៃក្រុមនឹងផ្តោតលើផ្នែកផ្សេងៗនៃការត្រៀមខ្លួន :

- អ្នកប្រឹក្សាយោបល់ផ្តោតលើការផ្តល់ការគាំទ្រផ្លូវអារម្មណ៍ដល់កុមារ ការដោះស្រាយលក្ខខណ្ឌនៃការប៉ះទង្គិចផ្លូវចិត្តនិងការបំពាក់បំប៉នដល់កុមារនូវបច្ចេកទេសដោះស្រាយដើម្បីជួយគាត់ឬនាងឱ្យឆ្លងកាត់ដំណើរការនេះ ។

- មេធាវីផ្តោតលើការផ្តល់ព័ត៌មានដល់កុមារអំពីដំណើរការតុលាការ ត្រៀមខ្លួនកុមារសម្រាប់ការចូលរួមនៅក្នុងតុលាការ ការឆ្លើយសំណួរ និងធ្វើការរៀបចំដើម្បីផ្តល់នូវការការពារដល់កុមារទាក់ទងនឹងការចូលរួមនៅក្នុងតុលាការ ។

- បុគ្គលិករបស់អង្គការក្រៅរដ្ឋាភិបាលសម្របសម្រួលដំណើរការនេះ និងធានាថា កុមារ និងឪពុកម្តាយ ឬអាណាព្យាបាលទទួលបានព័ត៌មានពេញលេញនៅដំណាក់កាលនីមួយៗនៃដំណើរការដោយធានាថា ជំនួបនានាត្រូវបានរៀបចំឡើងជាមួយនឹងអ្នកប្រឹក្សាយោបល់ និងមេធាវីដើម្បីអនុញ្ញាតឱ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការត្រៀមខ្លួន ។ បុគ្គលិករបស់អង្គការក្រៅរដ្ឋាភិបាលក៏អាចចូលរួមនៅក្នុងការរៀបចំភស្តុភារទាក់ទងនឹងការចូលរួមនៅក្នុងតុលាការផងដែរ (ឧទាហរណ៍ ការដឹកជញ្ជូន) ។

នៅក្នុងគ្រប់ចំណាត់ការទាំងអស់ដែលត្រូវបានអនុវត្តទាក់ទងនឹងកុមារ អ្នករាល់គ្នាគួរតែអនុវត្តចំណាត់ការដើម្បីឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារ និងធានាជានិច្ចនូវសុវត្ថិភាព និងសន្តិសុខរបស់កុមារ ។

> “នៅក្នុងគ្រប់ចំណាត់ការទាំងអស់ដែលត្រូវបានអនុវត្តទាក់ទងនឹកុមារ អ្នករាល់គ្នាគួរតែអនុវត្តចំណាត់ការដើម្បីឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារ និងធានាជានិច្ចនូវសុវត្ថិភាព និងសន្តិសុខរបស់កុមារ ។”



## ជំនួយពិសេសនៅក្នុងករណីនៃការជួញដូរមនុស្ស

ក្នុងករណីនៃការជួញដូរមនុស្ស មេធាវី និងបុគ្គលិកគ្រប់គ្រងករណីផ្សេងទៀតរបស់អង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រកុមាររងគ្រោះ ឬសាក្សីជាកុមារគួរតែដឹងអំពីគម្រោងសម្របសម្រួលសាក្សីជនរងគ្រោះដែលដំណើរការនៅក្នុងទីតាំងចំនួនពីរនៅភ្នំពេញនិងសៀមរាបសម្រាប់រយៈពេលសាកល្បងចំនួន ២ ឆ្នាំចាប់ពីឆ្នាំ២០១៥។ នេះគឺជាគម្រោងរួមគ្នាមួយរវាងកម្មវិធីអូស្ត្រាលីអាស៊ី ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស MOSVY (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា) និង MOJ (ក្រសួងយុត្តិធម៌)។

ក្រោមគម្រោងនេះ អ្នកសម្របសម្រួលសាក្សីជនរងគ្រោះចំនួនពីររូប ត្រូវបានដាក់នៅក្នុងការិយាល័យព្រះរាជអាជ្ញានិងរងចាំដើម្បីគាំទ្រជនរងគ្រោះ-សាក្សីនៅក្នុងដំណើរការយុត្តិធម៌ព្រហ្មទណ្ឌទាំងមូល។

មេធាវី និងបុគ្គលិកគ្រប់គ្រងករណីផ្សេងទៀតរបស់អង្គការមិនមែនរដ្ឋាភិបាលដែលគាំទ្រជនរងគ្រោះ-សាក្សីដែលជាកុមារដែលពាក់ព័ន្ធនៅក្នុងករណីនៃការជួញដូរមនុស្សនៅភ្នំពេញ ឬសៀមរាបគួរទាក់ទងការិយាល័យព្រះរាជអាជ្ញាសម្រាប់ការគាំទ្របែបនេះ។





# ការយល់ដឹងអំពី
# កុមារ និង ការប៉ះទង្គិចផ្លូវចិត្ត



ចងចាំថា : កុមារដែលត្រូវបានគាំទ្រកាន់តែប្រសើរ និងកុមារដែលត្រៀមខ្លួនបានល្អគឺជាសាក្សីកាន់តែល្អ

## តើអ្វីធ្វើឱ្យសាក្សីជាកុមារមានលក្ខណៈខុសពីសាក្សីជាមនុស្សពេញវ័យ?

អ្នកវិជ្ជាជីវៈណាម្នាក់ដែលកំពុងគាំទ្រសាក្សីជាកុមារឆ្លងកាត់ដំណើរការយុត្តិធម៌ ចាំបាច់ត្រូវតែយល់ដឹងអំពីអត្តចរិតពិសេសខុសៗគ្នារបស់កុមារដែលធ្វើឱ្យពួកគេមានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីសាក្សីជាមនុស្សពេញវ័យ ។

វាជាការសំខាន់ដែលត្រូវយល់ដឹងអំពីភាពខុសគ្នាទាំងនេះ ពីព្រោះភាពខុសគ្នាទាំងនេះនឹងមានឥទ្ធិពលដោយផ្ទាល់លើអ្វីដែលអ្នកអាចរំពឹងចង់បានពីកុមារនិងរបៀបដែលអ្នកត្រៀមកុមារសម្រាប់ដំណើរការយុត្តិធម៌ ។

ចងចាំថាៈ កុមារដែលត្រូវបានគាំទ្រកាន់តែប្រសើរ និងកុមារដែលត្រៀមខ្លួនបានល្អ គឺជាសាក្សីកាន់តែល្អ

- **ជាញឹកញាប់កុមារមានការពិបាកពីបញ្ហាផ្លូវចិត្តជាមួយអ្វីដែលបានកើតឡើងចំពោះពួកគេ**

កុមារដែលបានទទួលរងផលប៉ះពាល់ដោយសារបទល្មើស-ជាពិសេសអំពើហិង្សា ឬបទល្មើសផ្លូវភេទ-ជាធម្មតា ជួបប្រទះការប៉ះទង្គិចផ្លូវអារម្មណ៍ដែលធ្វើឱ្យពួកគេមានការលំបាកជាពិសេសក្នុងបញ្ហាផ្លូវចិត្ត ។

នេះមានន័យថាជាធម្មតាវាជាការចាំបាច់ដែលត្រូវចំណាយពេលកាន់តែច្រើនជាមួយពួកគេ និងចូលរួមនៅក្នុងការធ្វើអ្វីដដែលៗកាន់តែច្រើន មុនពេលពួកគេត្រៀមខ្លួនរួចរាល់ដើម្បីចូលរួមនៅក្នុងដំណើរការយុត្តិធម៌ ។

- **កុមារនៅតែកំពុងអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនដើម្បីយល់ដឹងអំពីការណែនាំមួយចំនួន**

ប្រសិនបើគ្មានវាក្យសព្ទដែលត្រូវបានបង្កើតពេញលេញសម្រាប់ពួកគេនោះទេ កុមារគឺជាអ្នករៀនតាមបែបមើលឃើញ និងតាមបទពិសោធន៍ និងដោយហេតុនេះបានទាញយកអត្ថប្រយោជន៍យ៉ាងខ្លាំងពីការប្រើប្រាស់ឧបករណ៍ជំនួយដើម្បីស្វែងយល់អ្វីៗនៅជុំវិញពួកគេ ។

នេះមានន័យថា វាជាការសំខាន់ដែលត្រូវប្រើប្រាស់វិធីដែលមានភាពច្នៃប្រឌិតដើម្បីពន្យល់អំពីគោលគំនិតនានា-ដូចជា ការចូលរួមនៅក្នុងតុលាការ-ដល់ពួកគេ។ អ្នកអាចពិចារណាប្រើប្រាស់គំនូរជីវចលអំពីតុលាការដែលត្រូវបានបញ្ចូលនៅក្នុងកញ្ចប់ឯកសារនេះ ។

- **កុមារអាចមានការពិបាកក្នុងការប្រាប់ពីគំនិត និងការចងចាំរបស់ពួកគេ**

កុមារអាចមិនទាន់អភិវឌ្ឍន៍ជំនាញក្នុងការប្រាប់ពីគំនិតអារម្មណ៍និងការចងចាំរបស់ពួកគេនៅឡើយ ។ពួកគេអាចមានវាក្យសព្ទមិនគ្រប់គ្រាន់ក្នុងការសម្តែងចេញនូវអ្វីដែលពួកគេចង់និយាយនិងមានការពិបាកក្នុងការពន្យល់ ព្រឹត្តិការណ៍នានាតាមរបៀបសាមញ្ញដែលមានតាមលំដាប់លំដោយ និងទាក់ទងគ្នា។

ជាធម្មតាមានន័យថា អ្នកគាំទ្រ និងមេធាវីចាំបាច់ត្រូវតែប្រើបច្ចេកទេសទំនាក់ទំនង និងសួរសំណួរតាមបែប កុមារមេត្រី ដើម្បីជួយកុមារឱ្យយល់ដោយខ្លួនឯង ។

- **កុមារប្រហែលជាមិនអាចសម្របខ្លួនបានល្អដូចមនុស្សពេញវ័យទេ**

ពីព្រោះតែពួកគេមានការគ្រប់គ្រងលើខ្លួនឯងតិចតួចលើស្ថានភាព កុមារមានសមត្ថភាពទាបជាងមនុស្សពេញវ័យក្នុងការដោះស្រាយ និងសម្របខ្លួនតាមហេតុការណ៍ជីវិតដែលបង្កអន្តរាយដល់ពួកគេ។

នេះអាចមានន័យថាពួកគេមិនឆ្លើយតបទៅនឹងដំណាក់កាលលំបាកៗនៃដំណើរការយុត្តិធម៌តាមរបៀបមួយដូចមនុស្សពេញវ័យទេ-ឧទាហរណ៍ ពួកគេអាចមានការពិបាកកាន់តែខ្លាំងក្នុងការឆ្លើយសំណួរនៅក្នុងការស៊ើបអង្កេត ឬផ្តល់ភស្តុតាងនៅក្នុងតុលាការ។

- **ជាញឹកញាប់កុមារមានការជួបប្រទះក្នុងការដោះស្រាយផ្នែកការប៉ះទង្គិចផ្លូវចិត្តខុសៗគ្នា**

ហេតុការណ៍នានា ដូចជា បទហិង្សា និងបទល្មើសផ្លូវភេទជាធម្មតាបង្កើតនូវការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរចំពោះជនរងគ្រោះ និងសាក្សី។ ឥទ្ធិពលនៃការប៉ះទង្គិចផ្លូវចិត្តនេះមានរយៈពេលយូរ និងអាចរារាំងសមត្ថភាពរបស់មនុស្សនោះមិនឱ្យចូលរួមជាមួយអ្នកដទៃ និងប្រព័ន្ធយុត្តិធម៌។

ការប៉ះទង្គិចផ្លូវចិត្តជាញឹកញាប់ស្តែងចេញចំពោះកុមារខុសៗគ្នាពីព្រោះខួរក្បាលរបស់ពួកគេមិនទាន់អភិវឌ្ឍពេញលេញនៅឡើយ ដើម្បីជួយពួកគេក្នុងការដោះស្រាយនូវការប៉ះទង្គិចផ្លូវចិត្តបែបនោះ។ ដូច្នេះវិធីសាស្ត្រមួយដែលមានព័ត៌មានគ្រប់គ្រាន់អំពីការប៉ះទង្គិចផ្លូវចិត្តដើម្បីគាំទ្រគឺមានសារៈសំខាន់ខ្លាំងណាស់-បញ្ហានេះត្រូវបានពិភាក្សាលម្អិតបន្ថែមខាងក្រោម។

- **កុមារមានភាពងាយរងគ្រោះច្រើន ពីព្រោះពួកគេមានលទ្ធភាពតិចដើម្បីការពារខ្លួនពួកគេ**

បទហិង្សា និងបទល្មើសផ្លូវភេទ ជាធម្មតាត្រូវបានផ្សារភ្ជាប់ទៅនឹងការមាក់ងាយ ពិរុទ្ធភាព និងក្តីអាម៉ាសដែលជាញឹកញាប់រារាំងកុមារមិនឱ្យនិយាយចេញមក។ បញ្ហានេះកាន់តែមានភាពធ្ងន់ធ្ងរសម្រាប់កុមារដែលអាចមានអារម្មណ៍កាន់តែងាយរងគ្រោះពីព្រោះពួកគេមិនមានលទ្ធភាពដូចមនុស្សពេញវ័យដើម្បីការពារខ្លួននោះទេ។ កុមារពឹងផ្អែកទាំងស្រុងលើមនុស្សពេញវ័យ និងសហគមន៍ដែលអ្នកទាំងអស់នោះក្នុងករណីមួយចំនួនបានក្បត់ទំនុកចិត្តលើកុមាររួចទៅហើយ ។ ជាញឹកញាប់ពួកគេមិនអាចនិយាយចេញមកសម្រាប់ខ្លួនឯងឡើយ ឬពួកគេមិនត្រូវបានផ្តល់ឱកាសដើម្បីនិយាយចេញមកទេ។ ពួកគេប្រហែលជាខកខានក្នុងការបញ្ចេញអង្គហេតុសំខាន់ៗ ពីព្រោះតែកំហុស ឬដោយសារតែពួកគេចង់ការពារក្រុមគ្រួសារ ឬ សូម្បីតែជនល្មើស។

ដោយចងចាំប្រការនេះក្នុងចិត្ត ការកំណត់ពេលវេលានិងជំហានៗឱ្យបានល្អគឺជាការចាំបាច់ដើម្បីជៀសវាងការបង្ខំកុមារឱ្យធ្វើការលាតត្រដាងមុនពេលពួកគេត្រៀមខ្លួនរួចរាល់។

## ប្រព័ន្ធយុត្តិធម៌តាមរយៈក្រសែភ្នែកកុមារ

ដំណើរការយុត្តិធម៌អាចមានលក្ខណៈធំធេងមិនគួរឱ្យជឿ ។ កុមារនឹងបារម្ភអំពីៈ

ខ្ញុំនឹងត្រូវនិយាយអំពីរឿងរ៉ាវដ៏អាម៉ាស ឈឺចាប់ និងផ្ទាល់ខ្លួនដល់មនុស្សពេញវ័យដែលខ្ញុំមិនស្គាល់ ឬទុកចិត្ត ។

ខ្ញុំឬគ្រួសាររបស់ខ្ញុំអាចមិនមានសុវត្ថិភាព ឬ "ធ្លាក់ក្នុងបញ្ហា" ពីព្រោះខ្ញុំបានរាយការណ៍អំពីអំពើបទល្មើសព្រហ្មទណ្ឌ ។

ខ្ញុំប្រហែលជាត្រូវបានបែកពីឪពុកម្តាយឬអាណាព្យាបាលរបស់ខ្ញុំ និងត្រូវបានមាក់ងាយពីសំណាក់សហគមន៍របស់ខ្ញុំ ។

ខ្ញុំនឹងត្រូវជួបជនជាប់ចោទនៅក្នុងតុលាការ-តើខ្ញុំមានសុវត្ថិភាព ឬទេ?

ខ្ញុំនឹងនៅក្នុងបន្ទប់តុលាការដែលពេញទៅដោយមនុស្សប្លែកមុខនិងអាជ្ញាធរដែលបំភិតបំភ័យនិងគំរាមកំហែង ។

ខ្ញុំនឹងត្រូវឆ្លើយសំណួរពីមេធាវីជនជាប់ចោទដ៏កម្រោលដែលព្យាយាមផ្ចាញ់ខ្ញុំ ឬធ្វើឱ្យខ្ញុំភាន់ច្រឡំ ។

បរិយាកាសបំភិតបំភ័យ និងលំបាកបែបនេះបង្កើតនូវភាពតានតឹងយ៉ាងធំធេងចំពោះកុមារ ។ ភាពតានតឹងនេះអាចបង្កើតហានិភ័យក្នុងការផ្តល់សក្ខីកម្មនៅក្នុងតុលាការ និងបង្កើតនូវការប៉ះទង្គិចផ្លូវចិត្តរយៈពេលយូរឬធ្វើឱ្យមានការប៉ះទង្គិចផ្លូវចិត្តជាថ្មីម្តងទៀតចំពោះកុមារ ។

## ហេតុអ្វីបានជាយើងចាំបាច់ត្រូវតែយល់ដឹងអំពីការប៉ះទង្គិចផ្លូវចិត្តដើម្បីគាំទ្រសាក្សីជាកុមារ?

ការប៉ះទង្គិចផ្លូវចិត្ត ផ្លាស់ប្តូរខួរក្បាល និងរាងកាយរបស់កុមារ ហេតុដូចនេះហើយ កុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តអាចប្រព្រឹត្តអាកប្បកិរិយាខុសគ្នាខ្លាំងពីរបៀបនៃការប្រព្រឹត្តអាកប្បកិរិយារបស់កុមារ "ធម្មតា" ។

នៅក្នុងការគាំទ្រកុមារឆ្លងកាត់ដំណើរការច្បាប់ អ្នកចាំបាច់ត្រូវតែយល់ដឹងថាការប៉ះទង្គិចផ្លូវចិត្តមានឥទ្ធិពលលើរបៀបដែលកុមារ ៖

- មានទំនាក់ទំនងជាមួយមនុស្សដែលនៅជុំវិញពួកគេ (រួមមានមេធាវី មន្ត្រីនគរបាល និងមន្ត្រីតុលាការ) ។
- គិតនិងដំណើរការព័ត៌មានអំពីអ្វីដែលនឹងកើតឡើងចំពោះពួកគេនិងដំណើរការតុលាការ ។
- អាចយល់អំពីសំណួរដែលត្រូវបានដាក់ឱ្យពួកគេនៅក្នុងតុលាការ ។
- ដោះស្រាយភាពតានតឹងនៅពេលស្ថិតនៅក្នុងតុលាការ ។

## តើការប៉ះទង្គិចផ្លូវចិត្តគឺជាអ្វី?

ការប៉ះទង្គិចផ្លូវចិត្តកើតមានឡើងនៅពេលមនុស្សម្នាក់ប្រឈមនឹងហេតុការណ៍ណាមួយដែលគំរាមកំហែង ឬគួរឱ្យភ័យខ្លាចខ្លាំង ដែលរាងកាយរបស់គាត់ ឬនាងឆ្លើយតបជាមួយនឹងឥទ្ធិពលដែលរយៈពេលយូរ-រាងកាយមានប្រតិកម្មផ្លូវកាយនិងស្ថានភាពផ្នែកប្រព័ន្ធប្រសាទមានការប្រែប្រួល ។

ដូច្នេះ ការប៉ះទង្គិចផ្លូវចិត្ត គឺជាសំណល់ផ្លូវអារម្មណ៍ ផ្លូវចិត្ត និងផ្នែកសរីរសាស្ត្រដែលបន្សល់ពីភាពតានតឹងដ៏ខ្ពស់ដែលនៅជាមួយបទពិសោធន៍នៃការគំរាមកំហែង ។

កុមារងាយទទួលរងគ្រោះដោយការប៉ះទង្គិចផ្លូវចិត្តជាងមនុស្សពេញវ័យពីព្រោះខួរក្បាល និងរាងកាយរបស់ពួកគេមិនទាន់អភិវឌ្ឍពេញលេញនៅឡើយ ។ ពួកគេមិនមានសមត្ថភាពផ្លូវចិត្ត ឬផ្លូវកាយដើម្បីដោះស្រាយនឹងអ្វីដែលបានកើតឡើងចំពោះពួកគេ ឬដើម្បីការពារខ្លួនឡើយ ។

## របៀបដែលការប៉ះទង្គិចផ្លូវចិត្តប៉ះពាល់ដល់អាកប្បកិរិយារបស់កុមារ

វាជាការសំខាន់ដែលអ្នកត្រូវយល់ដឹងថាការប៉ះទង្គិចផ្លូវចិត្ត ប៉ះពាល់ដល់កុមារទាំងផ្នែកផ្លូវចិត្ត ផ្លូវកាយ និងផ្នែកសរីរសាស្ត្រ ។

នេះមានន័យថា ប្រសិនបើអ្នកកំពុងជួយអតិថិជនជាកុមារដែលទំនងជា“ប្រព្រឹត្តអាកប្បកិរិយាមិនសមរម្យ” ឬ “មិនសហការ” ជាមួយនឹងដំណើរការតុលាការ នោះអ្នកមិនត្រូវដោះស្រាយតាមបែបធម្មតាដូចកុមារដទៃទៀតដែលមានអាកប្បកិរិ-យាមិនសមរម្យនោះឡើយ ។

ការប្រែប្រួលចំពោះខួរក្បាល និងរាងកាយរបស់កុមារដែលបណ្តាលមកពីការប៉ះទង្គិចផ្លូវចិត្ត នឹងប៉ះពាល់ដល់របៀប ដែលកុមារប្រព្រឹត្តអាកប្បកិរិយា ។



## ការប៉ះទង្គិចផ្លូវចិត្តប៉ះពាល់ដល់ខួរក្បាល

យោងតាមការសិក្សាជាច្រើន ការប៉ះទង្គិចផ្លូវចិត្តផ្លាស់ប្តូរប្រព័ន្ធប្រសាទ និងខួរក្បាល ។

ផ្នែកជាច្រើននៃខួរក្បាលដែលកំពុងអភិវឌ្ឍន៍របស់កុមារ ត្រូវបានផ្លាស់ប្តូរផ្នែកសរីរសាស្រ្តដោយសារការប៉ះទង្គិចផ្លូវចិត្ត ។ ជាលទ្ធផល មុខងារផ្សេងៗនៃខួរក្បាលបានទទួលរងផលប៉ះពាល់ :

- សមត្ថភាពរបស់កុមារក្នុងការគិត ឆ្លើយតប គ្រប់គ្រងអារម្មណ៍ និងសម្តែងចេញនូវអារម្មណ៍សុទ្ធតែទទួលរងផលប៉ះពាល់ ។
- កុមារអាចទទួលរងនូវការលូតលាស់យឺតយ៉ាវដែលមានន័យថាខួរក្បាលមានសមត្ថភាពកាន់តែតិចតួចក្នុងការអនុញ្ញាតឱ្យកុមារយល់អំពីរឿងរ៉ាវថ្មីៗឬអភិវឌ្ឍជំនាញថ្មីៗ ។
- កុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តអាចរស់នៅក្នុងសភាពភ្ញាក់ផ្អើលនិងប្រុងប្រយ័ត្នជានិច្ច ដែលមានន័យថា កុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត ងាយនឹងមានប្រតិកម្មទៅនឹងបញ្ហាបន្តិចបន្តួច ។
- ប្រព័ន្ធចងចាំរបស់កុមារស្ថិតនៅក្រោមភាពតានតឹងដែលមានន័យថា កុមារអាចមានការលំបាកយ៉ាងខ្លាំងក្នុងការរំឭកហេតុការណ៍ និងរក្សាទុកព័ត៌មានថ្មីៗ ។ ខួរក្បាលរបស់កុមារអាច "រាំងខ្ទប់" ក្នុងការចងចាំមួយចំនួនដែលមានភាពឈឺចាប់ហួសហេតុពិបាកក្នុងការរំឭកឡើងវិញ (ដូចជា ការរំលោភសេពសន្ថវៈ ឬការវាយប្រហារជាដើម) ។

ដូច្នេះនៅក្នុងការត្រៀមខ្លួនកុមារសម្រាប់តុលាការ ឬការនាំផ្លូវកុមារឆ្លងកាត់ដំណើរការយុត្តិធម៌ កុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តនឹងទាមទារនូវការយកចិត្តទុកដាក់ និងការយល់ចិត្តបន្ថែមកាន់តែច្រើន ។

## ការប៉ះទង្គិចផ្លូវចិត្តប៉ះពាល់ដល់អាកប្បកិរិយា និងអារម្មណ៍

ការចងចាំនៃការប៉ះទង្គិចផ្លូវចិត្ត គឺជាការទទួលរងនូវផ្នែករាងកាយ ព្រមទាំងផ្នែកអារម្មណ៍ និងផ្លូវចិត្ត ។ នៅពេលកុមាររំឭកហេតុការណ៍ប៉ះទង្គិចផ្លូវចិត្ត គាត់ ឬនាងអាចមានប្រតិកម្មផ្នែករាងកាយ តាមរបៀបដូចគ្នា នៅពេលដែលការប៉ះទង្គិចផ្លូវចិត្តកំពុងកើតឡើង ។

កុមារដែលរងការប៉ះទង្គិចផ្លូវចិត្តអាចមានអាកប្បកិរិយាតាមរបៀបដូចខាងក្រោម[1] :

- ការចងចាំរឿងរ៉ាវឈឺចាប់-កុមារអាចមានការចងចាំនូវហេតុការណ៍ដែលកើតឡើងនៅពេលវេលាដែលមិនរំពឹងទុក ។
- ការជំរុញឱ្យកើតឡើង-សូម្បីតែនៅពេលដែលកុមារកំពុងស្ថិតនៅក្នុងបរិយាកាសមានសុវត្ថិភាពក៏ដោយ អ្វីមួយអាចរំឭកកុមារអំពីហេតុការណ៍ដើមដែលគំរាមកំហែងកាលពីមុន ហើយកុមារអាចទទួលរងប្រតិកម្មផ្នែករាងកាយនិងផ្លូវចិត្តដូចគ្នា ដែលពួកគេបានឆ្លងកាត់ក្នុងអំឡុងពេលនៃហេតុការណ៍គំរាមកំហែងដំបូង ។
- "ការកាត់ផ្តាច់ទំនាក់ទំនង"-រាងកាយរបស់កុមារ ការពារកុមារ តាមរយៈការកាត់ចិត្តពីអ្វីដែលជួបប្រទះ ដែលមានភាពធំធេងពេកក្នុងការដោះស្រាយ ។

[1]Crenshaw,D "គោលការណ៍ណែនាំសម្រាប់មេធាវី និងចៅក្រមក្នុងការទទួលស្គាល់និងឆ្លើយតបទៅនឹងប្រតិកម្មនៃភាពតានតឹងដោយសារការប៉ះទង្គិចផ្លូវចិត្តរបស់សាក្សីជនរងគ្រោះជាកុមារ នៅពេលផ្តល់សក្ខីកម្ម" អាចរកបាននៅ www.childtherapytechniques.com

កុមារដែលរាងកាយរបស់ខ្លួនកំពុងប្រើប្រាស់យន្តការ “កាត់ផ្តាច់ទំនាក់ទំនង” អាចបង្ហាញនូវសញ្ញាមួយចំនួនដូចខាងក្រោមៈ

- ការដកដង្ហើមញាប់ ឬការដង្ហក់ក្នុងការដកដង្ហើម
- ហាក់ដូចជារងារ ឬធ្វើចលនារឹងទទឹង
- ភ្នែកសំឡឹងចុះឡើងពីម្ខាងទៅម្ខាង
- សំឡក់ធ្មឹង និងមិនឆ្លើយតបទៅនឹងទំនាក់ទំនងអ្វីឡើយ
- ឈប់និយាយ ឬហាក់ដូចជានិយាយមិនច្បាស់ ឬមិនឆ្លើយតប ។

● អារម្មណ៍មានសុវត្ថិភាពត្រូវបានចុះខ្សោយ-ដោយបានប៉ះពាល់ដ៏ធ្ងន់ធ្ងរឬគំរាមកំហែងរាំរ៉ៃ កុមារអាចសូម្បីតែ គិតថា បរិយាកាសដែលមានសុវត្ថិភាពគឺជាការគំរាមកំហែងផងដែរ ។

● ការពិបាកគ្រប់គ្រងអារម្មណ៍-ខួរក្បាលរបស់កុមារនៅតែ “មានភាពប្រុងប្រយ័ត្ន” ក្នុងការដោះស្រាយចំពោះការគំរាមកំហែង ហើយពួកគេអាចមានអារម្មណ៍ធុញថប់យ៉ាងងាយ និងខ្វះជំនាញក្នុងការរម្ងាប់អារម្មណ៍ខ្លួនឯងផងដែរ ។

● កង្វះទំនុកចិត្ត-បទពិសោធន៍របស់កុមារបានបង្រៀនគាត់ឬនាងមិនឱ្យទុកចិត្តបុគ្គលទាំងឡាយនៅជុំវិញពួកគេ-ប្រហែលជាសូម្បីតែបុគ្គលទាំងឡាយដែលជិតដិតបំផុតចំពោះពួកគេ ដូចជា សមាជិកគ្រួសាររបស់ពួកគេ បានក្បត់ទំនុកចិត្តរបស់ពួកគេ ។

● ការដំណើរការនៃព័ត៌មាន-ដោយសារការយឺតយ៉ាវនៃការវិវត្តមុខងារខួរក្បាលជាក់លាក់មួយចំនួន និងផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តដែលទាក់ទងខួរក្បាលកុមារអាចមានការលំបាកក្នុងការដំណើរការនៃព័ត៌មានថ្មីៗ ។

● បញ្ហាក្នុងការសម្តែងចេញនូវអារម្មណ៍ផ្ទាល់ខ្លួន-កុមារអាចមានការលំបាកក្នុងការពន្យល់ជាពាក្យសម្តីអំពីអ្វីដែលពួកគេមានអារម្មណ៍ ឬប្រាប់អ្នកអំពីបទពិសោធន៍របស់ពួកគេ ។

វាជាការសំខាន់ដែលត្រូវយល់ថា អ្វីដែលមើលទៅហាក់ដូចជាកុមារ “មានអាកប្បកិរិយាមិនសមរម្យ” តាមពិតគឺជាកុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត ។ ពួកគេចាំបាច់ត្រូវតែទទួលបាននូវការផ្តល់ប្រឹក្សានិងការគាំទ្រមិនមែនការស្តីបន្ទោសនោះទេ ។



## ការប៉ះទង្គិចផ្លូវចិត្តនៅក្នុងសាលសវនាការ

នៅក្នុងសាលសវនាការអ្នកអាចឃើញកុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត ប្រព្រឹត្តអាកប្បកិរិយាតាមរបៀបដែលមិនរំពឹងទុក ឬដែលធ្វើឱ្យពួកគេក្លាយជាសាក្សីដ៏ពិបាក ។

ឧទាហរណ៍ៈ

- ពួកគេមានយន្តការទប់ទល់តិចជាងអ្នកដទៃ ក្នុងការដោះស្រាយបញ្ហាដែលគំរាមកំហែងដល់ពួកគេ ឬដែលមិនសូវស្គាល់ (ដូចជា សាលសវនាការ) ដូច្នេះពួកគេអាចធ្វើសកម្មភាពយ៉ាងកម្រោល រំជួលចិត្ត កាត់ផ្តាច់ទំនាក់ទំនង ឬមិននិយាយ ។
- នៅពេលពួកគេត្រូវបានសួរនូវសំណួរ(ដូចជាសំណួរដែលសួរដោយចៅក្រមឬមេធាវីការពារជនជាប់ចោទ) ពួកគេប្រហែលជាមិនអាចយល់អំពីសំណួរ ពន្យល់ចម្លើយឱ្យបានច្បាស់លាស់ ឬចងចាំរឿងរ៉ាវបានប្រកបដោយភាពច្បាស់លាស់ ។
- ខួរកាលរបស់ពួកគេអាច "រាំងខ្ទប់" ការចងចាំជាក់លាក់មួយចំនួនដែលឈឺចាប់ខ្លាំងពេក ដើម្បីការពារខ្លួនឯង ។ នេះអាចមានន័យថាកុមារមិនអាចរំឭកភស្តុ-តាងរបស់ខ្លួនដែលគួរឱ្យទុកចិត្តបាននោះទេ ។
- ស្ថានភាពតានតឹងខ្លាំងអាចជំរុញឱ្យកុមារចងចាំអំពីហេតុការណ៍ប៉ះទង្គិចផ្លូវចិត្តហើយកុមារនឹងប្រព្រឹត្តអាកប្បកិរិយាប្រៀបដូចជារឿងរ៉ាវនោះកំពុងកើតឡើងវិញ ។ នៅពេលកុមារចូលរួមនៅក្នុងដំណើរការយុត្តិធម៌ គាត់ឬនាងនឹងត្រូវប្រឈមនឹងហេតុការណ៍ជាច្រើនដែលអាចជំរុញឱ្យមានការចងចាំនៃការប៉ះទង្គិចផ្លូវចិត្តៈការឃើញមន្ត្រីនគរបាល និងព្រះរាជអាជ្ញា ការតម្រូវឱ្យចងចាំ និងនិយាយអំពីហេតុការណ៍ប៉ះទង្គិចផ្លូវចិត្ត ការឃើញចុងចោទ ។

## គោលការណ៍ណែនាំសម្រាប់ការដោះស្រាយជាមួយកុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត

**ប្រការដែលគួរធ្វើ**

- ណែនាំខ្លួនអ្នក និងតួនាទីរបស់អ្នក ។
- ស្លៀកពាក់ឱ្យបានសមស្រប ដើម្បីធ្វើឱ្យកុមារមានអារម្មណ៍មានសុវត្ថិភាព និងផាសុខភាព ។
- ប្រសិនបើអាច រៀបចំជំនួបនៅកន្លែងដែលធ្វើឱ្យកុមារមានអារម្មណ៍មានផាសុខភាព ស្ងប់ស្ងាត់ និងមានសុវត្ថិភាព-ឧទាហរណ៍ កន្លែងដែលមានគ្រឿងសង្ហារិមទន់ល្មើយ ប្រដាប់ប្រដាក្មេងលេង ។
- មានភាពអត់ធ្មត់ ។ ចំណាយពេលកសាងទំនាក់ទំនងជាមួយកុមារ ។
- និយាយអំពីប្រធានបទដែលមានសុវត្ថិភាព អព្យាក្រឹតឬសប្បាយៗមុនពេលអ្នកដោះស្រាយបញ្ហាប៉ះទង្គិចផ្លូវចិត្ត ។ ឧទាហរណ៍ ៖ និយាយអំពីសកម្មភាពនៅសាលារៀនកាលពីពេលថ្មីៗ ។

- ផ្តល់ដល់កុមារនូវការយកចិត្តទុកដាក់ពេញលេញ
  - បិទទូរសព្ទចល័តរបស់អ្នក
  - ជួបនៅក្នុងបន្ទប់មួយដែលមិនមានការធ្វើឱ្យបែកអារម្មណ៍ផ្សេងទៀត
- យល់ដឹងអំពីទំនាក់ទំនងដែលមិនមែនជាពាក្យសម្តីរបស់អ្នកជាមួយកុមារ
  - ប្រើប្រាស់សំឡេងរួសរាយស្រទន់
  - អង្គុយនៅកម្រិតស្មើនឹងកុមារ ប៉ុន្តែមិននៅជិតពេកទេ
  - ទំនាក់ទំនងដោយក្រសែភ្នែក ប៉ុន្តែមិនត្រូវសំឡក់ទេ
  - បង្កើតភាពស្ងៀមស្ងាត់ ដើម្បីឱ្យកុមារមានអារម្មណ៍ហាក់ដូចជាពួកគេអាចបន្តនិយាយឱ្យបានច្រើនតាមដែលពួកគេត្រូវការ
  - បង្ហាញការអាណិតអាសូរនៅក្នុងសកម្មភាពរបស់អ្នក ប៉ុន្តែមិនត្រូវឱប ឬប៉ះពាល់កុមារទេ លុះត្រាតែគាត់ ឬនាងចាប់ផ្តើមមុន។
- ដោះស្រាយអាកប្បកិរិយារបស់កុមារដែលជាអាការៈនៃការប៉ះទង្គិចផ្លូវចិត្ត
  - កុំស្តីបន្ទោសកុមារចំពោះ“សកម្មភាពដែលពួកគេសម្តែងចេញមិនសមរម្យ” ប៉ុន្តែផ្ទុយទៅវិញ ត្រូវពិភាក្សាជាមួយពួកគេថាតើអ្វីកំពុងធ្វើឱ្យពួកគេខឹង/ក្រៀមក្រំ/អន្ទះអន្ទែង។
- ចូលរួមនៅក្នុង“ការស្តាប់យ៉ាងយកចិត្តទុកដាក់”
  - ឱ្យកុមារដឹងថាអ្នកកំពុងស្តាប់អ្វីដែលពួកគេកំពុងប្រាប់អ្នកដោយងក់ក្បាល និយាយអ្វីមួយដូចជា:
  - ខ្ញុំយល់។
  - ខ្ញុំរីករាយដែលអ្នកបានប្រាប់ខ្ញុំ។
  - វាមិនមែនជាកំហុសរបស់អ្នកទេ។
  - ខ្ញុំនឹងជួយអ្នក។
  - អរគុណអ្នកដែលបានប្រាប់ខ្ញុំ។
- ធ្វើការសម្រាកឱ្យបានញឹកញាប់ ដើម្បីកុំឱ្យកុមារធុញថប់។
- មានភាពស្មោះត្រង់-ប្រាប់កុមារអំពីហានិភ័យ និងបញ្ហាប្រឈមដែលអាចកើតឡើង។
- ប្រាប់ពួកគេឱ្យដឹងថា អ្នកនៅទីនោះដើម្បីស្តាប់ និងជួយពួកគេ។
- ផ្តល់ឱ្យកុមារនូវជម្រើសជាច្រើនតាមដែលអ្នកអាច ដើម្បីអនុញ្ញាតឱ្យកុមារមានអារម្មណ៍អាចគ្រប់គ្រង លើជីវិតរបស់ពួកគេបានខ្លះ។
  - ឧទាហរណ៍: តើទឹកផ្លែឈើប្រភេទណាដែលពួកគេចង់ញ៉ាំ? តើពួកគេចង់កាន់ប្រដាប់ប្រដាក្មេងលេង ខណៈពេលពួកគេនិយាយជាមួយអ្នកឬទេ? តើមួយណា?
- អរគុណកុមារដែលបានចែករំលែកជាមួយអ្នកនៅពេលបញ្ចប់ជំនួបនីមួយៗ។

**ប្រការដែលមិនគួរធ្វើ**

- កុំធ្វើការសន្យានូវអ្វីដែលអ្នកមិនអាចរក្សាទុកបាន ។
  - ឧទាហរណ៍ៈ កុំសន្យាថា ជនជាប់ចោទនឹងជាប់ពន្ធនាគារ និងកុំសន្យាថាអ្នកនឹងមិនប្រាប់អ្នកណាម្នាក់ផ្សេងទៀតអំពីអ្វីដែលពួកគេប្រាប់អ្នកឡើយ ។
- កុំបង្ខំកុមារឱ្យនិយាយ ប្រសិនបើពួកគេមិនចង់ ។
  - ប្រសិនបើកុមារមិនមានអារម្មណ៍រួចរាល់ក្នុងការនិយាយចេញនូវបញ្ហាមួយចំនួន ចូរនិយាយអំពីអ្វីផ្សេងទៀត និងគ្រោងជំនួបមួយផ្សេងទៀតសម្រាប់ថ្ងៃមួយទៀត ។
  - ចាប់ផ្តើមជាមួយសំណួរងាយៗ និងបន្តទៅសំណួរកាន់តែពិបាកក្នុងពេលដែលកុមារត្រៀមខ្លួនរួចរាល់ប៉ុណ្ណោះ ។
- កុំកាត់ផ្តាច់ការសន្ទនារបស់កុមារ ប្រសិនបើពួកគេចង់ប្រាប់អ្នកនូវអ្វីមួយ ។
- កុំនិយាយអ្វីដែលបង្ហើបថា កុមារមានកំហុសថា អ្នកមិនជឿកុមារឬថា អ្នកកំពុងវិនិច្ឆ័យកុមារដូចជាៈ
  - ហេតុអ្វីបានជាអ្នកមិនប្រាប់អ្នកណាម្នាក់ពីមុនមក?
  - ខ្ញុំមិនអាចជឿរឿងនេះបានទេ !
  - តើអ្នកប្រាកដថា នេះជាការណ៍ពិតឬ?
  - តើអ្នកបានធ្វើអ្វីដល់ពួកគេមុន?
- កុំប្រើអារម្មណ៍-បង្ហាញនូវសណ្តានចិត្តក្នុងការឆ្លើយតបទៅនឹងអ្វីដែលកុមារប្រាប់អ្នក ប៉ុន្តែស្ងប់អារម្មណ៍ និងគ្រប់គ្រងអារម្មណ៍ ។

កុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តដែលមិនទទួលបានការគាំទ្រត្រឹមត្រូវទំនងជាមិនអាចធ្វើជាសាក្សីដ៏ល្អបានទេ ។ ដូច្នេះហើយបានជាយុទ្ធសាស្ត្រដែលត្រូវបានរៀបចំឡើងយ៉ាងល្អមួយដើម្បីគាំទ្រសាក្សីជាកុមារដែលមានសារៈសំខាន់យ៉ាងខ្លាំង ។ អានបន្តដើម្បីយល់ដឹងអំពីរបៀបដែលអ្នកអាចជួយកុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្តក្នុងការត្រៀមខ្លួនសម្រាប់តុលាការ ។







# ការប្រមូលភស្តុតាង
## ពីកុមារដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត



### ការប្រមូលភស្តុតាងពីកុមារដែលទទួលរង ការប៉ះទង្គិចផ្លូវចិត្ត

ដោយសារកុមារយល់ និងការប្រាស្រ័យទាក់ទងព្រឹត្តិការណ៍នានាដែលបានកើតឡើងចំពោះ ពួកគេតាមរបៀបផ្សេងពីមនុស្សពេញវ័យ ត្រូវយកចិត្តទុកដាក់ជាពិសេសនៅក្នុងរបៀបដែលអ្នកសម្ភាសន៍កុមារដើម្បីប្រមូលភស្តុតាងដែលជាសក្ខីកម្ម ។

ចូរចងចាំថាកុមារមានលក្ខណៈខុសពីមនុស្សពេញវ័យ ហើយពួកគេត្រូវការរបៀបផ្សេងនៃការសួរ ដើម្បីឱ្យអ្នកអាចប្រមូលភស្តុតាងត្រឹមត្រូវ និងពេញលេញបំផុត ។

ចាប់ផ្តើម "មុនពេលធ្វើការសម្ភាសន៍" ។ វាជាការសន្ទនាមួយដែលមិនគំរាមកំហែង មុនពេលការសម្ភាសន៍ចាប់ផ្តើម ។ វាត្រូវការពេលវេលាតែពីរបីនាទីប៉ុណ្ណោះ ។

### ជំហាននានាសម្រាប់ការសម្ភាសន៍

1. ជ្រើសរើសប្រធានបទវិជ្ជមាន-ឧទាហរណ៍ មុខវិជ្ជាដែលកុមារចូលចិត្តបំផុតនៅសាលារៀន ។

ឧទាហរណ៍: "ប្រាប់ខ្ញុំអំពីអ្វីដែលអ្នកចូលចិត្តធ្វើនៅសាលារៀន "

2. បន្តដោយសំណួរ "ប្រាប់ខ្ញុំបន្ថែមទៀត " បន្ថែមទៀត ។

ឧទាហរណ៍: "ប្រាប់ខ្ញុំបន្ថែមទៀតអំពីមូលហេតុដែលអ្នកចូលចិត្តគូររូប "

3. បន្ទាប់មកជ្រើសរើសព្រឹត្តិការណ៍ធម្មតាមួយ-ឧទាហរណ៍សកម្មភាពកាលពីពេលថ្មីៗនៅសាលារៀន ។

ឧទាហរណ៍: "ខ្ញុំដឹងថា អ្នកលេងបាល់ទាត់នៅសាលារៀនរៀងរាល់ថ្ងៃពុធ " ។

4. សាកល្បងសំណួរលម្អិត រួមទាំងសំណួរតាមលំដាប់លំដោយ ។

ឧទាហរណ៍:

" តើអ្វីកើតឡើងបន្ទាប់? "

"តើអ្នកលេងអស់រយៈពេលប៉ុន្មាន? "



## ប្រការដែលត្រូវធ្វើ មុនអ្នកចាប់ផ្តើមសួរសំណួរ

1. ពន្យល់វិធានជាមូលដ្ឋាន

● ពន្យល់កុមារថា នៅពេលពួកគេកំពុងឆ្លើយសំណួរៈ

i. ប្រការសំខាន់បំផុតគឺប្រាប់ការពិត ។

ii. វាមិនអីទេដែលនិយាយថា "ខ្ញុំមិនដឹង" ។ អ្នកមិនគួរឆ្លើយនូវចម្លើយស្មានៗ ចំពោះសំណួរណាមួយឡើយ ។

iii. វាមិនអីទេដែលនិយាយថា "ខ្ញុំមិនយល់ " ប្រសិនបើអ្នកមិនយល់សំណួរណាមួយ ។

iv. ប្រសិនបើអ្នកមិនយល់ស្របនឹងអ្វីមួយដែលខ្ញុំនិយាយ អ្នកគួរនិយាយដូច្នោះ ។

v. សូមឱ្យខ្ញុំដឹងថាពេលណាដែលអ្នកអស់កម្លាំង ហើយអ្នកត្រូវការសម្រាកមួយសន្ទុះ ។

2. និយាយយឺតៗ និងផ្តល់ឱ្យកុមារនូវឱកាសក្នុងការឆ្លើយ

● កុំនិយាយកាត់ចម្លើយរបស់កុមារ ។

● ផ្អាកក្នុងការសួរសំណួរនិងចម្លើយដើម្បីអនុញ្ញាតឱ្យកុមារនិយាយពីដំណើរការនៃការផ្តល់ពត៌មាន ។

3. ពន្យល់មូលហេតុដែលអ្នកចាំបាច់ត្រូវសួរពួកគេនូវសំណួរនានា ជាពិសេសអំពីប្រធានបទដែលពួកគេអាចមានអារម្មណ៍មិនសូវស្រួលក្នុងការនិយាយ ។

ឧទាហរណ៍ៈ

"ខ្ញុំចាំបាច់ត្រូវសួរអ្នកនូវសំណួរមួយចំនួនអំពីអ្វីដែលបានកើតឡើងនៅថ្ងៃនោះ ។ ខ្ញុំកំពុងព្យាយាមស្វែងយល់អ្វីៗទាំងអស់ដែលបានកើតឡើងដើម្បីឱ្យខ្ញុំអាចជួយអ្នកប្រាប់រឿងរ៉ាវនៅក្នុងតុលាការ ។ រឿងរ៉ាវខ្លះដែលខ្ញុំចាំបាច់ត្រូវសួរអ្នកអាចធ្វើឱ្យអ្នកមានអារម្មណ៍មិនសប្បាយចិត្ត ។ ចូរពន្យល់តាមសម្រួលនូវរឿងរ៉ាវទាំងនេះចំពោះខ្ញុំ ។ ខ្ញុំនៅទីនេះដើម្បីជួយអ្នក ។"



## ប្រភេទនៃសំណួរដែលត្រូវសួរ

1. រៀបចំរចនាសម្ព័ន្ធនៃការសម្ភាសន៍ និងដាក់សញ្ញាសម្គាល់លើប្រធានបទ

● កុំលាយបញ្ចូលគ្នានូវប្រធានបទ ឬផ្លាស់ប្តូរទៅមករវាងប្រធានបទផ្សេងៗ

● អនុញ្ញាតឱ្យកុមារដឹងថាពេលណាអ្នកនឹងផ្លាស់ប្តូរប្រធានបទ។

ឧទាហរណ៍:

"ពេលនេះ ខ្ញុំនឹងសួរអ្នកអំពី..."

2. ចាប់ផ្តើមជាមួយ សំណួរបើក ដែលលើកទឹកចិត្តកុមារឱ្យប្រាប់រឿងរ៉ាវរបស់ពួកគេដោយមិនមានការនិយាយកាត់។

ឧទាហរណ៍:

"ប្រាប់ខ្ញុំអំពី..."

"តើអ្វីបានកើតឡើងបន្ទាប់"។ បន្ទាប់មកអ្នកអាចបន្តទៅសំណួរបិទដើម្បីទទួលបាននូវព័ត៌មានកាន់តែលម្អិត ។

ឧទាហរណ៍:

"តើមានមនុស្សណាម្នាក់នៅក្បែរអ្នកឬទេ នៅពេលដែលរឿងនេះបានកើតឡើង?"

3. ប្រើប្រាស់ពាក្យសាមញ្ញ ទូទៅ និងឃ្លាខ្លីៗ។

4. បញ្ជាក់ឈ្មោះ និងទីកន្លែងឡើងវិញជាញឹកញាប់

● "តើ XX បាននិយាយអ្វីខ្លះ?" មិនមែន "តើគាត់បាននិយាយអ្វីខ្លះ?" នោះទេ។

● "តើមានមនុស្សច្រើននៅក្នុងផ្ទះរបស់អ្នកឬទេ?" មិនមែន "តើមានមនុស្សច្រើននៅទីនោះឬទេ?" នោះទេ។

5. សួរគំនិតខ្លីមួយក្នុងមួយលើក

● សួរ: "តើអ្នកបាននិយាយទៅកាន់xx នៅថ្ងៃនោះឬទេ?" "តើអ្វីដែលអ្នកបាននិយាយទៅកាន់គាត់?"

● កុំសួរ: "តើអ្នកចាំថាបាននិយាយទៅកាន់ XX នៅថ្ងៃនោះឬទេ? ប្រសិនបើដូច្នេះ តើអ្នកបាននិយាយអ្វីខ្លះ?"

6. ពិនិត្យមើលការយល់ដឹងរបស់កុមារ

● កុំពឹងផ្អែកលើកុមារប្រាប់អ្នក ប្រសិនបើពួកគេមិនយល់ទេនោះ។

● កុមារអាចយល់ខុសនូវពាក្យ ដូចជា "តែងតែ/ មិនដែល" "មុនពេល/ ក្រោយពេល" និង "ច្រើនជាង / តិចជាង"។

● បំភ្លឺអត្ថន័យដោយសួរសំណួរបើក:

ឧទាហរណ៍:

"ប្រាប់ខ្ញុំបន្ថែមទៀតអំពីរឿង នោះ"

"តើអ្នកចង់មានន័យដូចម្តេច នៅពេលអ្នកនិយាយ?"

7. ពន្យល់មូលហេតុដែលអ្នកចាំបាច់ត្រូវបញ្ជាក់ពីអត្ថន័យឬសួរសំណួរឡើងវិញ ។

● កុំគ្រាន់តែសួរសំណួរឡើងវិញ ប្រសិនបើអ្នកគិតថាកុមារមិនយល់ ។ ពន្យល់មូលហេតុដែលអ្នកត្រូវការព័ត៌មានបន្ថែម ។

● ឧទាហរណ៍:

សំណួរ: "តើអ្នកនៅតែម្នាក់ឯងជាមួយពូ / អ៊ុំប្រុសរបស់អ្នកនៅក្នុងផ្ទះរបស់អ្នកឬ?"

ចម្លើយ: "ទេ" ។

សំណួរ:"ខ្ញុំចង់ពិនិត្យថាតើមានអ្នកណាម្នាក់ផ្សេងទៀតនៅជាមួយអ្នកនៅពេលពូ / អ៊ុំប្រុសរបស់អ្នក កំពុងវាយអ្នកឬទេ ។ តើមានអ្នកណាម្នាក់ផ្សេងទៀតនៅទីនោះជាមួយអ្នក និងពូ / អ៊ុំប្រុសរបស់អ្នកដែរ ឬទេ នៅពេលគាត់វាយអ្នក?"

ចម្លើយ: "ទេ មិនមានអ្នកណាម្នាក់ឡើយ ។ បងប្អូនប្រុសរបស់ខ្ញុំនៅឯវាលខាងក្រៅ ។"

8. ប្រើវិធីជំនួយផ្សេងៗគ្នាដើម្បីជួយកុមារឱ្យប្រាប់រឿងរ៉ាវ ប្រសិនបើចាំបាច់ ។

● នៅពេលនិយាយអំពីឧប្បត្តិហេតុឬការប៉ះពាល់ផ្លូវភេទ កុំឱ្យកុមារចង្អុលទៅផ្នែកនានានៃរាងកាយផ្ទាល់របស់ពួកគេដើម្បីបង្ហាញអ្វីដែលបានកើតឡើងឱ្យសោះ ។

● ពិចារណាប្រើប្រាស់ដ្យាក្រាម និងសំណួរបើកប៉ុណ្ណោះ ។

ឧទាហរណ៍: "អ្នកបាននិយាយថាគាត់បានប៉ះពាល់អ្នក ។ តើអ្នកអាចបង្ហាញខ្ញុំលើគំនូរនេះអំពីកន្លែងដែលគាត់បានប៉ះពាល់អ្នកឬទេ?"



## ប្រភេទនៃសំណួរដែលត្រូវជៀសវាង

1. សំណួរដែលធ្វើឱ្យយល់ច្រឡំ

- សំណួរដែលមានគោលបំណងពីរ ។ សំណួរតែមួយប៉ុណ្ណោះ គួរត្រូវបានសួរក្នុងមួយលើក ដើម្បីឱ្យកុមារអាចយល់ថា តើសំណួរណាមួយដែលគាត់ ឬនាងនឹងឆ្លើយ ។

សំណួរៈ “តើអ្នកបានឃើញបុរសនោះលើកដំបូងនៅពេលណា និងកន្លែងណា?”

- សំណួរដឹកមុខ

សំណួរ : “អ្នកបានអញ្ជើញគាត់ចូលក្នុងមែនទេ?” អ្នកចង់ឱ្យគាត់ចូលមកមើលអ្នកនៅល្ងាចនោះមែនទេ?

- សំណួរអវិជ្ជមាន

សំណួរៈ វាជាការណ៍ពិត តើវាមិនមែន ដែលអ្នកមិនបាន....?

សំណួរៈ តើអ្នកមិនជំទាស់នឹងរឿងនោះទេឬ?

សំណួរៈ តើអ្នកកំពុងនិយាយថា គ្មានអ្វីមួយនៃរឿងនោះបានកើតឡើងមែនទេ?

- សំណួរពិបាកផ្នែកទស្សនាទាន (អាស្រ័យលើអាយុរបស់កុមារ)

សំណួរៈ តើគាត់បានប៉ះពាល់អ្នកអស់រយៈពេលប៉ុន្មាន?

2. សំណួរដែលមានវាក្យសព្ទពិបាក ឬបច្ចេកសព្ទផ្នែកច្បាប់

សំណួរៈ តើអ្នកបានផ្តល់ភស្តុតាងមុននេះអំពី..... ដែរឬទេ?

3. ជាពិសេសជាមួយកុមារតូចៗឬកុមារដែលមានជំនាញយល់ដឹងខ្សោយ សំណួរដែលប្រៀបធៀបរយៈពេល ឬចំនួន ។

សំណួរៈ “តើវាបានកើតឡើងកាលពីបីខែមុន ឬបួនខែមុនមែនទេ?”

សំណួរៈ “តើវាបានកើតឡើងប៉ុន្មានដង?” ប្រាំដង? ដប់ដង?

4. សំណួរមិនច្បាស់លាស់

សំណួរៈ ក្រោយពីសួរអំពីបងប្អូនប្រុស និងពូ/អ៊ុំប្រុសរបស់កុមារៈ “តើគាត់នៅក្នុងបន្ទប់ឬ?”(អ្នកណា? បងប្អូនប្រុស ឬឪពុក?)

5. សំណួរដែលមាន “កន្ទុយ”

- សំណួរដែលមាន “កន្ទុយ” គឺជាសំណួរដែលអំណះអំណាងត្រូវបានធ្វើឡើងហើយបន្ទាប់មកសំណួរខ្លីមួយដែលបញ្ជាក់អំណះអំណាងនោះត្រូវបានបន្ថែមនៅចុងបញ្ចប់ :

- កុំសួរៈ “អ្នកបានស្នាក់នៅផ្ទះនៅថ្ងៃនោះ មែនទេ?”
- ជាជំនួសវិញ សួរ “តើអ្នកបានស្នាក់នៅផ្ទះនោះនៅថ្ងៃនោះឬទេ?”

6. សំណួរជម្រើសដែលមានកំហិត

● សំណួរជម្រើសដែលមានកំហិតផ្តល់ឱ្យកុមារនូវជម្រើសមួយរវាងចម្លើយផ្សេងៗដែលបានបានផ្តល់ឱ្យរួចទៅហើយដល់កុមារប៉ុណ្ណោះ ។

● កុំសួរៈ "នៅពេលដែលគាត់វាយអ្នក តើអ្នកស្រែក ឬយំ "

● ជាជំនួសវិញនូវសំណួរ "តើអ្នកបានធ្វើអ្វី នៅពេលដែលគាត់វាយអ្នក?"

7. សំណួរវិនិច្ឆ័យ

● កុំសួរសំណួរដែលបង្កប់ន័យមិនឯកភាពអំពីសកម្មភាព ឬជម្រើសរបស់កុមារ ។ នេះ នឹងបង្អាក់ទឹកចិត្តពួកគេមិនឱ្យប្រាប់នូវការណ៍ពិត ។

● កុំសួរៈ"ប្រសិនបើអ្នកភ័យខ្លាចខ្លាំងហេតុអ្វីបានជាអ្នកមិនប្រាប់អ្នកណាម្នាក់ភ្លាមៗបន្ទាប់ពីនោះ?"

● ជាជំនួសវិញនូវសំណួរៈ "តើអ្នកបានធ្វើបន្ទាប់ពីនោះមក?" "តើអ្នកមានអារម្មណ៍ដូចម្តេចនៅពេលក្រោយមក?" "តើអ្នកបានប្រាប់អ្នកណាម្នាក់អំពីអ្វីដែលបានកើតឡើងចំពោះអ្នកឬទេ?" "តើអ្នកអាចប្រាប់ខ្ញុំបានទេថាតើហេតុអ្វីបានជាអ្នកមិនបាន?"

8. សំណួរដែលសួរកុមារឱ្យស្មានអំពីបំណងរបស់មនុស្ស

● កុមារមិនអាចកំណត់អំពីបំណងរបស់មនុស្សផ្សេងទៀតបានទេ ទោះជាបំណងនោះអាចមានភាពច្បាស់លាស់ប៉ុណ្ណាក៏ដោយ ។

ឧទាហរណ៍ៈកុំសួរៈ "ហេតុអ្វីបានជាអ្នកគិតថាគាត់នឹងធ្វើរឿងនេះ?"

9. សំណួរដែលទាមទារនូវការយល់ដឹងអំពីពេលវេលាឬភាពញឹកញាប់(សម្រាប់កុមារតូច)

● សូម្បីកុមារដែលអាចរាប់លេខបាន ក៏ប្រហែលជាមិនយល់ចំនួន ឬគំនិតនៃភាពញឹកញាប់ និងលំដាប់លំដោយព្រឹត្តិការណ៍បានដែរ ។

● ផ្តល់នូវចំណុចបញ្ជាក់ច្បាស់លាស់ ដោយប្រើពេលវេលា ឬហេតុការណ៍ដែលពាក់ព័ន្ធនឹងកុមារ ។

ឧទាហរណ៍ៈ

សួរៈ "តើរឿងនេះបានកើតឡើងមុនពេល ឬក្រោយពេលអ្នកត្រឡប់ពីសាលារៀនមកផ្ទះ?"

កុំសួរៈ "តើរឿងនេះបានកើតឡើងនៅពេលណា?"

10. ជៀសវាងសរសើរចម្លើយជាក់លាក់ណាមួយ

● ការធ្វើបែបនេះ ផ្តល់ឱ្យកុមារនូវតម្រុយអំពីថាតើចម្លើយណាខ្លះ "មានប្រយោជន៍" ។ កុមារជាទូទៅចង់ធ្វើឱ្យមនុស្សពេញវ័យសប្បាយចិត្ត និងដោយហេតុនេះពួកគេអាចផ្តល់នូវចម្លើយ "មានប្រយោជន៍" ដោយមិនគិតអំពីថាតើចម្លើយនោះពិតឬអត់នោះទេ ។



# **ការត្រៀមខ្លួន**កុមារ
# ដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត
# សម្រាប់**តុលាការ**_សម្រាប់**មេធាវី**



## ការត្រៀមខ្លួនមុនចូលតុលាការ

ជួយកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តនៃការចូលរួមនៅក្នុងតុលាការ និងធ្វើឱ្យការផ្តល់សក្ខីកម្មមានភាពកាន់តែប្រសើរ ។ ផ្នែកខ្លះនៃកម្មវិធីត្រៀមខ្លួនមុនចូលតុលាការ នឹងត្រូវអនុវត្តដោយអ្នកគាំទ្រ មិនមែនផ្នែកច្បាប់ និងផ្នែកផ្សេងទៀតដោយមេធាវី ។

ជំហានទាំងឡាយខាងក្រោមគួរត្រូវបានអនុវត្តតាមដោយមេធាវី ។

### ជំហានទីមួយៈ ការត្រៀមខ្លួនកុមារដើម្បីឆ្លើយសំណួរនៅក្នុងតុលាការ

ការត្រៀមខ្លួនកុមារដើម្បីឆ្លើយសំណួរនៅក្នុងតុលាការពាក់ព័ន្ធនឹងផ្នែកចំនួនពីរៈ

1. ការជួយកុមារដើម្បីអភិវឌ្ឍន៍ជំនាញឆ្លើយសំណួរ-ការយល់នូវភាពខុសគ្នារវាងត្រូវនិងខុស ពេលណា និងរបៀបស្នើសុំការស្រាយបំភ្លឺ ពេលណា និងរបៀបបដិសេធមិនឆ្លើយសំណួរ ។

2. ការត្រៀមខ្លួនកុមារទាក់ទងនឹងភស្តុតាងជាក់លាក់របស់គាត់ឬនាង-ការរំឭកកុមារអំពីអង្គហេតុនៅក្នុងភស្តុតាង និងការត្រៀមខ្លួនគាត់ឬនាងឱ្យឆ្លើយតបយ៉ាងត្រឹមត្រូវទៅនឹងប្រភេទសំណួរដែលអាចមាន ដែលកុមារអាចប្រឈមពីសំណាក់ចៅក្រមព្រះរាជអាជ្ញា ឬមេធាវីការពារជនជាប់ចោទ ។

### ការបង្រៀនកុមារអំពីបច្ចេកទេសឆ្លើយសំណួរ

បំពាក់បំប៉នកុមារឱ្យយល់ដឹងអំពីរបៀបឆ្លើយសំណួរឱ្យបានត្រឹមត្រូវពិតប្រាកដ និងរបៀបឆ្លើយតបទៅនឹងសំណួរដែលពួកគេមិនដឹងចម្លើយ ឬដែលពួកគេមិនយល់នឹងសំណួរដឹកមុខ ។

វាជាការសំខាន់ដែលអ្នកប្រាប់ពួកគេដោយស្មោះត្រង់ថា ពួកគេអាចប្រឈមនឹងសំណួរពិបាកឬសំណួរដែលធ្វើឱ្យមានការភាន់ច្រឡំ ។ មេធាវីការពារជនជាប់ចោទ ឬចៅក្រមអាចនិយាយទៅកាន់ពួកគេដោយសំឡេងគ្រោតគ្រាត ។ កុមារគួរយល់ថា ប្រការទាំងនេះអាចកើតឡើង ប៉ុន្តែពួកគេអាចមានជំនាញដើម្បីដោះស្រាយបញ្ហាទាំងនេះ ។

### ប្រការដែលត្រូវពន្យល់កុមារអំពីការឆ្លើយសំណួរនៅក្នុងតុលាការ

ក. អ្នកអាចត្រូវបានសួរនូវសំណួរពិបាក និងពេលខ្លះសំណួរធ្វើឱ្យភាន់ច្រឡំនៅក្នុងតុលាការ ។ ចូរកុំខ្លាច ។ គ្រាន់តែឈប់បន្តិច រួចគិតយ៉ាងប្រុងប្រយ័ត្នអំពីសំណួរ ។ ប្រសិនបើអ្នកយល់សំណួរ គ្រាន់តែឆ្លើយឱ្យបានច្បាស់តាមអ្វីដែលអ្នកអាចធ្វើបាន ។

ខ. កុំស្មានចម្លើយចំពោះសំណួរ ។ ប្រសិនបើអ្នកមិនដឹងចម្លើយចំពោះសំណួរណាមួយ ។ ចម្លើយដែលត្រឹមត្រូវ គឺ "ខ្ញុំមិនដឹង" ។ វាមិនអីទេដែលមិនដឹងនូវចម្លើយចំពោះសំណួរណាមួយ ។ អ្នកមិនគួរស្មានឡើយ ។

គ. ពេលខ្លះសំណួរអាចត្រូវបានសួរតាមរបៀបមួយដែលធ្វើឱ្យភាន់ច្រឡំ ។ ប្រសិនបើអ្នកមិនយល់នូវសំណួរ អ្នកគ្រាន់តែអាចនិយាយថា "ខ្ញុំមិនយល់សំណួរទេ ។ តើអ្នកអាចសួរសំណួរតាមរបៀបផ្សេងមួយទៀតឬទេ?"

ឃ. ប្រសិនបើអ្នកមិនយល់ស្របទៅនឹងអ្វីមួយត្រូវនិយាយថា "មិនយល់ស្រប" ។ ពេលខ្លះអ្នកណាម្នាក់អាចសួរអ្នកនូវសំណួរតាមរបៀបមួយដែលហាក់ដូចជាអ្នកគួរនិយាយថា "បាទ/ចាស" ។ សូមគិតដោយប្រុងប្រយ័ត្នមុនពេលអ្នកឆ្លើយ ហើយវាជាការសំខាន់ដែលត្រូវនិយាយ ប្រសិនបើអ្នកមិនយល់ស្រប ។

ង. ប្រសិនបើអ្នកមានអ្វីមួយដែលអ្នកចង់បន្ថែមចំពោះចម្លើយរបស់អ្នក ទោះបីជាសំណួរ គឺ ជាសំណួរ "បាទ/ចាស" ឬ "ទេ" ក៏ដោយអ្នកគួរតែបន្ថែមអ្វីដែលអ្នកចង់និយាយ ។ វាជាការសំខាន់ដែលចៅក្រមមានព័ត៌មានទាំងអស់ ។

ច. អ្នកអាចត្រូវបានសួរនូវរឿងរ៉ាវដែលអ្នកមានភាពអៀនខ្មាសក្នុងការនិយាយ ។ កុំបារម្ភ ចៅក្រមបានឮរឿងរ៉ាវជាច្រើនពីមុនមកពីកុមារជាច្រើន ហើយអ្នកមិនមានអ្វីមួយដែលត្រូវអៀនខ្មាសឡើយ ។ គ្រាន់តែដកដង្ហើមឱ្យវែង ហើយនិយាយនូវអ្វីដែលអ្នកចង់និយាយយ៉ាងយឺតៗ ។

ឆ. អាកប្បកិរិយារបស់មេធាវីការពារជនជាប់ចោទអាចមានលក្ខណៈគ្រោតគ្រាត-ឧទាហរណ៍ ពួកគេអាចសូម្បីតែសើច ឬព្យាយាមកាត់ចម្លើយរបស់អ្នក ។ កុំបារម្ភអំពីរឿងនេះ ។ អ្នកមិនស្ថិតនៅក្នុងបញ្ហាឡើយ ។ អ្នកនៅទីនោះ ពីព្រោះចៅក្រមចង់ឮរឿងរ៉ាវពីអ្នក ។

ជ. និយាយឱ្យឮ ក្នុងសំឡេងច្បាស់-អ្នករាល់គ្នានៅក្នុងតុលាការចង់ឮនូវអ្វីដែលអ្នកត្រូវនិយាយ ។ អ្នកគឺជាបុគ្គលសំខាន់ខ្លាំងនៅក្នុងតុលាការ៖ និយាយឱ្យឮក្នុងសំឡេងច្បាស់ ។

ឈ. ប្រសិនបើអ្នកត្រូវការសម្រាក គ្រាន់តែនិយាយថា អ្នកត្រូវការសម្រាក-ប្រសិនបើអ្នកមានអារម្មណ៍អស់កម្លាំង ឬប្រសិនបើអ្នកមានអារម្មណ៍ពិបាកចិត្តពេករហូតមិនអាចឆ្លើយសំណួរបាន ហើយអ្នកត្រូវការសម្រាកមុនពេលអ្នកបន្ត គ្រាន់តែអនុញ្ញាតឱ្យចៅក្រមដឹងថា អ្នកត្រូវការសម្រាក ។

ញ. អ្នកមិនត្រូវបានអនុញ្ញាតឱ្យស្នើសុំអ្នកណាម្នាក់ផ្សេងដើម្បីជួយអ្នកឆ្លើយសំណួរឡើយ-ចៅក្រមចង់ស្តាប់អ្វីដែលអ្នកត្រូវនិយាយ ។អ្នកមិនត្រូវបានអនុញ្ញាតឱ្យស្នើសុំអ្នកណាម្នាក់ផ្សេងទៀត (ដូចជា ម្តាយ ឬឪពុករបស់អ្នក) ដើម្បីឆ្លើយសំណួរជំនួសអ្នកឡើយ ។

ការត្រៀមខ្លួនកុមារដើម្បីផ្តល់សក្ខីកម្មនៅក្នុងតុលាការ

● ធ្វើការបញ្ជាក់ជាមួយកុមារអំពីសារៈសំខាន់នៃការប្រាប់ការណ៍ពិតអំពីអ្វីដែលបានកើតឡើង ។

● រំឭក នៅក្នុងចិត្តរបស់កុមារអំពីអ្វីដែលកុមារចងចាំអំពីអង្គហេតុនៃករណីៈ

- ឱ្យកុមារគិតឡើងវិញនូវអ្វីដែលពួកគេនឹកឃើញអំពីហេតុការណ៍-អនុញ្ញាតឱ្យកុមារនិយាយដោយសេរី ។

- សួរកុមារអំពីសេចក្តីលម្អិតជាក់លាក់ដែលមានសារៈសំខាន់ ។

- ក្រោយពីអ្នកបានឮរបៀបដែលកុមារប្រាប់រឿងរ៉ាវរួច អ្នកអាចស្នើឱ្យមានការពន្យល់លម្អិត ឬការផ្លាស់ប្តូរ (ឧទាហរណ៍ ដើម្បីកែលម្អភាពត្រឹមត្រូវ ឬស្រាយបំភ្លឺ) ។

- ប្រសិនបើមានផ្នែកណាមួយនៃការនឹកឃើញរបស់កុមារដែលផ្ទុយពីភស្តុតាងដែលគាត់ ឬនាងបានផ្តល់ពីមុន សូមស្នើឱ្យកុមារស្រាយបំភ្លឺហេតុផល ។

- កុំស្នើសុំអង្គហេតុមួយចំនួនពីកុមារ ដែលពួកគេមិនបានប្រាប់អ្នក ។

- កុំព្យាយាមផ្លាស់ប្តូរខ្លឹមសារនៃអ្វីដែលកុមារនិយាយគឺជាភស្តុតាងរបស់គាត់ ឬនាង ។

- កុំប្រើការលើកដាក់សំឡេងបែបចោទប្រកាន់នៅពេលអ្នកកំពុងសួរកុមារអំពីភាពមិនស្របគ្នា ។ កុមារអាច មានការភាន់ច្រឡំ ឬអាចមានហេតុផលពិតប្រាកដសម្រាប់ការផ្លាស់ប្តូរ ។ បញ្ហានេះអាចចាំបាច់ត្រូវពន្យល់នៅក្នុងតុលាការ ហើយកុមារអាចចាំបាច់ត្រូវត្រៀមខ្លួនដើម្បីពន្យល់ពីភាពខុសគ្នា ។ ព្យាយាមសួរសំណួរដដែលតាមរបៀបផ្សេង ។

● ពិភាក្សាជាមួយកុមារអំពីសក្ខីកម្ម ឬភស្តុតាងផ្សេងទៀតដែលអាចត្រូវបានបង្ហាញៈ

- អនុញ្ញាតឱ្យកុមារដឹងអំពីភស្តុតាងរបស់សាក្សីផ្សេងទៀត ឬអ្វីដែលជនជាប់ចោទនិយាយអំពីអ្វីដែលបានកើតឡើង ។

- ពិនិត្យឡើងវិញជាមួយកុមារនូវឯកសារ ឬភស្តុតាងរូបវន្តផ្សេងទៀតដែលអាចត្រូវបានបង្ហាញដោយព្រះរាជអាជ្ញា ឬមេធាវីការពារជនជាប់ចោទ ។

- ស្នើឱ្យកុមារពិចារណាឡើងវិញនូវការនឹកឃើញរបស់ពួកគេអំពីហេតុការណ៍ដែលទាក់ទងនឹងភស្តុតាងផ្សេងទៀតដែលអាចត្រូវបានបង្ហាញ ។

- កុំសួរសំណួរដឹកមុខ ។

- ចូរសួរសំណួរបើកអំពីអ្វីដែលកុមារគិតអំពីភស្តុតាងផ្សេងទៀត ។

ឧទាហរណ៍ៈ

i. **ខុសៈ**"ជនជាប់ចោទបានប្រាប់នគរបាលថា ម្តាយរបស់អ្នកនៅទីនោះគឺនៅផ្ទះរបស់អ្នកនៅពេលគាត់មកលេងអ្នក ។ តើគាត់និយាយកុហកមែនទេ?"

ii.**ត្រូវ:** “ជនជាប់ចោទបានប្រាប់នគរបាលថា ម្តាយរបស់អ្នកនៅទីនោះនៅផ្ទះរបស់អ្នកនៅពេលគាត់មកលេងអ្នក។ តើអ្នកអាចប្រាប់ខ្ញុំអំពីអ្វីដែលអ្នកចងចាំបានទេ?”

● ពិភាក្សាអំពីប្រភេទនៃការសួរសំណួរដែលអាចមាន ដែលកុមារអាចត្រូវឆ្លើយនៅក្នុងតុលាការ (ពីសំណាក់ចៅក្រម ឬមេធាវីការពារចុងចោទ)។ ប្រការនេះជួយកុមារក្នុងការរំពឹងទុកនូវអ្វីដែលពួកគេនឹងត្រូវបានសួរ និងជៀសវាងការនិយាយរដាក់រដុបនៅពេលពួកគេនៅក្នុងតុលាការ។

- ដំបូង ពន្យល់ដល់កុមារថា អ្នកនឹងសួរសំណួរ ប្រៀបដូចជាអ្នកគឺជាចៅក្រម ឬមេធាវីការពារជនជាប់ចោទដូច្នោះដែរ។ ពន្យល់កុមារថា:

i.“យើងនឹងអនុវត្តសំណួរមួយចំនួនដែលចៅក្រម ឬមេធាវីការពារចុងចោទអាចសួរអ្នក។ ខ្ញុំនឹងធ្វើសកម្មភាពប្រៀបដូចជាខ្ញុំកំពុងសួរសំណួរក្នុងនាមចៅក្រម ឬមេធាវីការពារជនជាប់ចោទដូច្នោះដែរ”។ វិធីនេះ កុមារមិនភាន់ច្រឡំអំពីមូលហេតុដែលអ្នកកំពុងសួរពួកគេនូវសំណួរតាមរបៀបនេះ។

ii.“ពេលខ្លះ សំណួរអាចហាក់ដូចជាមានលក្ខណៈគឃ្លើន ឬដូចជាចៅក្រមឬមេធាវីការពារជនជាប់ចោទមិនជឿអ្នក។ មនុស្សទាំងនោះគ្រាន់តែធ្វើការងាររបស់ពួកគេប៉ុណ្ណោះ។

- **ហាត់សមសំណួរមួយចំនួន**ដែលចៅក្រមឬមេធាវីការពារជនជាប់ចោទអាចសួរ។ នេះគឺជាឱកាសមួយដើម្បីដោះស្រាយបញ្ហាអ្វីមួយដែលកុមារអាចភាន់ច្រឡំ។

i.ឧទាហរណ៍ វាអាចទៅរួចដែលកុមារយល់ច្រឡំសំណួរ ផ្តល់ព័ត៌មានមិនពាក់ព័ន្ធ ឬមិនបានផ្តល់នូវព័ត៌មានពាក់ព័ន្ធ។ អ្នកអាចជួយកុមាររៀបចំចម្លើយរបស់ពួកគេតាមរបៀបមួយដែលច្បាស់លាស់ និងត្រឹមត្រូវ និងឆ្លុះបញ្ចាំងអត្ថន័យជាក់ស្តែងរបស់កុមារ ។

ទោះជាយ៉ាងណាក៏ដោយអ្នកមិនត្រូវប្រាប់កុមារអំពីអ្វីដែលត្រូវនិយាយ ឬជួយកុមារក្នុងការផ្តល់សក្ខីកម្មមិនពិតអំពីអង្គហេតុសំខាន់ណាមួយឡើយ។

● **ពន្យល់ឱ្យបានច្បាស់អំពីតួនាទីរបស់ចៅក្រម និងមេធាវី**នៅពេលពួកគេសួរកុមារ:

- ការងាររបស់មេធាវីការពារជនជាប់ចោទ គឺព្យាយាមការពារជនជាប់ចោទ និងដោយហេតុនេះ គាត់ ឬនាងអាចព្យាយាមធ្វើឱ្យចៅក្រមជឿជាក់ថាមិនគួរជឿកុមារឡើយ។

- ការងាររបស់ចៅក្រម គឺព្យាយាមទទួលបានព័ត៌មានទាំងអស់អំពីរឿងក្តីដោយពិចារណាលើអ្វីដែលជនជាប់ចោទបាននិយាយ។ ដូច្នេះចៅក្រមអាចសួរកុមារនូវសំណួរលម្អិត រួចឱ្យកុមារពន្យល់នូវភាពខុសគ្នារវាងអ្វីដែលកុមារបាននិយាយកន្លងមក និងអ្វីដែលកុមារកំពុងនិយាយនៅក្នុងតុលាការ។

ជំហានទីពីរ ៖ ការផ្តល់ព័ត៌មានអំពីដំណើរការតុលាការដល់កុមារនិងឪពុកម្តាយ/អ្នកថែទាំ

**ព័ត៌មានកាត់បន្ថយការបារម្ភ**

កុមារទំនងជាមានសំណួរជាច្រើនអំពីមូលហេតុដែលពួកគេត្រូវទៅតុលាការ អ្វីជាតួនាទីរបស់កុមារ និងអ្វីកើតឡើងនៅក្នុងតុលាការ ។ ភាពមិនប្រាកដនេះ និងកង្វះការយល់ដឹងអាចបណ្តាលឱ្យកុមារមានការបារម្ភជាច្រើនក្នុងអំឡុងរយៈពេលឈានដល់សវនាការនៅតុលាការ ។ ប្រសិនបើកុមារអាចរំពឹងទុកមុននូវអ្វីដែលកើតឡើងប្រការនេះនឹងឆ្ពោះទៅដោះស្រាយការភ័យខ្លាច និងការបារម្ភរបស់កុមារ ។

1. អ្នកនឹងចាំបាច់ត្រូវតែបន្តផ្តល់ព័ត៌មានដល់កុមារអំពី៖

- តួនាទីរបស់មនុស្សនៅក្នុងតុលាការ
- តួនាទីរបស់កុមារនៅក្នុងនីតិវិធីតុលាការ
- ដំណើរការតុលាការ
- អ្វីកើតឡើងក្រោយពីតុលាការ

2. ព័ត៌មាននេះចាំបាច់ត្រូវផ្តល់ដល់កុមារ តាមរបៀបកុមារមេត្រី ។ កែសម្រួលភាសារបស់អ្នក អាស្រ័យលើអាយុ និងសមត្ថភាពរបស់កុមារ ។

3. យើងបានបង្កើតឧបករណ៍មួយចំនួនដើម្បីជួយអ្នកក្នុងការផ្តល់ព័ត៌មាននេះដល់កុមារ៖

- បង្ហាញកុមារនូវគំនូរជីវចលអំពីតុលាការនិងពិភាក្សាអំពីអ្វីដែលបានកើតឡើង ។ តើមានអ្វីមួយដែលពួកគេមិនច្បាស់ឬទេ?
- ផ្តល់ឱ្យកុមារនូវសំណៅមួយច្បាប់នៃកូនសៀវភៅទាំងពីរ ៖ "បូណា ទៅតុលាការ" និង"អ្នកណានឹងនៅក្នុងតុលាការ?" រួចអានកូនសៀវភៅទាំងពីរជាមួយពួកគេ ។

4. អនុញ្ញាតឱ្យកុមារនូវពេលវេលាគ្រប់គ្រាន់ដើម្បីឆ្លើយសំណួរ និងលេងល្បែងមួយចំនួនជាមួយកុមារ-ឧទាហរណ៍ អ្នកអាចសាកល្បងការចងចាំរបស់ពួកគេអំពីអ្នកណានៅក្នុងតុលាការ និងកន្លែងណាដែលពួកគេម្នាក់ៗអង្គុយ ។

**ការផ្តល់ព័ត៌មានដល់ឪពុកម្តាយ ឬអ្នកថែទាំ**

1. អ្នកគួរជួបជាមួយឪពុកម្តាយ/អ្នកថែទាំ មុនកាលបរិច្ឆេទនៃសវនាការពីព្រោះឪពុកម្តាយ/អ្នកថែទាំក៏នឹងចាំបាច់ត្រូវត្រៀមខ្លួនសម្រាប់តុលាការផងដែរ ។ វាជាការសំខាន់ដែលឪពុកម្តាយ ឬអ្នកថែទាំកុមារយល់អំពីដំណើរការតុលាការ និងតួនាទីរបស់កុមារនៅក្នុងដំណើរការ ។ នេះនឹងអនុញ្ញាតឱ្យឪពុកម្តាយ ឬអ្នកថែទាំ៖

- ពង្រឹងព័ត៌មានចំពោះកុមារ
- ផ្តល់ការគាំទ្រផ្នែកស្មារតីដល់កុមារនៅក្នុងដំណើរការទាំងមូល
- ធានាថា កុមារទទួលបានជំនួយសមស្រប ដូចជាមធ្យោបាយធ្វើដំណើរទៅកាន់ជំនួបប្រជុំជាមួយអ្នកប្រឹក្សាយោបល់ និងមេធាវី និងវត្តមាននៅតុលាការ ។

2. ជាញឹកញាប់ឪពុកម្តាយ ឬអ្នកថែទាំនឹងមិនយល់អំពីដំណើរការតុលាការច្រើនជាងកុមារនោះទេ ។ អ្នកចាំបាច់ត្រូវតែពន្យល់អំពីដំណើរការតុលាការទៅកាន់ឪពុកម្តាយ ។

- បង្ហាញពួកគេនូវគំនូរជីវចលអំពីតុលាការដែលអ្នកបានបង្ហាញដល់កុមារ ។
- យើងបានរៀបចំកូនសៀវភៅជាពិសេសសម្រាប់ឪពុកម្តាយ/អ្នកថែទាំដើម្បីពន្យល់ដល់ពួកគេអំពីដំណើរការតុលាការ និងបទបញ្ជាផ្ទៃក្នុងតុលាការៈ "ការជួយកុមារត្រៀមខ្លួនសម្រាប់តុលាការ" ។
  - អានកូនសៀវភៅនេះជាមួយឪពុកម្តាយ/អ្នកថែទាំ
  - ផ្តល់ឱ្យឪពុកម្តាយ/អ្នកថែទាំនូវសំណៅមួយច្បាប់នៃកូនសៀវភៅដើម្បីយកទៅ ។

3. ពន្យល់ដល់ឪពុកម្តាយ/អ្នកថែទាំថា កុមារ ជាញឹកញាប់ មានការភ័យខ្លាចខ្លាំងក្នុងការទៅកាន់តុលាការ ហើយកុមារនឹងត្រូវការជំនួយផ្នែកស្មារតីបន្ថែមពីឪពុកម្តាយ/អ្នកថែទាំក្នុងអំឡុងពេលនេះ ។

4. ពន្យល់ដល់ឪពុកម្តាយ/អ្នកថែទាំថា អ្នក (ឬអ្នកគ្រប់គ្រងករណី) នឹងទាក់ទងពួកគេនៅពេលកាលបរិច្ឆេទនៃសវនាការត្រូវបានកំណត់ភ្លាម ហើយវាជាការសំខាន់ដែលឪពុកម្តាយ/អ្នកថែទាំត្រៀមខ្លួនកុមារឱ្យរួចរាល់ដើម្បីចូលរួមនៅក្នុងតុលាការនៅកាលបរិច្ឆេទនោះ ។ នេះរួមបញ្ចូលទាំងៈ

- ប្រសិនបើចាំបាច់ ពន្យល់ដល់សាលារៀនរបស់កុមារថា កុមារនឹងអវត្តមាននៅកាលបរិច្ឆេទនៃសវនាការ ។
- ធ្វើការរៀបចំដើម្បីចូលរួមនៅក្នុងសវនាការ ដូចជា ការស្នើសុំច្បាប់ឈប់សម្រាកពីការងារ និងប្រសិនបើចាំបាច់រៀបចំការថែទាំកុមារសម្រាប់កូនផ្សេងទៀត ។
- ត្រៀមខ្លួនកុមារឱ្យរួចរាល់នៅថ្ងៃនៃសវនាការ និងប្រាកដថា ពួកគេជួបជាមួយអ្នក និងអ្នកប្រឹក្សាយោបល់នៅពេលវេលាដែលបានព្រមព្រៀងមុនសវនាការ ។

### ជំហានទីបីៈ ពិចារណាអំពីការរៀបចំសម្រាប់ការចូលរួមនៅក្នុងតុលាការ

**1.ធ្វើការរៀបចំសម្រាប់បន្ទប់រង់ចាំសម្រាប់គោលបំណងជាក់លាក់**

- វាអាចជាការភ័យខ្លាច និងភិតភ័យខ្លាំងសម្រាប់កុមារ ប្រសិនបើគាត់ ឬនាងជួបជនជាប់ចោទនៅក្នុងតុលាការ មុនសវនាការ ។
- កុមារមានសិទ្ធិរង់ចាំនៅក្នុងបន្ទប់រង់ចាំដាច់ដោយឡែកមួយនៅក្នុងតុលាការ មុនពេលគាត់ ឬនាងចូលក្នុងបន្ទប់ ។
- ទំនាក់ទំនងជាមួយក្រឡាបញ្ជីមុនកាលកាលបរិច្ឆេទនៃសវនាការដើម្បីធានាថា បន្ទប់រង់ចាំដាច់ដោយឡែកមួយត្រូវបានបម្រុងទុកសម្រាប់កុមារ ។

**2.ពិចារណាអំពីការរៀបចំដែលចាំបាច់សម្រាប់ជំនួយសក្ខីកម្មកុមារមេត្រី ការផ្តល់សក្ខីកម្មដែលមានរបាំងសវនាការសម្រាប់សាក្សី ឬភ្ជាប់បណ្តាញទូរទស្សន៍**

- សួរកុមារថាតើគាត់ ឬនាងមានការភ័យខ្លាចក្នុងការផ្តល់ភស្តុតាងនៅចំពោះវត្តមានជនជាប់ចោទឬទេ ។
- ប្រសិនបើដូច្នោះចូរពន្យល់ថាអ្នកអាចស្នើសុំឱ្យតុលាការប្រើរបាំងសវនាការដែលញែកកុមារពីជនជាប់ចោទ ដើម្បីកុំឱ្យជនជាប់ចោទអាចមើលឃើញកុមារ ។
- ប្រសិនបើអ្នកគិតថាទោះជាមានរបាំងសវនាការក៏ដោយ កុមារនៅតែងាយរងគ្រោះខ្លាំងរហូតដល់សូម្បីតែនៅជាមួយគ្នាក្នុងបន្ទប់តែមួយជាមួយជនជាប់ចោទមានការភ័យខ្លាចខ្លាំងឬជាការគំរាមកំហែងចំពោះកុមារ អ្នកអាចស្នើសុំទៅកាន់តុលាការដើម្បីឱ្យកុមារផ្តល់ភស្តុតាងតាមរយៈបន្ទាប់សវនាការដែលភ្ជាប់បណ្តាញទូរទស្សន៍ ដើម្បីយកសក្ខីកម្ម ។
- ភ្លាមៗក្រោយពេលអ្នកត្រូវបានជូនដំណឹងអំពីកាលបរិច្ឆេទតុលាការ ចូរសរសេរលិខិតមួយច្បាប់ទៅកាន់ក្រឡាបញ្ជីតុលាការដើម្បីស្នើសុំឱ្យមានរបាំងសាក្សី ឬបរិក្ខារ CCTV(បន្ទប់សវនការដែលភ្ជាប់បណ្តាញទូរទស្សន៍ដើម្បីយកសក្ខីកម្ម) សម្រាប់ការកាត់ក្តី។
  - [សូមមើលគំរូដែលប្រើដោយ IJM នៅផ្នែកចុងក្រោយនៃជំពូកនេះ]
- ប្រាកដថាបរិក្ខារទាំងនេះនឹងត្រូវបានបង្កើតឡើង មុនពេលចាប់ផ្តើមការកាត់-ក្តី ដើម្បីកុំឱ្យកុមារមើលឃើញជនជាប់ចោទនៅពេលកុមារដើរចូលក្នុងសាវនាការ ។
- នៅថ្ងៃមុនសវនាការ ហៅទៅកាន់ក្រឡាបញ្ជីតុលាការដើម្បីបញ្ជាក់អះអាងថា ការរៀបចំត្រូវបានធ្វើឡើង ។
- កុំធ្វើការសន្យាណាមួយជាមួយកុមារ ប៉ុន្តែនៅពេលអ្នកបានអះអាងជាមួយតុលាការថា ការរៀបចំទាំងនេះអាចរកបាន ចូរជូនដំណឹងដល់កុមារ ដើម្បីឱ្យកុមារដឹងអំពីអ្វីដែលត្រូវរំពឹង ។

**អ្នកគាំទ្រសាក្សី**

- សួរយោបល់កុមារថាតើគាត់ឬនាងមានការភ័យខ្លាចក្នុងការផ្តល់ភស្តុតាងនៅចំពោះវត្តមានជនជាប់ចោទ ដោយមិនចាំបាច់មានអ្នកណាម្នាក់ឈរ ឬអង្គុយក្បែរខ្លួនឬទេ ។
- សួរកុមារថាតើគាត់/នាងនឹងមានអារម្មណ៍កាន់តែងាយស្រួលឬទេ ប្រសិនបើមានបុគ្គលគាំទ្រម្នាក់ត្រូវបានអនុញ្ញាតឱ្យឈរក្បែរគាត់/នាងខណៈកុមារផ្តល់ភស្តុតាង ។ ប្រសិនបើដូច្នោះ តើកុមារចង់ឱ្យបុគ្គលគាំទ្រនោះជាអ្នកណា?
- ភ្លាមៗក្រោយពីអ្នកត្រូវបានជូនដំណឹងអំពីកាលបរិច្ឆេទសវនាការចូរសរសេរលិខិតមួយច្បាប់ទៅកាន់ក្រឡាបញ្ជីតុលាការ ដើម្បីស្នើសុំការអនុញ្ញាតដល់អ្នកគាំទ្រសាក្សី ។
- កុំធ្វើការសន្យាណាមួយជាមួយកុមារ-ប៉ុន្តែភ្លាមៗក្រោយពីក្រឡាបញ្ជីតុលាការបានអះអាងថា ការរៀបចំត្រូវបានអនុញ្ញាត ចូរផ្តល់ដំណឹងដល់កុមារជានិច្ច ។

3. **ពិចារណាអំពីការរៀបចំការពារ**

● ភ្លាមៗក្រោយពីអ្នកត្រូវបានជូនដំណឹងអំពីកាលបរិច្ឆេទសវនាការចូរសរសេរលិខិតមួយច្បាប់ទៅកាន់ក្រឡាបញ្ជីតុលាការ ដោយស្នើសុំនូវវិធានការណាមួយដូចខាងក្រោម ប្រសិនបើវិធានការទាំងនេះមានភាពសមស្រប៖

- សវនាការជាអសាធារណ៖
- ដីកាការពារ
- ការហាមឃាត់លើប្រព័ន្ធផ្សព្វផ្សាយ និងសារព័ត៌មានដែលផ្សាយព័ត៌មានលាតត្រដាងអត្តសញ្ញាណរបស់កុមារ ។

4. **ពិចារណាអំពីការរៀបចំផ្នែកភស្តុភារសម្រាប់ការចូលរួមនៅក្នុងតុលាការ**

● មធ្យោបាយដឹកជញ្ជូន

- ធានាថា កុមារ ឪពុកម្តាយ/អ្នកថែទាំ អ្នកគាំទ្រ (ប្រសិនបើមាន) និងអ្នកប្រឹក្សាយោបល់បានរៀបចំមធ្យោបាយដឹកជញ្ជូនទៅតុលាការ ដោយមានពេលវេលាច្រើន ។
- កុមារមិនគួរត្រូវបានដឹកជញ្ជូនទៅតុលាការនៅក្នុងយានយន្តតែមួយជាមួយនឹងជនជាប់ចោទជាដាច់ខាត ។

● ការមកដល់តុលាការ

- មុនថ្ងៃសវនាការ យល់ព្រមជាមួយសមាជិកនីមួយៗនៃក្រុម(អ្នកប្រឹក្សាយោបល់ អ្នកថែទាំ មេធាវី អ្នកគ្រប់គ្រងករណី មេធាវី) អំពីកន្លែងពិតប្រាកដដែលអ្នកនឹងជួបគ្នានៅថ្ងៃសវនាការ ។

● អ្នកថែទាំកុមារ

- អះអាងថា អ្នកថែទាំកុមារមានព័ត៌មានទាំងអស់អំពីកាលបរិច្ឆេទ និងទីកន្លែងនៃសវនាការ និងបានធ្វើការរៀបចំទាំងអស់ដែលចាំបាច់ដើម្បីអមដំណើរកុមារទៅតុលាការនៅថ្ងៃនោះ ។





# ការត្រៀមខ្លួនកុមារ ដែលទទួលរងការប៉ះទង្គិចផ្លូវចិត្ត សម្រាប់តុលាការ សម្រាប់អ្នកគាំទ្រមិនមែនផ្នែកច្បាប់



## ការត្រៀមខ្លួនរបស់តុលាការ

ជួយកាត់បន្ថយការប៉ះទង្គិចផ្លូវចិត្តនៃការចូលរួមនៅក្នុងតុលាការ និងនាំឱ្យការផ្ដល់សក្ខីកម្មមានលក្ខណៈកាន់តែប្រសើរ ។ ផ្នែកខ្លះនៃកម្មវិធីត្រៀមខ្លួនរបស់តុលាការនឹងត្រូវអនុវត្តដោយអ្នកគាំទ្រមិនមែនផ្នែកច្បាប់ និងផ្នែកផ្សេងទៀតដោយមេធាវី ។

ជំហានទាំងឡាយខាងក្រោម គួរត្រូវបានអនុវត្តតាមដោយអ្នកគាំទ្រមិនមែនផ្នែកច្បាប់ ។

## ជំហានទីមួយ : វាយតម្លៃកុមារ

អ្នកនឹងចាំបាច់ត្រូវវាយតម្លៃកុមារដើម្បីយល់ដឹងអំពីកម្រិតនៃការប៉ះទង្គិចផ្លូវចិត្តរបស់កុមារ និងសមត្ថភាពរបស់គាត់ ឬនាងក្នុងនាមជាសាក្សី ។ ការធ្វើបែបនេះនឹងអនុញ្ញាតឱ្យអ្នក និងមេធាវីអាចកំណត់ថាតើកុមារត្រូវការការគាំទ្រ និងការត្រៀមខ្លួនកម្រិតណា និងការជួយជ្រោមជ្រែងពិសេសណាមួយដែលអាចជាការចាំបាច់ ។

1.វាយតម្លៃកម្រិតនៃការប៉ះទង្គិចផ្លូវចិត្តរបស់កុមារ

● កសាងទំនាក់ទំនងជាមួយកុមារ និងសង្កេតមើលសញ្ញានៃការប៉ះទង្គិចផ្លូវចិត្តរបស់កុមារ ។

● និយាយទៅកាន់ឪពុកម្ដាយ ឬអ្នកថែទាំកុមារ ដើម្បីទទួលព័ត៌មានអំពីប្រវត្តិការគាំទ្រអាកប្បកិរិយារបស់កុមារ ។ កុមារដែលធ្លាប់ឆ្លងកាត់ប្រវត្តិនៃការប៉ះទង្គិចផ្លូវចិត្ត និងដែលមិនមានការគាំទ្រច្រើនពីសំណាក់គ្រួសារ ឬសហគមន៍ នឹងត្រូវការការយកចិត្តទុកដាក់ និងពេលវេលាច្រើនជាងមុន ។

2.វាយតម្លៃកម្រិតនៃការយល់ដឹងរបស់កុមារ

● និយាយជាមួយកុមារអំពីប្រធានបទនានាដែលមិនទាក់ទងនឹងរឿងក្ដី ដើម្បីទទួលបានគំនិតអំពីកម្រិតនៃការយល់ដឹង និងជំនាញទំនាក់ទំនងផ្ទាល់មាត់របស់កុមារ ។

● សួរកុមារនូវសំណួរនានាដែលនឹងប្រាប់អ្នកថា តើពួកគេអាចយល់នូវសំណួរសាមញ្ញ និងសំណួរបើកឬទេ និងថាតើពួកគេអាចប្រាប់ពីលំដាប់លំដោយនៃព្រឹត្តិការណ៍បានឬទេ ។ កែសម្រួលរបៀបទំនាក់ទំនងរបស់អ្នក យោងតាមសមត្ថភាពរបស់កុមារក្នុងការយល់ដឹង និងទំនាក់ទំនង ។

ឧទាហរណ៍ :

- តើអ្នកអាចប្រាប់ខ្ញុំអំពីសាលារៀនបានទេ?
- តើអ្វីទៅជាកិច្ចការដែលអ្នកចូលចិត្តបំផុតពីការទៅសាលារៀន?
- តើអ្នកអាចប្រាប់ខ្ញុំអំពីមិត្តភ័ក្ដិរបស់អ្នកនៅសាលារៀនបានទេ?
- តើអ្នកអាចប្រាប់ខ្ញុំអំពីអ្វីដែលអ្នកបានធ្វើនៅថ្ងៃនេះនៅសាលារៀនបានទេ?

● អ្នកអាចចាំបាច់ត្រូវអះអាងថា កុមារយល់ដឹងនូវភាពខុសគ្នារវាងការណ៍ពិត និងការកុហក និងការសន្យាប្រាប់ការណ៍ពិតនៅក្នុងតុលាការ ។

ឧទាហរណ៍:

- ប្រសិនបើខ្ញុំត្រូវនិយាយថា ខ្ញុំកំពុងពាក់ស្បែកជើងពណ៌ខៀវ តើនោះ ពិត ឬមិនពិត? នោះនឹងជា ការកុហក ពីព្រោះខ្ញុំកំពុងពាក់ស្បែកជើងពណ៌ត្នោត ។

3.បញ្ជូនលទ្ធផលរកឃើញរបស់អ្នកទៅមេធាវីរបស់កុមារ

● អ្នកចាំបាច់ត្រូវតែបញ្ជូនលទ្ធផលរកឃើញរបស់អ្នកទៅមេធាវីរបស់កុមារ ដើម្បីឱ្យមេធាវីអាចយល់នូវរបៀបកែសម្រួលការត្រៀមខ្លួនសម្រាប់កុមារ ។

ជំហានទីពីរ: ផ្តល់នូវការគាំទ្រផ្នែកស្មារតីដល់កុមារ

1. **ផ្តោតលើការផ្តល់ប្រឹក្សាអំពីការត្រៀមខ្លួនសម្រាប់តុលាការ**

● កុមារដែលជាជនរងគ្រោះ ឬជាសាក្សីនៃបទល្មើសធ្ងន់ធ្ងរ ទំនងជាត្រូវការការគាំទ្រផ្នែកផ្តល់ប្រឹក្សារយៈពេលវែង ដើម្បីជួយគាត់ ឬនាងក្នុងការដោះស្រាយការប៉ះទង្គិចផ្លូវចិត្តដែលធ្លាប់បានឆ្លងកាត់ ដែលជាលទ្ធផលនៃហេតុការណ៍ ។

● ទោះជាយ៉ាងណាក៏ដោយនៅទីនេះ យើងយកចិត្តទុកដាក់អំពីការគាំទ្រផ្នែកស្មារតីដែលកុមាររងគ្រោះត្រូវការ ដើម្បីបំពាក់បំប៉នពួកគេឱ្យជំនះដំណើរការផ្តល់សក្ខីកម្មនៅក្នុងតុលាការ ។

● ដូច្នេះ ផ្តោតលើ:

- ការរំពឹងទុក និងការដោះស្រាយពីក្តីបារម្ភដ៏ខ្លាំងក្លារបស់ក្មេង អំពីការផ្តល់ភស្តុតាងនៅក្នុងតុលាការ

- ហេតុការណ៍អាក្រក់ដែលអាចកើតមានឡើង

- ការផ្តល់នូវការអះអាងឡើងវិញនិងការលួងលោមនៅក្នុងការគាំទ្ររបស់អ្នក

- ការបង្រៀនបច្ចេកទេសក្នុងការដោះស្រាយ ។

2.**បង្រៀនកុមារនូវបច្ចេកទេសក្នុងការដោះស្រាយ**

ទាំងការភ័យខ្លាចអំពីការនៅក្នុងតុលាការ ទាំងការស្ថិតនៅក្នុងស្ថានភាពប៉ះទង្គិចផ្លូវចិត្តដែលអាចជាហេតុការណ៍អាក្រក់ អាចធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់កុមារក្នុងការផ្តល់នូវភស្តុតាង ពេញលេញ និងត្រឹមត្រូវ ។

ដូច្នេះ វាជាការចាំបាច់ដែលត្រូវបំពាក់បំប៉នកុមារជាមុននូវបច្ចេកទេសក្នុងការដោះស្រាយដែលពួកគេអាចប្រើនៅពេលពួកគេកំពុងផ្តល់ភស្តុតាង ប្រសិនបើពួកគេមានអារម្មណ៍ធុញថប់ ឬភ័យខ្លាចខ្លាំង ។

## លំហាត់ដកដង្ហើមរំងាប់អារម្មណ៍

នៅពេលអ្នកមានអារម្មណ៍ភ័យខ្លាច ពេលខ្លះការដកដង្ហើមរបស់អ្នកអាចក្លាយជាមានការលំបាក។

ការអនុវត្ត "ការដកដង្ហើមរំងាប់អារម្មណ៍" នឹងជួយអ្នកពន្យឺតការដកដង្ហើមរបស់អ្នក និងធ្វើឱ្យអ្នកមានអារម្មណ៍កាន់តែស្ងប់។

ជំហាននានាក្នុងការបង្រៀនកុមារ

1. អង្គុយត្រង់ខ្លួននៅលើកៅអី រួចដាក់ដៃមួយនៅលើពោះរបស់អ្នក។

2. ដកដង្ហើមចូលយឺតមួយតាមច្រមុះដោយដកដង្ហើមចូលទៅក្នុងពោះផ្នែកខាងក្រោមរបស់អ្នក (រយៈពេលប្រហែល ៤ វិនាទី) រហូតទាល់តែដៃនៅលើពោះរបស់អ្នកចាប់ផ្តើមរីកធំ។

3. ទប់ដង្ហើមរបស់អ្នករយៈពេល ១ ឬ ២ វិនាទី។

4. ផ្លុំខ្យល់យឺតៗតាមមាត់ (រយៈពេលប្រហែល ៤ វិនាទី)។

5. រង់ចាំពីរបីវិនាទី មុនពេលដកដង្ហើមចូលម្តងទៀត។

6. ធ្វើបែបនេះប្រហែល ៦-៨ ដង ក្នុងមួយនាទី ដើម្បីកាត់បន្ថយការបារម្ភ ប៉ុន្តែស្វែងរកចង្វាក់ដង្ហើមដែលងាយស្រួលរបស់អ្នកផ្ទាល់។

7. សាកល្បងធ្វើបែបនេះរយៈពេលប្រហែល ៥ នាទី។

ប្រសិនបើអ្នកកំពុងជួបប្រទះការចងចាំរឿងរ៉ាវឈឺចាប់ អ្នកគួរបើកភ្នែករបស់អ្នកនៅពេលធ្វើការដកដង្ហើមរំងាប់អារម្មណ៍។

## លំហាត់បន្ធូរភាពតានតឹងនៃសាច់ដុំ

ការបន្ធូរភាពតានតឹងនៃសាច់ដុំជាបន្តបន្ទាប់នឹងបង្រៀនអ្នកអំពីរបៀបបន្ធូរភាពតានតឹងនៃសាច់ដុំរបស់អ្នក និងបញ្ចេញអារម្មណ៍តានតឹង និងភាពតឹងតែង។ តាមរយៈការហ្វឹកហាត់ អ្នកអាចដឹងពីភាពខុសគ្នារវាងអារម្មណ៍នៃសាច់ដុំដែលតានតឹង និងសាច់ដុំដែលធូរស្រាលទាំងស្រុង។

ការបន្ធូរភាពតានតឹងនៃសាច់ដុំនឹងជួយអ្នកក្នុងការបន្ធូរអារម្មណ៍នៅពេលណាដែលអ្នកមានអារម្មណ៍តានតឹង។

ជំហាននានាក្នុងការបង្រៀនកុមារ

1. ផ្តោតលើដៃឆ្វេងរបស់អ្នក។ ស្រមៃស្រមៃថាអ្នកកំពុងកាន់ក្រូចឆ្មារមួយផ្លែ។

2. ដកដង្ហើមវែងយឺតៗមួយ រួចច្របាច់ផ្លែក្រូចឆ្មារនៅក្នុងដៃរបស់អ្នកយ៉ាងខ្លាំងតាមដែលអ្នកអាចធ្វើបានរយៈពេលប្រហែល ៥ វិនាទី។

3. ក្រោយពីរយៈពេលប្រហែល ៥ វិនាទី អនុញ្ញាតឱ្យភាពតឹងទាំងអស់ហូរចេញពីដៃរបស់អ្នកនៅពេលអ្នកប្រលែងក្រូចឆ្មារ។ ដកដង្ហើមចេញនៅពេលអ្នកធ្វើជំហាននេះ។

អ្នកគួរតែមានអារម្មណ៍ថា សាច់ដុំនៅក្នុងដៃរបស់អ្នកក្លាយជាធូរនិងទន់ ហើយភាពតានតឹងនឹងហូរទៅអស់។

4. ធ្វើបែបនេះឡើងវិញយឺតៗ ប្រហែល ៤ ឬ ៥ ដង។

## មីឆ្អិន និងមិនឆ្អិន

នេះក៏ជាសកម្មភាពបន្ធូរភាពតានតឹងនៃសាច់ដុំផងដែរ ។ វាអាចជាការសប្បាយ និងអាចត្រូវបានប្រើប្រាស់ជាមួយកុមារតូចនិងកុមារធំ-ក្មេងប្រុស ឬក្មេងស្រី ។

ជំហាននានាក្នុងការបង្រៀនកុមារ :

1. អង្គុយយ៉ាងស្រួលនៅក្នុងកៅអី ឬនៅលើកម្រាល ។

2. ចូរអនុវត្តរបៀបបន្តឹងសាច់ដុំរបស់យើង ។ បន្តឹងដៃរបស់អ្នកយ៉ាងខ្លាំងតាមដែលអ្នកអាចធ្វើទៅបាន ។

3. ស្រមើស្រមៃអំពីមីមួយចាន ។ មីឆ្អិនគឺទន់ មីឆៅគឺរឹង ។ ហើយវាក៏ដូច្នោះដែរសម្រាប់សាច់ដុំ ។

4.នៅពេលខ្ញុំនិយាយថា “មីឆៅ” បន្តឹងដៃរបស់អ្នកដូចជាមីឆៅដ៏រឹងដូច្នោះដែរ ។ រក្សាឱ្យវានៅតឹង! [ អ្នកអាចទុកវាចោលប្រហែល ៦-៧វិនាទី រវាងមីឆៅ និងមីឆ្អិន] ។ បន្ទាប់មក នៅពេលខ្ញុំនិយាយថា “មីឆ្អិន” អ្នកអាចរលាសាច់ដុំរបស់អ្នក ដើម្បីឱ្យវាទន់ដូចជាមីឆ្អិន ដូច្នោះដែរ ។

5. ចូរធ្វើបែបនោះពីរបីដង ។

6. ចូរព្យាយាមធ្វើបែបនេះ ជាមួយការបន្តឹងសាច់ដុំនៃផ្នែកផ្សេងទៀតនៃរាងកាយរបស់យើង ។

ដើម្បីធ្វើឱ្យវាកាន់តែសប្បាយ អ្នកអាចឱ្យកុមារក្រោកឈរបន្ទាប់មកឱ្យពួកគេធ្វើឱ្យឆៅ(បន្តឹង) និងទប់សាច់ដុំដោយចាប់ផ្តើមពីម្រាមជើងរហូតដល់ក្បាល ។ នៅពេលរាងកាយទាំងមូលរបស់ពួកគេឡើងតឹង អ្នកអាចឱ្យពួកគេដើរ ។ ដូច្នេះពួកគេនឹងមានអារម្មណ៍ ដូចជាមនុស្សយន្តដើរ ។ បន្ទាប់មកអ្នកអាចនិយាយថា “មីឆ្អិន” ដើម្បីរលាសាច់ដុំរបស់ពួកគេ ។

## Grounding

Grounding គឺជាបច្ចេកទេសដែលមានប្រយោជន៍ខ្លាំង ប្រសិនបើអ្នកជួបប្រទះការចងចាំអារម្មណ៍ឈឺចាប់ឬបាត់បង់ទំនាក់ទំនងជាមួយពេលវេលាបច្ចុប្បន្ន ។

Grounding បង្រៀនអ្នកឱ្យបញ្ឈប់ការបាត់បង់ទំនាក់ទំនងជាមួយពេលវេលាបច្ចុប្បន្ន ដោយផ្តោតលើ បច្ចុប្បន្ន ឬដោយការបង្វែរការយកចិត្តទុកដាក់របស់អ្នកចំពោះអ្វីមួយផ្សេង ។

ជំហាននានាក្នុងការបង្រៀនកុមារ

1. បើកភ្នែករបស់អ្នក ។ មើលជុំវិញអ្នក និងកត់សម្គាល់កន្លែងដែលអ្នកនៅ ។

2. ប៉ះវត្ថុនៅជុំវិញអ្នក និងពណ៌នាវត្ថុទាំងនោះ (សាច់ផ្ទៃ ពណ៌) ។ ឧទាហរណ៍ “ខ្ញុំកំពុងឈរលើដី ។ ស្បែកជើងរបស់ខ្ញុំពណ៌ខៀវ ។ ដីរឹង និងធ្វើពីឈើ និងមានកៅអីក្រហមនៅជ្រុងកែងនៃបន្ទប់” ។

3.រៀបរាប់ឈ្មោះដោយប្រើវិញ្ញាណរបស់អ្នក ( “តើអ្នកអាចស្តាប់ឮអ្វីនៅក្នុងបន្ទប់ពេលនេះ?” រៀបរាប់ឈ្មោះវត្ថុចំនួន ៥ នៅក្នុងបន្ទប់នេះដែលមានពណ៌បៃតង?)

4.បើកភ្នែករបស់អ្នក ដើម្បីឱ្យអ្នកអាចមើលឃើញ និងផ្តោតលើអ្វីដែលនៅជុំវិញអ្នកពេលនេះ។ និយាយចេញមកក្រៅឮៗដោយរៀបរាប់អ្វីដែលអ្នកកំពុងមើលឃើញនិងធ្វើ។

5.រំឭកខ្លួនអ្នក “ដូច្នេះខ្ញុំដឹង (ដាក់ឈ្មោះការប៉ះទង្គិចផ្លូវចិត្តតាមចំណងជើងម្តងទៀតប៉ុណ្ណោះ ឧទាហរណ៍ “ការត្រូវបានវាយដោយពូ/អ៊ុំប្រុសរបស់ខ្ញុំ ”) មិនកំពុងកើតឡើងនៅពេលនេះទេ ឬតទៅទៀតឡើយ ” ។

កំណត់សម្គាល់សំខាន់: ការបន្ថយភាពតានតឹងនៃសាច់ដុំ ការគ្រប់គ្រង ដង្ហើម គ្រាន់តែជាបច្ចេកទេសមួយចំនួន ដែលកុមារទទួលរងការប៉ះទង្គិចផ្លូវចិត្ត អាចប្រើដើម្បីរំងាប់អារម្មណ៍របស់ពួកគេប៉ុណ្ណោះ។ សកម្មភាពផ្សេងទៀតជាច្រើនក៏អាចរកបាន និងមានប្រយោជន៍ផងដែរ ដើម្បីជួយពួកគេឱ្យមានអារម្មណ៍ធូរស្រាល ដូចជាការគូររូប ការផាត់រូប ការលេងប្រស្នា ការស្តាប់តន្ត្រី។ល។ កុមារទាំងអស់មានលក្ខណៈផ្ទាល់ខ្លួនផ្សេងៗគ្នា។ បច្ចេកទេសណាមួយដែលមានប្រយោជន៍ចំពោះកុមារណាម្នាក់អាចមិនមានប្រយោជន៍ចំពោះកុមារម្នាក់ទៀតឡើយ។ ការសួរកុមារថាតើជាធម្មតា ពួកគេធ្វើអ្វីដើម្បីមានអារម្មណ៍ធូរស្រាល គឺជាការសំខាន់ មុនពេលផ្តល់នូវការណែនាំដល់ពួកគេ។

## ជំហានទីបី : ការផ្តល់ព័ត៌មានអំពីដំណើរការតុលាការដល់កុមារ និងឪពុកម្តាយ/អ្នកថែទាំ

**ព័ត៌មានកាត់បន្ថយការបារម្ភ**

កុមារទំនងជាមានសំណួរជាច្រើនអំពីមូលហេតុដែលពួកគេត្រូវទៅតុលាការ អ្វីជាតួនាទីរបស់កុមារ និងអ្វីកើតឡើងនៅក្នុងតុលាការ។ ភាពមិនប្រាកដនេះនិងកង្វះការយល់ដឹងអាចបណ្តាលឱ្យកុមារមានការបារម្ភជាច្រើន ក្នុងអំឡុងរយៈពេលឈានដល់សវនាការនៅតុលាការ ។ ប្រសិនបើកុមារអាចរំពឹងទុកមុននូវអ្វីដែលកើតឡើងប្រការនេះនឹងឆ្ពោះទៅដោះស្រាយការភ័យខ្លាច និងការបារម្ភរបស់កុមារ។

ចងចាំថា នៅពេលដែលអ្នកជួបជាមួយអតិថិជន កុមារទាំងនេះជាញឹកញាប់មានការភ័យខ្លាច ប៉ះទង្គិចផ្លូវចិត្ត និងអាចមិនដែលជួបជាមួយមេធាវីពីមុនមកទេ។ ចំណាយពេលវេលារបស់អ្នក ដើម្បីធ្វើឱ្យពួកគេមានអារម្មណ៍កក់ក្តៅជាមួយអ្នក។

1. អ្នកនឹងចាំបាច់ត្រូវតែបន្តផ្តល់ព័ត៌មានដល់កុមារអំពីៈ

- តួនាទីរបស់មនុស្សនៅក្នុងតុលាការ
- តួនាទីរបស់កុមារនៅក្នុងនីតិវិធីតុលាការ
- ដំណើរការតុលាការ
- អ្វីកើតឡើងក្រោយពីតុលាការ

ព័ត៌មាននេះចាំបាច់ត្រូវផ្តល់ដល់កុមារ តាមរបៀបកុមារមេត្រី។ កែសម្រួលភាសារបស់អ្នក អាស្រ័យលើអាយុ និងសមត្ថភាពរបស់កុមារ។

2. យើងបានបង្កើតឧបករណ៍មួយចំនួនដើម្បីជួយអ្នកក្នុងការផ្តល់ព័ត៌មាននេះដល់កុមារៈ

● បង្ហាញកុមារនូវគំនូរជីវចលអំពីតុលាការនិងពិភាក្សាអំពីអ្វីដែលបានកើតឡើង ។ តើពួកគេមានអារម្មណ៍ដូចម្តេច អំពីអ្វីដែលពួកគេបានឃើញ?

● ផ្តល់ឱ្យកុមារនូវសំណៅមួយច្បាប់នៃកូនសៀវភៅទាំងពីរ : "បូណាទៅតុលាការ" និង "អ្នកណានឹងនៅក្នុងតុលាការ?" រួចអានកូនសៀវភៅទាំងពីរជាមួយពួកគេ ។

3. អនុញ្ញាតឱ្យកុមារនូវពេលវេលាគ្រប់គ្រាន់ ដើម្បីឆ្លើយសំណួរ និងលេងល្បែងមួយចំនួនជាមួយកុមារ-ឧទាហរណ៍ អ្នកអាចសាកល្បងការចងចាំរបស់ពួកគេអំពីអ្នកណានៅក្នុងតុលាការ និងកន្លែងណាដែលពួកគេម្នាក់ៗអង្គុយ ។

**ការផ្តល់ព័ត៌មានដល់ឳពុកម្តាយ ឬអ្នកថែទាំ**

1. អ្នកគួរជួបជាមួយឪពុកម្តាយ/អ្នកថែទាំមុនកាលបរិច្ឆេទនៃសវនាការ ពីព្រោះឪពុកម្តាយ/អ្នកថែទាំ ក៏នឹងចាំបាច់ត្រូវត្រៀមខ្លួនសម្រាប់តុលាការផងដែរ ។ វាជាការសំខាន់ដែលឪពុកម្តាយ ឬអ្នកថែទាំកុមារយល់អំពីដំណើរការតុលាការ និងតួនាទីរបស់កុមារនៅក្នុងដំណើរការ ។ នេះនឹងអនុញ្ញាតឱ្យ ឪពុកម្តាយ ឬអ្នកថែទាំៈ

● ពង្រឹងព័ត៌មានចំពោះកុមារ

● ផ្តល់ការគាំទ្រផ្នែកស្មារតីដល់កុមារនៅក្នុងដំណើរការទាំងមូល

● ធានាថា កុមារទទួលបានជំនួយសមស្របដូចជា មធ្យោបាយធ្វើដំណើរទៅកាន់ជំនួបប្រជុំជាមួយអ្នកប្រឹក្សាយោបល់ និងមេធាវី និងវត្តមាននៅតុលាការ ។

2. ជាញឹកញាប់ឪពុកម្តាយឬអ្នកថែទាំនឹងមិនយល់អំពីដំណើរការតុលាការច្រើនជាងកុមារនោះទេ ។ អ្នកចាំបាច់ត្រូវតែពន្យល់អំពីដំណើរការតុលាការទៅកាន់ឪពុកម្តាយៈ

● បង្ហាញពួកគេនូវគំនូរជីវចលអំពីតុលាការដែលអ្នកបានបង្ហាញដល់កុមារ ។

● យើងបានរៀបចំកូនសៀវភៅជាពិសេសសម្រាប់ឪពុកម្តាយ/អ្នកថែទាំដើម្បីពន្យល់ដល់ពួកគេអំពី ដំណើរការតុលាការ និងបទបញ្ជាផ្ទៃក្នុងតុលាការៈ "ការជួយកុមារត្រៀមខ្លួនសម្រាប់តុលាការ " ។

- អានកូនសៀវភៅនេះជាមួយឪពុកម្តាយ/អ្នកថែទាំ

- ផ្តល់ឱ្យឪពុកម្តាយ/អ្នកថែទាំនូវសំណៅមួយច្បាប់នៃកូនសៀវភៅដើម្បីយកទៅ ។

3. ពន្យល់ដល់ឪពុកម្តាយ/អ្នកថែទាំថាកុមារជាញឹកញាប់មានការភ័យខ្លាចខ្លាំងក្នុងការទៅតុលាការហើយកុមារនឹងត្រូវការជំនួយផ្នែកស្មារតីបន្ថែមពីឪពុកម្តាយ/អ្នកថែទាំក្នុងអំឡុងពេលនេះ ។

4.ពន្យល់ដល់ឪពុកម្តាយ/អ្នកថែទាំថា អ្នក (ឬអ្នកគ្រប់គ្រងករណី) នឹងទាក់ទងពួកគេនៅពេលកាលបរិច្ឆេទនៃសវនាការត្រូវបានកំណត់ភ្លាម ហើយវាជាការសំខាន់ដែលឪពុកម្តាយ/អ្នកថែទាំត្រៀមខ្លួន កុមារឱ្យរួចរាល់ដើម្បីចូលរួមនៅក្នុងតុលាការនៅកាលបរិច្ឆេទនោះ ។ នេះរួមបញ្ចូលទាំង:

- ប្រសិនបើចាំបាច់ ពន្យល់ដល់សាលារៀនរបស់កុមារថា កុមារនឹងអវត្តមាននៅកាលបរិច្ឆេទ នៃសវនាការ ។
- ធ្វើការរៀបចំដើម្បីចូលរួមនៅក្នុងសវនាការដូចជាការស្នើសុំច្បាប់ឈប់សម្រាកពីការងារ និងប្រសិនបើចាំបាច់រៀបចំការថែទាំកុមារសម្រាប់កូនផ្សេងទៀត ។
- ត្រៀមខ្លួនកុមារឱ្យរួចរាល់នៅថ្ងៃនៃសវនាការ និងប្រាកដថាពួកគេជួបជាមួយអ្នក និងអ្នកប្រឹក្សាយោបល់ នៅពេលវេលាដែលបានព្រមព្រៀងមុនសវនាការ ។

## ជំហានទីបួន : ពិចារណាអំពីការរៀបចំសម្រាប់ការចូលរួមនៅក្នុងតុលាការ

1.ធ្វើការរៀបចំសម្រាប់បន្ទប់រង់ចាំជាក់លាក់មួយ

- វាអាចជាការភ័យខ្លាច និងភិតភ័យខ្លាំងសម្រាប់កុមារ ប្រសិនបើគាត់ ឬនាងជួបជនជាប់ចោទនៅក្នុងតុលាការមុនសវនាការ ។
- កុមារមានសិទ្ធិរង់ចាំនៅក្នុងបន្ទប់រង់ចាំដាច់ដោយឡែកមួយនៅក្នុងតុលាការមុនពេលគាត់ ឬនាងចូលក្នុងបន្ទប់ ។
- ទំនាក់ទំនងជាមួយក្រឡាបញ្ជីមុនកាលកាលបរិច្ឆេទនៃសវនាការដើម្បីធានាថាបន្ទប់រង់ចាំដាច់ដោយឡែកមួយត្រូវបានបម្រុងទុកសម្រាប់កុមារ ។

2.ពិចារណាអំពីការរៀបចំដែលចាំបាច់សម្រាប់ជំនួយសក្ខីកម្មកុមារមេត្រី

ការផ្តល់សក្ខីកម្មដែលមានរបាំងសាក្សី ឬភ្ជាប់តាមទូរទស្សន៍

- សួរកុមារថាតើគាត់ឬនាងមានការភ័យខ្លាចក្នុងការផ្តល់ភស្តុងតាងនៅចំពោះវត្តមានជនជាប់ចោទ ឬទេ ។
- ប្រសិនបើដូច្នោះចូរពន្យល់ថាអ្នកអាចស្នើសុំឱ្យតុលាការប្រើរបាំងសវនាការដែលញែកកុមារពីជនជាប់ចោទ ដើម្បីកុំឱ្យជនជាប់ចោទអាចមើលឃើញកុមារ ។
- ប្រសិនបើអ្នកគិតថា ទោះជាមានរបាំងសវនាការក៏ដោយ កុមារនៅតែងាយរងគ្រោះខ្លាំងរហូតដល់ សូម្បីតែនៅជាមួយគ្នាក្នុងបន្ទប់តែមួយជាមួយជនរងគ្រោះមានការភ័យខ្លាចខ្លាំង ឬជាការគំរាមកំហែងចំពោះកុមារ អ្នកអាចស្នើសុំទៅកាន់តុលាការដើម្បីឱ្យកុមារផ្តល់ភស្តុតាងតាមរយ:បន្ទប់សវនាការដែលភ្ជាប់បណ្តាញទូទរទស្សន៍ដើម្បីយកសក្ខីកម្ម ។

ភ្លាមៗក្រោយពេលអ្នកត្រូវបានជូនដំណឹងអំពីកាលបរិច្ឆេទសវនាការ ចូរសរសេរលិខិតមួយច្បាប់ទៅកាន់ក្រឡាបញ្ជីតុលាការ ដើម្បីស្នើសុំឱ្យមានរបាំងសាក្សី ឬបរិក្ខារ CCTV (បន្ទប់សវនាការដែលភ្ជាប់បណ្តាញទូរទស្សន៍ដើម្បីយកសក្ខីកម្ម) សម្រាប់ការជំនុំជម្រះក្តី ។

- [សូមមើលគំរូដែលប្រើដោយ IJM នៅផ្នែកចុងក្រោយនៃជំពូកនេះ]

● ប្រាកដថា បរិក្ខារទាំងនេះនឹងត្រូវបានបង្កើតឡើង មុនការចាប់ផ្ដើមការជំនុំជម្រះក្ដី ដើម្បីកុំឱ្យកុមារមើលឃើញជនជាប់ចោទ នៅពេលកុមារដើរចូលក្នុងបន្ទប់សវនាការ ។

● នៅថ្ងៃមុនសវនាការ ហៅទៅកាន់ក្រឡាបញ្ជីតុលាការដើម្បីបញ្ជាក់អះអាងថាការរៀបចំត្រូវបានធ្វើឡើង ។

● កុំធ្វើការសន្យាណាមួយចំពោះកុមារ ប៉ុន្តែនៅពេលអ្នកបានអះអាងជាមួយតុលាការថា ការរៀបចំទាំងនេះអាចរកបាន ចូរជូនដំណឹងដល់កុមារ ដើម្បីឱ្យកុមារដឹងអំពីអ្វីដែលត្រូវរំពឹង ។

អ្នកគាំទ្រសាក្សី

● សួរយោបល់កុមារថាតើគាត់ឬនាងមានការភ័យខ្លាចក្នុងការផ្ដល់ភស្ដុតាងនៅចំពោះវត្តមានជនជាប់ចោទដោយមិនចាំបាច់មានអ្នកណាម្នាក់ឈរ ឬអង្គុយក្បែរខ្លួនឬទេ ។

● សួរកុមារថាតើគាត់/នាងនឹងមានអារម្មណ៍កាន់តែងាយស្រួលឬទេ ប្រសិនបើមានអ្នកគាំទ្រម្នាក់ត្រូវបានអនុញ្ញាតឱ្យឈរក្បែរគាត់/នាង ខណៈកុមារផ្ដល់ភស្ដុតាង ។ ប្រសិនបើដូច្នោះ តើកុមារចង់ឱ្យអ្នកគាំទ្រនោះជាអ្នកណា?

● ភ្លាមៗក្រោយពីអ្នកត្រូវបានជូនដំណឹងអំពីកាលបរិច្ឆេទសវនការ ចូរសរសេរលិខិតមួយច្បាប់ទៅកាន់ក្រឡាបញ្ជីតុលាការដើម្បីស្នើសុំឱ្យអនុញ្ញាតដល់អ្នកគាំទ្រសាក្សី ។

● កុំធ្វើការសន្យាណាមួយចំពោះកុមារ-ប៉ុន្តែភ្លាមៗក្រោយពីក្រឡាបញ្ជីតុលាការបានអះអាងថាការរៀបចំត្រូវបានអនុញ្ញាត ចូរជូនដំណឹងដល់កុមារ ។

3. ពិចារណាអំពីការរៀបចំការពារ

● ភ្លាមៗក្រោយពីអ្នកត្រូវបានជូនដំណឹងអំពីកាលបរិច្ឆេទសវនាការចូរសរសេរលិខិតមួយច្បាប់ទៅក្រឡាបញ្ជីតុលាការ ដោយស្នើសុំនូវវិធានការណាមួយដូចខាងក្រោម ប្រសិនបើវិធានការទាំងនេះមានភាពសមស្រប:

- សវនាការអសាធារណៈ
- ដីកាការពារ
- ការហាមឃាត់លើប្រព័ន្ធផ្សព្វផ្សាយ និងសារព័ត៌មានដែលផ្សាយព័ត៌មានលាតត្រដាងអត្តសញ្ញាណរបស់កុមារ ។

4. ពិចារណាអំពីការរៀបចំផ្នែកភស្ដុភារសម្រាប់ការចូលរួមនៅក្នុងតុលាការ

● ធម្យោបាយធ្វើដំណើរ

- ធានាថា កុមារ ឪពុកម្ដាយ/អ្នកថែទាំ អ្នកគាំទ្រ (ប្រសិនបើមាន) និងអ្នកប្រឹក្សាយោបល់បានរៀបចំមធ្យោបាយធ្វើដំណើរទៅកាន់តុលាការ ដោយមានពេលវេលាច្រើន ។
- កុមារមិនគួរត្រូវបានដឹកជញ្ជូនទៅកាន់តុលាការនៅក្នុងយានយន្តតែមួយជាមួយជនជាប់ចោទជាដាច់ខាត ។

- ការមកដល់តុលាការ

- មុនថ្ងៃសវនាការយល់ព្រមចំពោះសមាជិកនីមួយៗនៃក្រុម (អ្នកប្រឹក្សាយោបល់ អ្នកថែទាំ មេធាវី អ្នកគ្រប់គ្រងករណីមេធាវី) អំពីកន្លែងពិតប្រាកដដែលអ្នកនឹងជួបគ្នានៅថ្ងៃសវនាការ ។

- អ្នកថែទាំកុមារ

- អះអាងថាអ្នកថែទាំកុមារមានព័ត៌មានទាំងអស់អំពីកាលបរិច្ឆេទ និងទីកន្លែងនៃសវនាការ និងបានធ្វើការរៀបចំទាំងអស់ដែលចាំបាច់ដើម្បីអមដំណើរកុមារទៅកាន់តុលាការនៅថ្ងៃនោះ ។







# ថ្ងៃសវនាការ



## នាំ “ក្រុម” របស់អ្នកសម្រាប់ថ្ងៃនោះ

នៅថ្ងៃបើកសវនាការសមាជិកគ្រប់រូបនៃក្រុមគាំទ្រតុលាការនឹងចាំបាច់ត្រូវតែបំពេញតួនាទីរបស់ពួកគេដើម្បីគាំទ្រ និងការពារកុមារ ។

## អ្វីដែលអ្នកចាំបាច់ត្រូវធ្វើ ប្រសិនបើអ្នកគឺជាអ្នកគាំទ្រមិនមែនផ្នែកច្បាប់

តួនាទីរបស់អ្នកនៅថ្ងៃសវនាការមានសារៈសំខាន់ខ្លាំងណាស់ ។ អ្នកនៅទីនោះដើម្បីគាំទ្រផ្នែកស្មារតីចំពោះកុមារ ការពារកុមារពីជនជាប់ចោទ និងនិយាយចេញប្រសិនបើអ្នកគិតថា វិធានការណ៍កុមារមេត្រី មិនត្រូវបានប្រើប្រាស់ទេនោះ ។

ចងចាំថា កុមារប្រហែលជាកំពុងមានអារម្មណ៍ភ័យខ្លាច ភិតភ័យ ឬប្រហែលជាមិនមានសុវត្ថិភាព និងមិនអាចជំនះអារម្មណ៍បាន ។ ពួកគេអាចស្ថិតនៅក្នុងសភាព “តានតឹង” ដោយការមើលឃើញជនជាប់ចោទ ឬត្រូវបានដាក់ឱ្យស្ថិតក្នុងស្ថានភាពមួយដែលពួកគេចាំបាច់ត្រូវនិយាយអំពីការចងចាំដែលប៉ះទង្គិចផ្លូវចិត្តរបស់ខ្លួន ។

សូមមើលការត្រួតពិនិត្យសម្រាប់អ្នកគាំទ្រមិនមែនផ្នែកច្បាប់សម្រាប់ដំបូន្មានបន្ថែម ។

## អ្វីដែលអ្នកចាំបាច់ត្រូវធ្វើ ប្រសិនបើអ្នកគឺជាមេធាវី

តួនាទីរបស់អ្នកនៅថ្ងៃបើកសវនាការមានសារៈសំខាន់ខ្លាំងណាស់ ។ អ្នកនៅទីនោះដើម្បីធ្វើជាតំណាងផ្លូវច្បាប់ឱ្យកុមារ និងធានាថា នីតិវិធីកំពុងត្រូវបានធ្វើឡើងដើម្បីឧត្តមប្រយោជន៍ល្អបំផុតរបស់កុមារ ។ អ្នកចាំបាច់ត្រូវតែធានាថា កុមារយល់នូវអ្វីៗទាំងអស់ដែលកំពុងកើតឡើងនៅក្នុងតុលាការថាសំណួរទាំងឡាយណាចំពោះកុមារត្រូវបានសួរតាមរបៀបកុមារមេត្រី និងថា កុមារទទួលបានកិច្ចការពារផ្នែកច្បាប់ ។

កុំភ្លេចប្រើជំនួយរបស់សមាជិកផ្សេងទៀតនៃក្រុម-អ្នកប្រឹក្សាយោបល់ ឪពុកម្តាយ ឬអ្នកថែទាំកុមារ និងអ្នកគ្រប់គ្រងករណី-ដើម្បីជួយអ្នកក្នុងការគាំទ្រ និងការ-ពារកុមារពេញមួយថ្ងៃ ។

សូមមើលការត្រួតពិនិត្យសម្រាប់មេធាវី និងពិនិត្យមើលសំណួរដែលអ្នកចាំបាច់ត្រូវបញ្ឈប់នៅក្នុងសវនាការខាងក្រោមសម្រាប់ដំបូន្មានបន្ថែម ។



## សំណួរដែលអ្នកចាំបាច់ត្រូវបញ្ឈប់នៅក្នុងសវនាការ

ការងាររបស់អ្នកគឺទទូចឱ្យមានការសួរសំណួរសមស្របចំពោះកុមារ ។ ប្រសិនបើអ្នកពិនិត្យឃើញមានការសួរសំណួរប្រភេទនេះពីមេធាវីការពារចុងចោទព្រះរាជអាជ្ញា ឬចៅក្រម អ្នកគួរធ្វើការជំទាស់ទៅចៅក្រម និងស្នើសុំឱ្យបញ្ឈប់ការសួរសំណួរនោះ និងស្នើឱ្យសួរសំណួរនោះតាមរបៀបផ្សេងដែលមានលក្ខណៈកុមារមេត្រី ។

1. សំណួរដែលធ្វើឱ្យយល់ច្រឡំ (ជំទាស់ ប្រសិនបើកុមារទំនងជាមិនយល់ ឬកំពុងយល់ច្រឡំ) ។

## សំណួរដែលមានគោលបំណងពីរយ៉ាង:

សំណួរ :“អ្នកបានអញ្ជើញគាត់ចូលក្នុង មែនទេ?” អ្នកចង់ឱ្យគាត់មកនិងជួបអ្នកនៅល្ងាចនោះ មែនទេ?

សំណួរ :“តើអ្នកបានឃើញបុរសនោះលើកដំបូងនៅពេលណានិងនៅកន្លែងណា?”

● សំណួរតែមួយប៉ុណ្ណោះគួរត្រូវបានសួរក្នុងមួយលើក ដើម្បីឱ្យកុមារអាចយល់ថាតើសំណួរណាមួយដែលគាត់ ឬនាងកំពុងឆ្លើយ ។

សំណួរបដិសេធ

សំណួរ : វាគឺជាករណី តើវាមិន ដែលអ្នកមិនបាន....?

សំណួរ : តើអ្នកមិនយល់ស្របជាមួយរឿងនោះទេឬ?

សំណួរ : តើអ្នកកំពុងនិយាយថាគ្មានរឿងបែបនោះណាមួយធ្លាប់បានកើតឡើងឬ?

សំណួរពិបាកផ្នែកទស្សនាទាន (អាស្រ័យលើអាយុកុមារ)

សំណួរ : តើគាត់បានប៉ះពាល់អ្នករយៈពេលយូរប៉ុណ្ណា?

2. សំណួរប្រមាថ ឬបំពាន

សំណួរដែលទាមទារសេចក្តីលម្អិតដែលមិនចាំបាច់អំពីឧប្បត្តិហេតុផ្លូវភេទ

សំណួរដែលបង្កប់ន័យថាកុមារ “បានរីករាយនឹង” បទពិសោធន៍ផ្លូវភេទ

សំណួរ : “តើអ្នករីករាយនឹងវា មែនទេ?”

3. សំណួរមិនពាក់ព័ន្ធ

វាអាចមិនពាក់ព័ន្ធក្នុងការស្វែងរកការពន្យល់អំពីអាកប្បកិរិយា ប្រសិនបើវាមានតម្លៃផ្នែកភស្តុតាងបន្តិចបន្តួច និងមិនពាក់ព័ន្ធសម្រាប់គោលបំណងជំនុំជម្រះ ។

4. សំណួរច្រំដែល

ការសួរសំណួរច្រំដែលជាប្រចាំនៅក្នុងទម្រង់ដដែលអាចលើកទឹកចិត្តកុមារឱ្យកែប្រែចម្លើយរបស់ពួកគេ យោងតាមអ្វីដែលពួកគេអាចគិតថាអ្នកសួរសំណួរចង់ឮ។

សំណួរ : "អ្នកមិនបានប្រាប់អ្នកណាម្នាក់ទេ មែនទេ?"

សំណួរ : "តើអ្នកបានប្រាប់អ្នកណាម្នាក់ឬទេ?"

សំណួរ : "តើអ្នកបានប្រាប់មនុស្សចំនួនប៉ុន្មាននាក់?"

5. សំណួរដែលមានវាក្យសព្ទពិបាកនេះរួមបញ្ចូលទាំងបច្ចេកសព្ទច្បាប់:

សំណួរ : "តើអ្នកបានផ្តល់ភស្តុតាងពីមុនអំពី...?"

6. លើកលែងតែកុមារបានអភិវឌ្ឍជំនាញយល់ដឹងល្អ សំណួរប្រៀបធៀបរយៈពេល ឬចំនួន។

សំណួរ : "តើវាបានកើតឡើង ៣ ខែកន្លងមក ប ៤ ខែកន្លងមក?"

សំណួរ : តើវាបានកើតឡើងប៉ុន្មានដង? ៥ ដង? ១០ ដង?

7. សំណួរមិនច្បាស់លាស់

សំណួរ : ក្រោយពីសួរអំពីបងប្អូនប្រុស និងពូ/អ៊ុំប្រុសរបស់កុមារ: "តើគាត់នៅក្នុងបន្ទប់ឬ?"(អ្នកណា? បងប្អូនប្រុស ឬឪពុក?)

8. សំណួរ "មានកន្ទុយ"

សំណួរ "មានកន្ទុយ" គឺជាសំណួរដែលអំណះអំណាងត្រូវបានធ្វើឡើងនិងបន្ទាប់មកសំណួរខ្លីមួយដែលបញ្ជាក់អំណះអំណាងនោះ ត្រូវបានបន្ថែមនៅខាងចុង:

សំណួរ : "អ្នកបាននៅផ្ទះនៅថ្ងៃនោះ មែនទេ?"

9. សំណួរដែលមានជម្រើសរឹតត្បិត

សំណួរដែលមានជម្រើសរឹតត្បិតគ្រាន់តែផ្តល់ឱ្យកុមារនូវជម្រើសរវាងចម្លើយដែលត្រូវបានស្នើឡើងរួចជាស្រេចប៉ុណ្ណោះ:

"សំណួរ : នៅពេលដែលគាត់វាយអ្នក តើអ្នកបានស្រែក ឬយំ?"



### ការសាកសួរ (ទាំងអ្នកគាំទ្រមិនមែនផ្នែកច្បាប់និងមេធាវី)

ការងាររបស់អ្នកមិនទាន់បញ្ចប់ទេ នៅពេលសវនាការត្រូវបានបញ្ចប់ ។

ផ្នែកសំខាន់ខ្លាំងបំផុតមួយនៃការគាំទ្រ និងការការពារកុមារ គឺ "ការសាកសួរ" ជាមួយកុមារ ក្រោយពេលសវនាការ ។

នេះមានន័យថា ក្នុងលក្ខណៈជាក្រុម អ្នកគួរចំណាយពេលវេលាខ្លះក្រោយពេលសវនាការបានបញ្ចប់ដើម្បីជួបជុំគ្នាជាមួយកុមារនៅកន្លែងឯកជននិងធ្វើកិច្ចការដូចខាងក្រោម:

- អរគុណកុមារដែលមានភាពក្លាហានគ្រប់គ្រាន់ក្នុងការបង្ហាញខ្លួននៅក្នុងតុលាការ
- អះអាងឡើងវិញចំពោះកុមារថា ពួកគេធ្វើកិច្ចការបានល្អ
- ពន្យល់កុមារថា ចៅក្រមនឹងត្រូវការពេលវេលាខ្លះដើម្បីពិចារណាអំពីអ្វីៗដែលត្រូវបាននិយាយនៅក្នុងតុលាការ ។ ទោះបីជាសាលក្រម គឺ "គ្មានពិរុទ្ធ" ក៏ដោយ វាជាការសំខាន់ដែលត្រូវយល់ថា នេះមិនមែនមានន័យថា ចៅក្រមមិនបានជឿកុមារនោះទេ ។ ភស្តុតាងរបស់កុមារគ្រាន់តែជាផ្នែកមួយនៃរឿងរ៉ាវប៉ុណ្ណោះហើយចៅក្រមអាចសម្រេចថា មិនមានភស្តុតាងគ្រប់គ្រាន់ ។
- ពន្យល់កុមារអំពីអ្វីដែលកើតឡើងបន្ទាប់-ថាអ្នកនឹងទាក់ទងទៅឪពុកម្តាយ ឬអ្នកថែទាំកុមារ នៅពេលដែលកាលបរិច្ឆេទចេញសាលក្រម និងការកាត់ទោសត្រូវបានជូនដំណឹងភ្លាម ។

សួរកុមារថា តើពួកគេមានចម្ងល់ណាមួយអំពីអ្វីដែលបានកើតឡើងនៅក្នុងតុលាការនៅថ្ងៃនេះដែរ ឬទេ រួចដោះស្រាយចម្ងល់ទាំងនោះ ។



HAGAR
the whole journey

unicef
unite for children